OLD VERSION

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 09-Jun-2015, 08:30

CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៨៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ាង

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ស្រ៊ា រតនៈ

លោក ត្រាវីស ហ្វារ

*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms. Marie GUIRAUD)*

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| កញ្ញា សុង ឆវន្ត | ខ្មែរ |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី សៀង សុរិដា (2-TCCP-273) | ខ្មែរ |
| លោក អ៊ុត សេង (2-TCW-804) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី សៀង សុទិដា** (2-TCCP-273)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៣
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................ទំព័រ ៤
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី ....................ទំព័រ ២៧
សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី ....................ទំព័រ ៣៧
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៤២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៤៤
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ....................ទំព័រ ៥៤
សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្តើមពី ....................ទំព័រ ៥៥
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៥៨

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុត សេង** (2-TCW-804)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៦៩
សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ....................ទំព័រ ៧២
សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ....................ទំព័រ ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-273។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០៤:០៧]

ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCCP-273។ ដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះផងដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-804។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥។

[០៩:០៥:២៩]

មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា នៅថ្ងៃនេះ មានអាការៈឈឺចង្កេះខ្លាំង វិលមុខពេលបំលាស់ទី និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួន ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:៤១]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា នៅក្នុងអំឡុង

ពេលស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-273 គឺមានវត្តមានបុគ្គលិកអង្គការ ធី.ភី.អូ ឈ្មោះ ថ្លែន សុគន្ធណារ៉ា អង្គុយអមដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពង្រឹងស្មារតីគាត់ នៅក្នុងអំឡុងពេលដែលដើមបណ្តឹងរដ្ឋប្បវេណីនេះ ផ្តល់សក្ខីកម្មនៅថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-273 រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:១០:០៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអ្វី?

**លោកស្រី សៀង សុវិដា៖**

**ឆ៖** នាងខ្ញុំសូមគោរពប្រធាន និងលោកចៅក្រម ព្រះរាជអាជ្ញា មេធាវីទាំងអស់ ភ្ញៀវជាតិនិងអន្តរជាតិដែលមានវត្តមាននៅទីនេះ។ នាងខ្ញុំឈ្មោះ សៀង សុវិដា។ ឈ្មោះកំណើត លី ស៊ីងួន ហៅស៊ីនួន។

**ស៖** លោកស្រីកើតនៅថ្ងៃខែឆ្នាំណា ចាំទេ?

**ឆ៖** នាងខ្ញុំកើតឆ្នាំពិតប្រាកដ ១៩៦៤។

**ស៖** បាទ អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកស្រី នៅទីកន្លែងណា?

**ឆ៖** នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ហើយទីលំនៅសព្វថ្ងៃនេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** នៅផ្សារថ្មីទី១ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ។

**ស៖** បាទ អរគុណ។ ហើយលោកស្រីប្រកបមុខរបរធ្វើអ្វី?

**ឆ៖** នាងខ្ញុំ មន្ត្រីរាជការក្នុងក្រសួងមហាផ្ទៃ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអ្វី?

**ឆ៖** លី ជីវសៀង។

**ស៖** ចុះម្តាយបង្កើត គាត់ឈ្មោះអ្វី?

**ឆ៖** គាត់ឈ្មោះ ម៉ៅ គឹមយ៉ាន។

[០៩:១២:១២]

**ស៖** បាទ អរគុណ។ ហើយស្វាមីរបស់លោកស្រីឈ្មោះអ្វី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** គាត់ឈ្មោះ ម៉ុក ប្រឌិតវាសនា។ កូនពីរនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រី សៀង សុវិដា។ ហើយជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកស្រី ក្នុងឋានៈលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានឡើងចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើសិនជាលោកស្រីមានបំណងធ្វើដូច្នេះ។

អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញបាទ!

[០៩:១៣:៣០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ លោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រី សៀង សុវិដា។ នៅព្រឹកនេះ ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកស្រី។ សំណួរទី១ គឺខ្ញុំចង់សុំបំភ្លឺលោកស្រីៗ ឆ្លើយជូនលោកប្រធានថា លោកស្រីកើតនៅឆ្នាំ៦៤ ក៏ប៉ុន្តែនៅពេលដែលយើងអានអត្តសញ្ញាណប័ណ្ណលោកស្រី ដែលភ្ជាប់ទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺឯកសារ E -- D22/2531 ក្នុងនោះគេដាក់ថ្ងៃខែឆ្នាំកំណើតលោកស្រី គឺ

១៩៦៧។ អ៊ីចឹងលោកស្រីអាចបញ្ជាក់ជូនបានទេ ថាហេតុអ្វីបានជា អត្តសញ្ញាណប័ណ្ណរបស់លោកស្រីគឺឆ្នាំ៦៧ ហើយអម្បាញ់មិញនេះ លោកស្រីឆ្លើយជូនលោកប្រធានថាឆ្នាំ៦៤? អ៊ីចឹងតើមួយណាដែលត្រឹមត្រូវដែរលោកស្រី?

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ចាស ជម្រាបសួរ។ ពេលដែលនាងខ្ញុំចេញពីភ្នំពេញមក -- ពេលចេញមកពីរបប ប៉ុល ពត មកនាងខ្ញុំជាកូនកំព្រា រស់នៅជាមួយឪពុកមា និងម្ដាយមីងរបស់នាងខ្ញុំគាត់ដាក់ប្រវត្តិរូប ហើយឈ្មោះអីគាត់ដូរ ដាក់តាមជាខ្មែរ ហើយគាត់ដាក់តាម ឲ្យសមស្របនឹងកូនរបស់គាត់ មិនឲ្យឃ្លាតឆ្ងាយពីហ្នឹងពេក។ តែដល់ឆ្នាំពិតប្រាកដនាងខ្ញុំ គឺកើតឆ្នាំ១៩៦៤ ជាឆ្នាំពិតប្រាកដ។ ហើយប្រើរាល់ថ្ងៃនេះគឺ ១៩៦៧ ដាក់ឈ្មោះ សៀង សុវិដា ឈ្មោះខ្ញុំកំណើតគឺ លី ស៊ីម្ហួន។ នេះ ជាការពិតប្រាកដរបស់នាងខ្ញុំ។

[០៩:១៥:១៨]

**ស៖** សូមអរគុណ។ ខ្ញុំសូមយោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី គឺឯកសារលេខ D22/2531 ERN ជាភាសាបារាំង 01095759, ជាភាសាអង់គ្លេស 01063843, ជាភាសាខ្មែរ 00552159។ នៅក្នុងកថាខណ្ឌទី១នេះ លោកស្រីបានពន្យល់អំពីខ្សែជីវិតរបស់លោកស្រី គឺចាប់ពីថ្ងៃទី១៧ មេសា ៧៥។ ខ្ញុំគ្រាន់តែចង់ឲ្យលោកស្រីបញ្ជាក់អំពីខ្សែជីវិតរបស់លោកស្រី បន្ទាប់មកទៀត ខ្ញុំនឹងផ្ដល់សំណួរទៅលើបទពិសោធន៍របស់លោកស្រីនៅទំនប់១មករា។ យោងទៅតាមឯកសារនេះ គឺនៅកថាខណ្ឌទី១ លោកស្រីគឺបានបញ្ជាក់ថា នៅថ្ងៃទី១៧ មេសា ៧៥ លោកស្រីនៅភ្នំពេញជាមួយគ្រួសារ។ បន្ទាប់មកទៀតគេជម្លៀសទៅខេត្តកណ្ដាល។ បន្ទាប់មកទៀត គឺបញ្ជូនទៅខេត្តកំពង់ចាម។ លោកស្រីស្នាក់នៅភូមិមួយនៅក្នុង គេហៅថា មុខភ្នំ – ភូមិមុខភ្នំ ដែលសុទ្ធតែជាព្រៃ។ ក្រោយមកទៀត ទៅភូមិឫស្សីគីឡូ នៅក្នុងស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា តើអ្វីៗដែលលោកស្រីបានរៀបរាប់នោះ ពិតជាត្រឹមត្រូវដែរឬទេ?

[០៩:១៧:០៦]

**ឆ៖** ចាស អ្នកស្រីពិតជាត្រឹមត្រូវ។ នៅថ្ងៃ១៧ មេសា តែនាងខ្ញុំចេញពីភ្នំពេញថ្ងៃទី១៨។ ចេញមកតាមផ្លូវចំនួន៣ថ្ងៃ មកដល់នឹងកៀនស្វាយ សំណាក់នៅកៀនស្វាយប្រហែល១ខែ។ បន្ទាប់មកក៏ឡើងកាណូត គេជម្លៀសទៅនៅវត្ត ជិតព្រែកជំនីត វត្តស្រឡៅដំណាក់ គឺវត្តជំនីត។ កាលហ្នឹង ខ្ញុំនៅតូចដែរ ទៅសំណាក់នៅទីនោះ១ខែ បន្ទាប់មកបញ្ជូនប្រជាជនបណ្ដើរៗ ប្រហែលជា១០០, ២០០នាក់អ៊ីចឹង

ទៅនៅភូមិមុខភ្នំ ឃុំទួលស្នួល ស្រុកក្រូចឆ្មា ខេត្តក្រចេះ -- ខេត្តកំពង់ចាម។ នៅទីនោះចំនួន៦ខែ ពេលនោះ ទៅដល់ទីនោះ គឺគ្មានអ្វីទាំងអស់ នៅលើខ្នងភ្នំសុទ្ធតែព្រៃ ធ្វើផ្ទះតូចៗពីរជួរ។ ពេលនោះម្ដាយខ្ញុំគាត់ចាញ់ទឹកចាញ់ដី និងប្អូនស្រីខ្ញុំ ហើយខ្ញុំនៅតូច នៅជាកងកុមារ។ ហើយប៉ាខ្ញុំ គេឲ្យកាប់ភ្លឺស្រែ ធ្វើជាសិប្បកម្មជាមួយចាស់ ធ្វើសព្វបែបយ៉ាង ទាំងម្ដាយ ទាំងបងស្រី។ ហើយនាងខ្ញុំធ្វើការ ក្រៅពីម៉ោងធ្វើការ ពេលម្ដាយឪពុកម្ដាយខ្ញុំ គាត់អត់មានអីពិសា នៅពេលនោះគេចែកអង្ករក្នុងម្នាក់កន្លះកំប៉ុង មានពោត ហើយសម្លរម។ សម្លគេ គេស្លនឹងខ្ទះ ហើយគេដួសតាមគ្រួសារ យកចានទៅដួសមកៗញ៉ាំតាមគ្រួសារ។ ពេលនោះរបបយើងញ៉ាំ យើងអត់ញ៉ាំឆ្អែតទេ ឃ្លាន។ ហើយពេលម្ដាយឈឺ ហើយខ្ញុំឃើញការពិបាកហ្នឹង ខ្ញុំឆ្លៀតដើររកក្ដាមខ្យងត្រីនៅក្រោយផ្ទះ ជួនខ្ញុំដើរហួសទៅដល់ផ្ទះប្រជាជនឆ្ងាយ បើគេឃើញខ្ញុំ គេចាប់ខ្ញុំសម្លាប់ហើយ។ ប៉ុន្តែខ្ញុំតស៊ូ ខ្ញុំសុខចិត្តអាណិតម្ដាយឪពុកខ្ញុំ ខ្ញុំសុទ្ធចិត្តដើរទៅរក។ ពេលនោះគាត់ខំប្រឹងដាំដំណាំនៅក្នុងផ្ទះ ពេលបានផលប្រហែល៦ខែ គេជម្លៀសយកចេញទៅត្រើយម្ខាងទៀត ខាងភូមិឫស្សីកែវលើ សង្កាត់ឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ ពេលនោះ នាងខ្ញុំបាននៅទីនោះ គេធ្វើផ្ទះតូចខ្ទមនៅខាងក្រោយភូមិ។ មកដល់ទីនេះប៉ាខ្ញុំឈឺទៀត។ ហើយវាចោទប៉ាខ្ញុំថាប៉ាខ្ញុំនាយទុន ថាប៉ាខ្ញុំអីចេះអីចុះ ហើយចាប់ពួកខ្ញុំជាក្មេងៗហ្នឹងសួរពីឪពុក ឪពុកធ្វើអីៗអីចឹងទៅ ខ្ញុំអត់ប្រាប់ត្រង់ទេ ខ្ញុំចេះតែភរគាត់ដែរ។

[០៩:១៩:៤៦]

ដល់តែពេលក្រោយមកទៀតបានខ្ញុំនៅកងកុមារ ឲ្យធ្វើការសព្វបែបយ៉ាងជាមួយកុមារ។ ក្រោយមកក៏ឃើញខ្ញុំរាងជំទង់ ក៏យកខ្ញុំចូលកងចល័តភូមិជាមួយបងស្រីរបស់ខ្ញុំ។ នៅពេលធ្វើការជាមួយបងស្រីរបស់ខ្ញុំហ្នឹងទៅ បានប៉ុន្មានខែទេ។ ពេលធ្វើការហ្នឹងមិនមែននៅក្នុងភូមិទេ គឺចូលទៅក្នុងព្រៃតាមព្រៃក្នុងៗជ្រៅ ហើយខ្ញុំតូចហ្នឹងទៅធ្វើសព្វបែបយ៉ាងដូចគេអីចឹង។ ហត់តែមិនដឹងនិយាយថាម៉េចឃ្លានក៏ខ្ញុំមិនដឹងថាម៉េចដែរ។ ខ្ញុំតស៊ូធ្វើខ្លាចស្លាប់ទាំងអស់គ្នា អត់ហ៊ានឈប់ទេ ចេញពីភូមិមួយទៅភូមិ -- ចេញពីទីកន្លែងការដ្ឋានមួយទៅកន្លែងការដ្ឋានមួយ។ ខ្ញុំអត់ចាំថា ការដ្ឋានឈ្មោះអីខ្លះទេ តែថ្ងៃមួយមានការដ្ឋានមួយ ខ្ញុំភ្លេចជម្រាបក្នុងក្រដាសហ្នឹង ភូមិខ្សាត់ ភូមិហ្នឹងគឺប្រជាជនស្លាប់ឡើងអស់។ ពួកខ្ញុំទៅនៅទីនោះ បាន -- ខ្ញុំអត់ចាំកំណត់ថ្ងៃទេ។ ដល់បន្ទាប់មកទៀតមក វាចាប់បង្ខំបងស្រីខ្ញុំរៀបការ។ បងខ្ញុំទើបចូល១៥ឆ្នាំ ចូល១៦កាលនុំង។ បងខ្ញុំអត់ព្រមទេ ម៉ាក់ខ្ញុំក៏គាត់ទៅសុំថា មិន -- អត់បានទៅរៀបការ ដូចថាគាត់នៅក្មេងអីចឹង មិនចង់ឲ្យរៀបការអីចឹងមានគូដណ្ដឹងអី គាត់អត់ចង់ឲ្យ តែគេអត់

ព្រមទេ។ បើយើងរឹងទទឹង យើងខ្លាចមានគេធ្វើបាប។ អ៊ីចឹងក៏គាត់សុខចិត្តរៀបការទៅ តែបងស្រីខ្ញុំរៀបការហើយ វាចាប់ វាធ្វើបាបបងស្រីខ្ញុំពេលគាត់រៀបការ នាងខ្ញុំមកទំនប់ ១មករា។ នាងខ្ញុំមកកងចល័តស្រុក ១មករា។ ពេលនោះ នៅផ្ទះខ្ញុំក៏អត់ដឹងរឿងហេតុអីទាំងអស់។ ខ្ញុំបាននៅទីនេះ៣ខែ។ នាងខ្ញុំមក៣ខែ ដំបូងគេឲ្យសំណាក់នៅក្រោយជិតវត្តបារាយណ៍ជាន់ដែក ហើយទម្រាំតែគេធ្វើរោងវែងៗមានឈើ មានស្លឹកមានអីហ្នឹងឲ្យពួកខ្ញុំស្នាក់នៅទីនោះ ប្រហែលជិត១ខែ។ ពេលនោះពួកខ្ញុំនៅភូមិនោះ គេហៅ "ចេនឡាទី២" ដូចជាភូមិត្នោត។ អូខេ ពេល--

[០៩:២២:០៥]

**ស៖** សូមអរគុណលោកស្រី។ សូមឲ្យលោកស្រីបញ្ចប់ត្រឹមហ្នឹងសិនហើយ ព្រោះដើម្បីឲ្យខ្ញុំអាចសួរសំណួរផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងពេលដែលលោកស្រីគេបញ្ជូនទៅទំនប់១មករា ដើម្បីឲ្យគេយល់ថា ហេតុអ្វីបានជាលោកស្រីចាកចេញទៅទីនោះ ហើយនិងជីវិតរបស់លោកស្រីនៅ -- ៣ខែនៅការដ្ឋាននោះ។ តើលោកស្រីអាចជម្រាបឲ្យបានខ្លីៗបានទេថា ពេលណាដែរ ហើយហេតុអ្វីបានជាលោកស្រីចេញទៅធ្វើការនៅទំនប់១មករានោះ?

**ឆ៖** ពេលនោះ បងស្រីខ្ញុំបានរៀបការរួច។ ខ្ញុំធ្លាប់តែទៅពីរនាក់បងប្អូននៅចល័តភូមិ ដល់បងស្រីខ្ញុំគាត់រៀបការ បងស្រីខ្ញុំនៅភូមិជាមួយម្ដាយខ្ញុំបាន ខ្ញុំក៏សម្រេចចិត្តថា ខ្ញុំទៅឆ្ងាយដើម្បីជួយក្រុមគ្រួសារក្នុងថា ក្នុងគ្រួសារមួយមានអ្នកធ្វើការកម្លាំងឈានមុខអ៊ីចឹង បែបគេអនុគ្រោះ គេមិនធ្វើបាបនៅក្នុងក្រុមគ្រួសារនាងខ្ញុំទេ។ ពេលនោះនាងខ្ញុំក៏សម្រេចចិត្តទៅ បើខ្ញុំមិនទៅខាងហ្នឹង ក៏គេត្រូវបញ្ជូនទៅទីកន្លែងផ្សេងទៀតដែរ។ អ៊ីចឹងខ្ញុំសម្រេចចិត្តថា ខ្ញុំទៅខាង ១មករា ដែលមានបងៗទៅជាមួយ នៅភូមិជាមួយគ្នានុ៎ង។ តែទីបំផុតត្រឡប់មកវិញ វាធ្វើបាបបងស្រីខ្ញុំបង្អត់បាយ ម្ដាយឪពុកគេធ្វើបាបទាំងអស់គ្នា ក្នុងការងារធ្វើ។ ខ្ញុំមកវិញ ខ្ញុំអស់សង្ឃឹម។ ពេលនោះខ្ញុំឈឺ ខ្ញុំក៏មិន -- ម៉ាក់ខ្ញុំគាត់ថា កូនឯងនៅផ្ទះទៅ កុំទៅឈឺ ខ្ញុំមិននៅទេ បើនៅស្លាប់ទាំងអស់គ្នាហើយ បើឃើញគេកំពុង -- គេកាប់សម្លាប់ច្រើនណាស់នៅក្នុងឆ្នាំ១៩៧៧ហ្នឹង។ ពេលនោះ ខ្ញុំក៏ដាច់ចិត្តទៅ--

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីអាចជម្រាបបានទេថា នៅពេលដែលគេចាត់ឲ្យលោកស្រីទៅធ្វើការនៅទំនប់១មករា នុ៎ងលោកស្រីមានអាយុប៉ុន្មានដែរ?

[០៩:២៤:២៣]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោកស្រី សៀង សុវិដា៖**

**ឆ៖** អាយុ១១ៗឆ្នាំ ចូល១២អង្កាល់នុំង។ ហ្នឹងខ្ញុំចាំអាយុប្រហែលប៉ុណ្ណឹង បើខ្មែរគេថា ១២ បើយើងរាប់តាមឆ្នាំបរទេស គឺ១១ជាង។ នាងខ្ញុំតូចជាងគេទាំងអស់។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមអានឃ្លាមួយនៅក្នុងឯកសារព័ត៌មានបន្ថែម ដែលលោកស្រីបានដាក់ជូន អ.វ.ត.ក គឺឯកសារលេខ E307/6.1.6 ERN ជាភាសាបារាំង 01030294, ជាភាសាអង់គ្លេសគឺ 01063819, ជាភាសាខ្មែរ 00 -- គឺ (សូមទោស) 01003357។ នៅក្នុងឯកសារនេះលោកស្រីបានសរសេររៀបរាប់ដូចតទៅ លោកស្រីបានរៀបរាប់ដើម្បីពន្យល់អំពីមូលហេតុដែលលោកស្រីចាកចេញទៅទំនប់១មករា ខ្ញុំសូមដកស្រង់៖ "នេះគឺការលះបង់សម្រាប់គ្រួសាររបស់ខ្ញុំ ដែលត្រូវទៅធ្វើការនៅទីនោះ។ ខ្ញុំបាននិយាយថាប្រសិនបើសមាជិកណាមួយនៃក្រុមគ្រួសាររបស់ខ្ញុំស្ម័គ្រចិត្តទៅធ្វើការនៅក្នុងការដ្ឋាននោះដែលនៅឆ្ងាយ និងដែលលំបាកនោះ ខ្មែរក្រហមនឹងមានអ្វី -- មិនមានអ្វីស្តីបន្ទោសមកលើគ្រួសាររបស់យើងឡើយ"។ តើលោកអាចរៀបរាប់បានទេថា ពាក្យថា លោកស្រីប្រើពាក្យថា "ពលិកម្ម" នេះ លោកស្រីចង់មានន័យថាម៉េចដែរឬ? ហើយវាមានអត្ថន័យខ្លឹមសារយ៉ាងណាចំពោះលោកស្រី នៅពេលដែលលោកស្រីធ្វើការពលិកម្មបែបនេះនោះ?

[០៩:២៦:២៤]

**ឆ៖** នាងខ្ញុំមានន័យថាខ្លួនខ្ញុំនៅតូច តែខ្ញុំសុខចិត្តលះបង់ ឬក៏ធ្វើអ្វីសព្វបែបយ៉ាងដើម្បីក្រុមគ្រួសារ ឱ្យតែក្រុមគ្រួសារខ្ញុំបានសុខ។ ខ្ញុំហត់ ខ្ញុំនឿយ ខ្ញុំលំបាកប៉ុនណាក៏ដោយ ព្រោះម្តាយឪពុកខ្ញុំគាត់ចាស់ៗ។ ខ្ញុំមិនគិតពីការលំបាកហ្នឹង គឺជាពលិកម្មខ្លួនខ្ញុំ ដែលខ្ញុំស្ម័គ្រចិត្តចូលកងចល័ត។ ខ្ញុំយល់នេះជាគំនិតរបស់ខ្ញុំ ខ្ញុំយល់ថាប្រហែលជាទៅហ្នឹងអាចរួចខ្លួនក្នុងក្រុមគ្រួសារ។ ហើយខ្ញុំក៏នៅការសោកស្តាយដែរ បើសិនជាខ្ញុំមិនទៅប្រហែលជារស់។ ខ្ញុំគិតរហូតមកដល់ពេលហ្នឹង បើសិនជាខ្ញុំមិនទៅគេទាំងអស់នៅរស់ ឬក៏ខ្ញុំទៅហ្នឹងខ្ញុំខុសឬយ៉ាងម៉េច។ ខ្ញុំគិតមិនយល់ ទាល់ដល់ថ្ងៃហ្នឹង។

**ស៖** សូមអរគុណ។ តើលោកស្រីអាចជម្រាបបានទេថា លោកស្រីចាកចេញពីភូមិទៅកាន់ទំនប់១មករាហ្នឹង លោកស្រីទៅជាមួយអ្នកណាគេខ្លះ? មានអ្នកភូមិផ្សេងៗទៀតទៅជាមួយលោកស្រី

ទេ? លោកស្រីអាចរៀបរាប់បានទេ ថាតើអ្នកណាខ្លះទៅជាមួយលោកស្រីហ្នឹង ហើយការធ្វើដំណើរទៅហ្នឹងមានលក្ខណៈដូចម្ដេចដែរ?

**ធ៖** នាងខ្ញុំទៅហ្នឹងមាន ភូមិរបស់ខ្ញុំហ្នឹង ខ្ញុំនាងខ្ញុំនៅអត់ចាំច្បាស់ទេ មានច្រើន ប្រហែលជាក្រោម១០នាក់។ មានប្រជាជនពួកខ្ញុំ១៧មេសាហ្នឹង ហើយនិងមានមូលដ្ឋាន ហើយនិងភូមិផ្សេង សង្កាត់ផ្សេងក្នុងស្រុកព្រែកប្រសព្វហ្នឹងទៅច្រើនគ្នា។ ទៅហ្នឹង នាងខ្ញុំធ្វើដំណើរតាមកាណូតទៅចុះនៅស្ទឹងត្រង់ ខ្ញុំគេងតាមថ្នល់នៅស្ទឹងត្រង់ហ្នឹង១យប់។ ហើយមានឡានគេមកយក យើងដើរបណ្ដើរៗអ៊ីចឹង ពេលជិតភ្លឺ ដើរទៅឡានណាគេមកយកមុនទៅៗ មកក្រោយតគ្នា។ យកទៅដាក់នៅកំពង់ថ្ម។

[០៩:២៨:៣២]

**ស៖** តើលោកស្រីចាំទេថា ពេលដែលលោកស្រីដើរពីភូមិទៅកាន់ទំនប់១មករាហ្នឹង លោកស្រីប្រើពេលអស់ប៉ុន្មានថ្ងៃដែរ?

**ធ៖** ខ្ញុំមិន -- ខ្ញុំដឹងថាសម្រាក១យប់នៅស្ទឹងត្រង់។ តែខ្ញុំអត់ចាំថាប្រហែលជា២ថ្ងៃ១យប់ ខ្ញុំសង្ស័យ តែខ្ញុំអត់ចាំច្បាស់ ប្រហាក់ប្រហែលប៉ុណ្ណឹង។ ព្រោះគេងតែ១យប់តាមផ្លូវនៅស្ទឹងត្រង់ ហើយយប់ទី២ គេងនៅកំពង់ថ្ម។

**ស៖** សូមអរគុណ។ លោកស្រីបានបញ្ជាក់ថា លោកស្រីបានជិះទូក បន្ទាប់មកជិះឡាន។ តើលោកស្រីចាំទេថា នៅក្នុងពេលជិះទូក ហើយនិងជិះឡានហ្នឹង លោកស្រីមានគ្នាច្រើនទេ?

**ធ៖** គ្នាច្រើនដែរ ខ្ញុំកាណូតទេ មិនមែនទូកតូចទេជិះហ្នឹង កាណូតៗរាងធំដែរ ប្រហែល៣០, ៤០ក៏មិនដឹង ប៉ុន្តែដាក់ប្រហែលជា នាងខ្ញុំអត់ចាំច្បាស់ដែរ។ ហើយពេលឡានគេមកដឹកទៅហ្នឹង ក៏មិនដាក់តិចទេ ដាក់ពេញឡាន។ នាងខ្ញុំប្រហាក់ប្រហែលមិនច្បាស់ទេ គ្រាន់ថាដឹងក្នុង១ភូមិ វាគ្នាជិត១០នាក់ ប្រហែលជាជិត១០នាក់ អ៊ីចឹងក្នុងកាណូតមួយគេដាក់មួយពេញតាមសង្កាត់ផ្សេងៗក៏ចូលរួមជិះកាណូតហ្នឹងដែរ។ អស់ទៅគេដឹកបន្ត។

[០៩:៣០:៣៦]

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រីទៅដល់ទំនប់១មករានោះ ពេលណាដែលលោកស្រីចាប់ផ្ដើមធ្វើការ?

**ធ៖** ទៅដល់សម្រាកនៅពេលដែលបានយើងរៀបចំហើយ សម្រាកហើយគេចាប់ផ្ដើមនាំទៅកន្លែងធ្វើការ ក៏មិនឲ្យ -- ប្រហែលជាមិនឲ្យយើងសម្រាកច្រើនទេ ខ្ញុំអត់ចាំ។ ចាំថាពេលយើងទៅដល់

អ៊ីចឹងក្នុង១ថ្ងៃហ្នឹង ប្រហែលជាអត់ទាន់ទៅធ្វើទេ នាំគ្នាទៅឲ្យស្គាល់កន្លែងអ៊ីចឹង រៀបចំចបបង្គីអីអ៊ីចឹង ក្នុង១ថ្ងៃហ្នឹង តែគេមិនទុកឲ្យយើងសម្រាកយូរទេ គ្រាន់តែយើងរៀបចំហើយហ្នឹង។ ប៉ុន្តែនាងខ្ញុំចាំថា មិនដែលគេឲ្យពួកខ្ញុំបានសម្រាកយូរទេ។ ប្រហែលជាក្នុង១ថ្ងៃ ពេលដែលធ្វើដំណើរ។ កន្លែងហ្នឹងខ្ញុំចាំ អត់សូវច្បាស់ដែរ ប៉ុន្តែគ្រាន់តែរៀបចំចបបង្គី ទីតាំងហើយ យើងចាប់ផ្តើមធ្វើការហើយ។ ទៅដល់អ៊ីចឹង ពេលព្រឹកអ៊ីចឹងប្រហែលជាញ៉ាំបាយ ឬក៏រៀបចំហើយអត់មាននៅសម្រាកទំនេរទេ អត់ទេ។ ខ្ញុំចាំបាន តែប៉ុណ្ណឹង។

[០៩:៣២:០៦]

**សៈ** សូមអរគុណ។ លោកស្រីអាចរៀបរាប់អំពីកន្លែងដែលលោកស្រីធ្វើការបានទេ?

**ឆៈ** បាន។ នាងខ្ញុំធ្វើការនុ៎ងនៅតាមដងប្រឡាយ គេហៅប្រឡាយ១ហ្នឹង ស្ទឹងជីនិត ឈ្មោះ ស្ទឹងជីនិតសព្វថ្ងៃ គេហៅទំនប់១មករា ស្ទឹងជីនិត។ ជីកប្រឡាយពីក្រោមមកនៅជិត នៅតាម -- យើង ជិះ សព្វថ្ងៃនេះ យើងជិះពីភ្នំពេញទៅមានស្ពានស្ទឹងជីនិតមួយ តែទីតាំងហ្នឹងនៅឆ្ងាយ គេឆ្ងាយវែងទៅ ស្ទឹងហ្នឹងប្រហែលជាជិតដល់សៀមរាបអី ឆ្ងាយច្រើន វែង មិនតូចទេ ស្ទឹងជីនិតហ្នឹង។ គ្រាន់ថា ទីតាំង នុ៎ងវាឆ្ងាយពីកន្លែងស្នាក់នៅ។

**សៈ** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចហ្នឹងនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំចង់ ដឹងថា តើលោកស្រីចាំទេថា ប្រហែលជានៅឆ្នាំណា ឬក៏ខែណាដែលលោកស្រីទៅដល់ទំនប់នុ៎ង?

**ឆៈ** នាងខ្ញុំចាំថា ពេលគេចាប់បងខ្ញុំរៀបការដូចជាក្នុងខែ១២, ខែ១ ប៉ុន្តែនាងខ្ញុំចេញទៅក្នុង -- គេ មានគេទៅលើកទំនប់មុនពួកខ្ញុំហើយ១មករាហ្នឹង។ នាងខ្ញុំទៅប្រហែលជាចុងខែ១ ពីព្រោះអីនាងខ្ញុំ ត្រឡប់មកវិញ ចូលឆ្នាំខ្មែរហើយ ៣ខែ ប្រហែលជាចុងខែមករា ឬដើមខែកុម្ភៈ។ នាងខ្ញុំចាំមិនសូវច្បាស់ ដែរ តែដឹងតែ ៣ខែ។

[០៩:៣៤:១៤]

**សៈ** សូមអរគុណ។ អម្បាញ់មិញនេះ លោកស្រីថាកន្លែងដែលលោកស្រីធ្វើការហ្នឹងឆ្ងាយពី កន្លែងលោកស្រីសម្រាក។ តើលោកស្រីអាចបញ្ជាក់អំពីកន្លែងលោកស្រីសម្រាកបានទេ?

**ឆៈ** ពីដំបូងនាងខ្ញុំសម្រាកនៅភូមិប្រជាជននៅជិតវត្តបារាយណ៍ជាន់ដែក។ ហ្នឹងទៅកន្លែងធ្វើ ការប្រហែលជា១គីឡូ ឬក៏២ ល្ងាក់ជិត១គីឡូៗ អីហ្នឹង ខ្ញុំអត់ប៉ាន់ស្មានដឹងដែរ តែដើរជិតជាង។ ដល់ ក្រោយមក ឲ្យពួកនាងខ្ញុំទៅសម្រាកឆ្ងាយដើរកាត់តាមវាលស្រែនោះឆ្ងាយ ប្រហែលជា៥គីឡូ ឆ្ងាយដើរ

យូរ ក្រោកតាំងពីងងឹត ដើរមកដល់កន្លែងការដ្ឋាន។ នៅពេលធ្វើហើយកន្លែងមួយអ៊ីចឹង យើងចេះតែបន្តទៅកន្លែងផ្សេងឆ្ងាយទៅៗមុខទៀត។

**សៈ** នៅពេលដែលលោកស្រីនិយាយថា ធ្វើហើយទៅមួយកន្លែងហ្នឹង លោកស្រីអាចរៀបរាប់លម្អិតឲ្យបានទេ ថាតើធ្វើយ៉ាងម៉េច? ធ្វើហើយមួយកន្លែងទៅមួយកន្លែង ឬក៏ធ្វើមួយកន្លែងចប់ ឬក៏យ៉ាងម៉េច? លោកស្រីអាចពន្យល់រៀបរាប់បានទេ អំពីថា ធ្វើមួយកន្លែងទៅមុខមួយកន្លែងទៀតហ្នឹង?

**ធៈ** ឧទាហរណ៍ គេវាស់ម៉ែត្រឲ្យពួកខាងសង្កាត់ខ្ញុំ ស្រុកខ្ញុំព្រែកប្រសព្វហ្នឹងធ្វើរយៈពេលថាកន្លះខែ ឬក៏១ខែអ៊ីចឹង នៅចំទីតាំងហ្នឹងប៉ុន្មានម៉ែត្រ។ ដល់ពេលពួកខ្ញុំលើកទំនប់នៅទីហ្នឹងហើយ ហើយគេចាប់ផ្ដើមបន្តប្រឡាយទៅមុខទៀត។ ឧទាហរណ៍ថា ហើយទីតាំងកន្លែងហ្នឹង ប្រឡាយវាវែង យើងត្រូវទៅមុខទៀត ដើម្បីចេះតែឆ្ការព្រៃទៅមុខទៀត។ ព្រោះធ្វើបន្តរហូត ប្រហែលជាភ្ជាប់ទៅដល់ជិតខេត្តសៀមរាប មានស្ទឹងគេក៏មិនដឹង ខ្ញុំអត់យល់កន្លែងហ្នឹងដែរ។ ប៉ុន្តែហើយពីហ្នឹងទៅ ឆ្ងាយជាងហ្នឹងទៀតទៅ ប្រហែលជាប៉ុន្មានរយម៉ែត្រអីអ៊ីចឹងទៅ ជិត១គីឡូទៅ យើងធ្វើកន្លែងថ្មី។ ដល់ហើយកន្លែងថ្មីហ្នឹង តទៅទៀត។ គ្រប់គ្នាអ៊ីចឹង មិនមែនតែពួកភូមិស្រុកខ្ញុំទេ។

[០៩:៣៦:៤៧]

**សៈ** សូមអរគុណ។ លោកស្រីនិយាយអំពីការកាប់ឆ្ការផងដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា ក្នុងរយៈពេល៣ខែហ្នឹង លោកស្រីធ្វើការងារអ្វីខ្លះ?

**ធៈ** នៅពេល៣ខែ នាងខ្ញុំរែកដី មានពួកប្រុសៗ គេកម្លាំងខ្លាំង គេកាប់។ នាងខ្ញុំអ្នករែក។ រែកពីប្រឡាយយកទៅចាក់ទំនប់។ ធ្វើការងារតែប៉ុណ្ណឹងដដែលៗរាល់ថ្ងៃ។ ជួនកាល ពេលញ៉ាំទឹកអី នាងខ្ញុំទៅដងទឹកឲ្យគេធំៗ គេថា ខ្ញុំតូចណាស់ យកកម្លាំងខ្ញុំមួយទៅយកទឹកឲ្យបងៗគេនាំគ្នាហូបនៅកន្លែងការដ្ឋានទៅ នាងខ្ញុំទៅដងទឹកមក ឲ្យគេញ៉ាំ។ ទោះមានកន្លែងគេដាំទឹក មានរោងបាយកន្លែងរួម គេដាក់ដាំទឹកឲ្យយើង ទៅដួសនៅឆ្ងាយពីកន្លែងរែកដីដែរ។ គេអត់ឲ្យយើងម្នាក់ៗស្រេកទឹកហើយ ដើរទៅញ៉ាំរៀងខ្លួនទេ អត់ទេ គឺខ្ញុំអ្នកទៅដងទឹកដាក់បំពង់រែកយកមកឲ្យគេ មានបឺដុង មានបំពង់អ៊ីចឹង នាងខ្ញុំតែងតែទៅដងរាល់ថ្ងៃ។

**សៈ** សូមអរគុណ។ ខ្ញុំចង់ឲ្យលោកស្រីពន្យល់ថា តើកងរបស់លោកស្រីហ្នឹងដំណើរការយ៉ាងដូចម្ដេច? ក្នុងកងនោះមានមនុស្សប៉ុន្មាននាក់? ហើយលោកស្រីជាមនុស្សក្មេងជាងគេ ឬក៏យ៉ាងម៉េច? សូមលោកស្រីរៀបរាប់អំពីកងដែលលោកស្រីធ្វើការហ្នឹងបន្តិចទៅមើល។

[០៩:៣៨:៤៨]

**ធ៖** កងនាងខ្ញុំ ខ្ញុំនាងខ្ញុំស្មានមិនត្រូវកម្លាំងមនុស្សទេ ប្រហែលជានៅរួមហ្នឹង ប្រហែលជាចូលរយនាក់ហើយ កន្លែងស្រុកក្នុងកងខ្ញុំហ្នឹងមាន គេហៅមួយស្រុកព្រែកប្រសព្វហ្នឹង ក្នុងមួយភូមិជិត១០នាក់ យើងរាប់ទៅ ក្នុងការងារហ្នឹងវាមានច្រើនសង្កាត់។ អ៊ីចឹងនាងខ្ញុំមិនអាចប៉ាន់ស្មាន ប្រហែលជាខ្ទង់រយនាក់ គ្រាន់តែនាងខ្ញុំគិត។ សូមទោសអ្នកស្រី សំណួរក្រោយអំមិញ នាងខ្ញុំអត់ចាំ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយពេលក្រោយ។ អ៊ីចឹង តើនៅក្នុងកងរបស់លោកស្រីហ្នឹង គេចែកចេញជាក្រុម ឬក្រុមតូចៗអីយ៉ាងម៉េចទៀតទេ? ហើយធ្វើការហ្នឹងទាំងអស់រួមគ្នាតែម្ដង ឬយ៉ាងម៉េច?

**ធ៖** នៅក្នុងកង -- នៅក្នុងមួយស្រុកព្រែកប្រសព្វហ្នឹង គេចែកចេញជាកង កងហើយចែកចេញជាក្រុម ក្រុមហើយមានជាពួកតូចៗ តែអ្នកក្ដោបក្ដាប់ហ្នឹង គឺប្រជាជនមូលដ្ឋាន។ ប្រធានកង ប្រធានក្រុម ប្រធានអីគឺមូលដ្ឋានអ្នកក្ដោបក្ដាប់។

[០៩:៤០:២៩]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ ខ្ញុំសួរហ្នឹងគឺសួរថា តើលោកស្រីក្មេងជាងគេ ឬក៏យ៉ាងម៉េចនៅក្នុងកងរបស់លោកស្រីហ្នឹង? ហើយលោកស្រីចាំទេថា នៅក្នុងក្រុមរបស់លោកស្រីហ្នឹង គឺមានអាយុប្រហាក់ប្រហែលប៉ុន្មានដែរ អ្នកដែលធ្វើការហ្នឹង? ហើយចុះអ្នកនៅក្នុងកងវិញហ្នឹងក៏អាយុប្រហាក់ប្រហែលប៉ុន្មានដែរ?

**ធ៖** នាងខ្ញុំនៅចាំ ប្រហែលអត់មានចំណាស់ទេ ច្រើនបំផុតក្រោម៣០ អត់ដល់៣០ទេ ម្ភៃជាង, ជាង១០, ១៤, ១៥, ១៦, ១៧ច្រើន ម្ភៃចុះក្រោមរាងច្រើន ម្ភៃក្រាស់តិច ចាស់ពេកអត់មានទេ នៅវ័យ -- អត់សូវឃើញមានចាស់មក។ ភាគច្រើនជាង១០ឆ្នាំ ហើយនាងខ្ញុំក្មេងជាងគេ តូចជាងគេមានគេបងនាងខ្ញុំ១ឆ្នាំ, ៣ឆ្នាំ តែគេៗធំជាងខ្ញុំ នាងខ្ញុំតូច។

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រីថា លោកស្រីក្មេងជាងគេហ្នឹង គឺលោកស្រីចង់មានន័យថា នៅក្នុងក្រុម ឬក៏ក្នុងកងរបស់លោកស្រីហ្នឹង មានអាយុប្រហែលៗនឹងលោកស្រីដែរ ឬក៏នៅក្នុងក្រុមលោកស្រីហ្នឹង គឺថាមានតែលោកស្រីដែលអាយុតិចជាងគេបំផុត ដែលថា១២ឆ្នាំហ្នឹង?

[០៩:៤២:០៤]

**ធ៖** នៅក្នុងកងពួកខ្ញុំ មាននាងខ្ញុំតូចជាងគេ។ គេចូលចិត្តនិយាយថា នាងខ្ញុំមិនទាន់ នេះឈប់អីនៅជាមួយម្ដាយមិនទាន់នេះផង អ្នកណាចេះឲ្យមកធ្វើការដែរ តូចជាងគេ។ គេលេងសើចជាមួយខ្ញុំ ថា

"អ្នែងអត់ទាន់ឈប់បៅទឹកដោះទេអី អ្នែងមកហ្នឹង!" រាល់ពេល។ ខ្ញុំអត់ឃើញអ្នកណាតូចដូចប៉ិនខ្ញុំ ដូច អត់មាន មាននាងខ្ញុំតូចជាងគេ។

**ស៖** សូមអរគុណ។ មុននេះ បន្តិចលោកស្រីនិយាយអំពីការងារដែលលោកស្រីត្រូវធ្វើនៅទំនប់ ១មករា។ អ៊ីចឹងខ្ញុំចង់ដឹងថា ការងារដែលលោកស្រីធ្វើហ្នឹង គឺធ្វើដូចមនុស្សធំៗដែរ ឬក៏គេគិតឃើញថា លោកស្រីមានអាយុតូចអ៊ីចឹង គេឲ្យលោកស្រីធ្វើការស្រាលជាងគេ?

**ឆ៖** គេយល់ថា នាងខ្ញុំតូច រែកដីដូចគេដែរ តែនាងខ្ញុំបង្គីតូចជាងគេៗ គេដាក់ឲ្យតិចជាងៗ មនុស្សធំ ហើយគេច្រើនប្រើឲ្យទៅដងទឹក។ គេអត់ដាក់ដីច្រើនពេញៗ ដូចពួកធំៗដាក់សុទ្ធឡើងពេញ ហៀរៗ នាងខ្ញុំដាក់តិចជាង។

**ស៖** សូមអរគុណលោកស្រី។ តើគេមានកំណត់ឲ្យលោកស្រីរែក ឬក៏ជីកប៉ុន្មានគូបអីអ៊ីចឹងទេ? ហើយបើសិនជាមានមែននោះ តើលោកស្រីធ្វើយ៉ាងម៉េច អាចសម្រេចតាមផែនការហ្នឹងបាន?

**ឆ៖** គេអត់កំណត់នាងខ្ញុំម្នាក់ឯងទេ គេកំណត់តាមក្រុម។ ក្រុមហ្នឹងមានបងៗធំៗដែរ កំណត់ ចូលគ្នាទៅកាប់ប៉ុន្មានម៉ែត្រអ៊ីចឹង រែកជាមួយគេហ្នឹងទៅ។ ជួយទាំងអស់គ្នា។

[០៩:៤៥:២៥]

**ស៖** លោកស្រីចាំទេពេលហ្នឹង សម្រាប់ក្រុមលោកស្រី គេកំណត់ឲ្យជីក និងរែកហ្នឹងប៉ុន្មាន ម៉ែត្រគូបដែរ?

**ឆ៖** នាងខ្ញុំអត់ចាំទេ នាងខ្ញុំចាំថាគេវាស់ម៉ែត្រ។ ក្នុងមួយស្រុកអ៊ីចឹង ចែកជាសង្កាត់ចែកជា អ៊ីចឹង ប៉ុន្មានម៉ែត្រអ៊ីចឹងទៅ ដាក់ផែនការថា កំណត់ប៉ុន្មានអាទិត្យ ឬក៏ប៉ុន្មានថ្ងៃឲ្យហើយអ៊ីចឹង ដឹង អ៊ីចឹង។ ហើយពេលហ្នឹងក៏គេចែកជាក្រុមតូចៗទៀត នាងខ្ញុំដឹងបានតែប៉ុណ្ណឹង។

**ស៖** លោកស្រីពេលនុ៎ងមានគិតថា ដូចជាមានសម្ពាធទេនៅក្នុងការបំពេញការងារឲ្យសម្រេច តាមផែនតាមការហ្នឹង ឬក៏លោកស្រី ដោយសារតែអាយុនៅតូចអ៊ីចឹង គឺអត់មានសម្ពាធអីទេ ធ្វើតាម ធម្មតាទេ?

**ឆ៖** នាងខ្ញុំគិតថាមានសម្ពាធ គិតថាគេបង្ខំ ប៉ុន្តែបើ -- អ៊ីតែនាងខ្ញុំអត់បានគិតអីវែងឆ្ងាយ នាង ខ្ញុំដឹងតែធ្វើ ធ្វើទៅហត់ ដឹងហត់ដឹងស្អីអ៊ីចឹង ប៉ុន្តែបងៗធំ គាត់ប្រជាជន១៧មេសា គាត់ -- គេមិនឲ្យ យើងនិយាយគ្នាទេ ក៏ប៉ុន្តែគាត់ ពេលសម្រាកជួនកាលគាត់រអ៊ូ គាត់ថាមិនដែលជួបប្រទះរបបអីប្រើ មនុស្សជាងគោ ជាងក្របីទៀត។ អ្នកខ្លះថា បើចង់កើតជាសត្វប្រហែលជាល្អជាង មានសិទ្ធិ តែយើង

អត់មានសិទ្ធិប្រើរហូត ធំៗគេស្តីឲ្យរាល់ថ្ងៃ។ តែនាងខ្ញុំមានចិត្ត នាងខ្ញុំធ្វើការឧស្សាហ៍ នាងខ្ញុំមិនដែលឲ្យគេស្តីបន្ទោសទេ។ នាងខ្ញុំនៅទំនប់១មករាហ្នឹង នាងខ្ញុំធ្វើរហូតដល់នាងខ្ញុំដួលសន្លប់ម្តង គេសែង។

[០៩:៤៦:៣៥]

**ស៖** សូមអរគុណ។ តើលោកស្រីអាចនិយាយអំពីពេលម៉ោងធ្វើការទេ លោកស្រីចាប់ផ្តើមធ្វើការពីម៉ោងប៉ុន្មាន? ហើយរហូតទៅដល់ម៉ោងប៉ុន្មានបានគេឲ្យសម្រាក ហើយម៉ោងចាប់ផ្តើម -- ម៉ោងប៉ុន្មានទៀតធ្វើការរហូតទៅដល់យប់ហ្នឹង?

**ឆ៖** ពេលព្រឹក ពួកនាងខ្ញុំនៅឆ្ងាយកន្លែងគេង អ៊ីចឹងពួកខ្ញុំក្រោកពីយប់ រាងងងឹតៗ មកដល់កន្លែងភ្លឺ។ គឺអត់ដូចជាអត់មានម៉ោង ដឹងកំណត់ពេល តែដឹងថ្ងៃរះ ព្រាងៗគឺពួកនាងខ្ញុំមកដល់ការដ្ឋានហើយ។ ហើយព្រឹកឡើង ពួកខ្ញុំអត់មានអីញ៉ាំទេ។ ដល់តែពេលថ្ងៃត្រង់ ប្រហែលជាថ្ងៃចំលើក្បាល គេឲ្យសម្រាកបាយ។ សម្រាកតែមួយភ្លែត អត់មានគេងអីទេ គឺអង្គុយលើបង្គីហ្នឹង តែមួយភ្លែតគេវាយជួងទៀតហើយ គេវាយជួង គេប្រើជួង។ ប្រហែលជាសន្មតថាកន្លះម៉ោង ឬក៏ខ្ញុំដឹងតែមួយភ្លែត ញ៉ាំបាយហើយអង្គុយតែមួយភ្លែត ម៉ឹង ចូលធ្វើការរហូតដល់ល្ងាច។ ល្ងាចពួកខ្ញុំនៅញ៉ាំបាយ នៅរោងជិតកន្លែងធ្វើការ។ ដល់យប់ម៉ោងប្រាំបួន ម៉ោងដប់ បានពួកខ្ញុំទៅដល់កន្លែងគេង។ ហើយកន្លែងខ្ញុំគេង អត់មានទឹកទេ នាងខ្ញុំងូតទឹកតាមភូមិ មានអណ្តូងតាមភូមិ ហើយបានដើរទៅទាំងអស់គ្នា។ ដូចគ្នាទាំងអស់ គឺនាំគ្នាងូតទឹកតាមផ្លូវ។

[០៩:៤៨:២៤]

**ស៖** សូមអរគុណ។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីពេលម៉ោងដដែលហ្នឹង លោកស្រីនិយាយថា៖ “កន្លែងគេងហ្នឹង គឺមានចម្ងាយប្រហែលជា៥គីឡូម៉ែត្រពីទំនប់”។ តើលោកស្រីអាចរៀបរាប់ឲ្យបានច្បាស់បន្តិចទេថា លោកស្រីងើបពីគេងម៉ោងប៉ុន្មាននៅពេលព្រឹក? លោកស្រីថាងើបពីព្រលឹមណាស់ អ៊ីចឹងខ្ញុំចង់ដឹងថា ងើបពីម៉ោងប៉ុន្មានពេលព្រឹកហ្នឹង ហើយដើរពីកន្លែងគេងហ្នឹងទៅការដ្ឋានហ្នឹងប្រើពេលអស់ប៉ុន្មានដែរ? លោកស្រីនៅចាំទេ?

**ឆ៖** នាងខ្ញុំចាំថា ក្រោកប្រហែលជាបួនកន្លះ ឬក៏ប្រាំ នៅងងឹតៗ នាងខ្ញុំស្មានទេ តែអត់មានម៉ោងមើលទេ។ ប៉ុន្តែដើរ ដើរយូរ ដើរចង់ជិត១ម៉ោង យូរ យើងស្មានពេលអត់ដឹងថាដើរប៉ុន្មាន តែដើរយូរ ដើរឆ្ងាយណាស់ ដើរកាត់តាមវាលស្រែ។ បើសិនជាអ្នកនៅទីនោះស្គាល់ពីថ្នល់ជាតិ កំពង់ថ្មហ្នឹងចូលទៅដល់ក្នុង ដូចជាហៅថា ភូមិត្នោត កន្លែងចេនឡាទី២។ កន្លែងនោះគេហៅ តំបន់ចេនឡាទី២។

ហ្នឹងគេអាចដឹងគីឡូម៉ែត្រ ឯនាងខ្ញុំស្មានអត់ត្រូវ នាងខ្ញុំដឹងថាឆ្ងាយៗដើរ ដើរហត់ ដើរឆ្ងាយខ្លាំង។

[០៩:៥០:០៨]

**ស៖** ពីទំនប់ហើយនិងកន្លែងដែលត្រូវសម្រាកញ៉ាំអាហារថ្ងៃត្រង់ហ្នឹងមានចម្ងាយឆ្ងាយទេ?

**ឆ៖** ចាស ពីទំនប់មកកន្លែងអាហារមិនសូវឆ្ងាយទេ ជិតៗគ្នាទេ។ ទំនប់ហើយឆ្ងាយបន្តិចទេ អត់ឆ្ងាយប៉ុន្មានទេ កន្លែងញ៉ាំអាហារ។ នាងខ្ញុំស្មានអត់បាន ប្រហែលជាប៉ុន្មានរយម៉ែត្រអីប៉ុណ្ណឹង ១០០ ម៉ែត្រ ឬក៏ជិត ១០០ម៉ែត្រ អត់ដល់ទេ ជិតមានរោងគេធ្វើនៅទីនោះ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកស្រីឆ្លើយថា លោកស្រីសម្រាកពីការងារប្រហែលជាម៉ោងប្រាំបួន ម៉ោងដប់យប់។ អ៊ីចឹងខ្ញុំចង់ដឹងថា ម៉ោងប្រាំបួនដប់យប់នោះ ជាម៉ោងលោកស្រីឈប់ធ្វើការតែម្តង ឬក៏ម៉ោងដែលលោកស្រីដើរទៅដល់កន្លែងគេង។

**ឆ៖** ម៉ោងប្រាំបួនម៉ោងដប់ហ្នឹងជួនកាលឈប់ធ្វើការ ហើយទម្រាំដើរទៅដល់កន្លែងគេង នាងខ្ញុំពិបាកស្មានម៉ោងអត់ត្រូវ គ្រាន់តែដឹងថា នៅពេលយប់នាងខ្ញុំសម្រាកបាន -- ពេលល្ងាចសម្រាកបានបន្តិចហើយចាប់ធ្វើការ។ ធ្វើការជួនម៉ោងប្រាំបួន ជួនម៉ោងដប់ អ្នកគេនុំងនិយាយថា ម៉ោងយប់ជ្រៅហើយអត់មានម៉ោងមើលអីអ៊ីចឹងណ៎ា ប៉ុន្តែនាងខ្ញុំអត់ប៉ាន់ស្មានដឹងទេ។ ប្រហែលជាមកដល់កន្លែងធ្វើ -- មកដល់កន្លែងគេងខ្ទង់ប្រហែលជាម៉ោងដប់ ឬម៉ោងជិតដប់មួយរាល់ថ្ងៃ។ ភូមិគេផ្សេង ខ្ញុំអត់ដឹង តែដឹងកន្លែងពួកខ្ញុំ គឺធ្វើរាល់ថ្ងៃ។ ជួនកាលមានចន្លុះ ពេលខែភ្លឺ គឺខែភ្លឺ។ ចន្លុះនោះ គឺដុតបំភ្លឺ។

[០៩:៥២:២៦]

**ស៖** សូមអរគុណ។ លោកស្រីថា នៅពេលរដូវប្រាំង លោកស្រីធ្វើការពេលយប់នោះ។ អ៊ីចឹងមានន័យថា ពេលដែលរដូវប្រាំងហ្នឹងលោកស្រីធ្វើការច្រើនជាងធម្មតាមែនទេ? ហើយធ្វើការរហូតទៅដល់ពេលណាដែរ?

**ឆ៖** នៅក្នុងរបបនោះ ពេលរដូវប្រាំង រដូវវស្សាធ្វើការដូចគ្នាទាំងអស់។ វាបង្ខំឲ្យធ្វើការមិនដែលមានពេលទំនេរ ដូចគ្នា។ គ្រាន់តែនាងខ្ញុំមកខាងទំនប់អ៊ីចឹងទៅអត់ចុះទឹកចុះអីប៉ូកប៉ាកជាមួយស្ទូងដក ហើយកន្លែងទំនប់ហ្នឹង រដូវណាក៏ដូចរដូវណា ភ្លៀងគឺធ្វើទាំងភ្លៀង អត់មានភ្លៀងនាំគ្នាចូលសម្រាកទេ គឺអត់ទេ។

**ស៖** នៅពេលដែលលោកស្រីនិយាយអំពីការងារពេលយប់នោះ ចង់ -- សម្រាប់លោកស្រី គឺមានន័យថា យ៉ាងម៉េចដែរ គឺលោកស្រីសំដៅពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ដែលលោកស្រីសំដៅថា

ការងារពេលយប់នុ៎ង?

**ឆ៖** ការងារពេលយប់នោះ សំដៅពេលម៉ោងយប់ល្ងាចម៉ោងប្រាំមួយប្រាំពីរយប់ហ្នឹង។ ប្រហែលជាម៉ោងប្រាំមួយកន្លះ ប្រាំពីរហ្នឹងចូលធ្វើរហូតដល់ម៉ោងយប់ ម៉ោងប្រាំបួន ឬក៏ម៉ោងដប់។

[០៩:៥៤:១០]

**សៈ** ដើម្បីឲ្យច្បាស់ទាំងអស់គ្នា។ អ៊ីចឹងពេលម៉ោងដែលធ្វើដល់យប់ហ្នឹង ធ្វើតែពេលរដូវប្រាំងទេ ឬក៏ធ្វើទាំងរដូវប្រាំង ទាំងរដូវវស្សា?

**ឆ៖** សួរថា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំគិតថា ខ្ញុំមានការជំទាស់មួយដោយសារយើងបានស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គាត់ធ្វើការតែ៣ខែទេ។ ហើយគាត់ឈប់ធ្វើការនៅប្រហែលអំឡុងពេលចូលឆ្នាំខ្មែរ គឺនៅក្នុងពាក់កណ្ដាលខែមេសា។ ដូច្នេះវាហាក់ដូចជាមិនមានភស្តុតាងថា ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការនៅក្នុងរដូវវស្សានោះឡើយ។ ដូច្នេះគួរតែមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ឲ្យច្បាស់អំពីសក្ខីកម្មទាំងអស់នេះ។ ដូច្នេះតាមដែលខ្ញុំយល់ គឺថារដូវវស្សាចាប់ផ្ដើមនៅខែឧសភារហូតដល់ទៅដល់ខែតុលា។ ដូច្នេះដោយសារគាត់ទៅធ្វើការ៣ខែ ពីខែមករារហូតទៅដល់ពេលចូលឆ្នាំ ឬមួយក៏អាចថាគាត់ធ្វើពីចូលឆ្នាំរហូតដល់ខែវស្សា។ ដូច្នេះគួរតែបញ្ជាក់ច្បាស់អំពីចំណុចទាំងអស់នេះ ទាក់ទងនឹងការងាររបស់គាត់។

[០៩:៥៥:៣២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំគ្រាន់តែចង់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរៀបរាប់ឡើងវិញអំពីអ្វីដែលគាត់បានឆ្លងកាត់។ អ៊ីចឹងឲ្យគាត់បញ្ជាក់ទៅថាតើគាត់ធ្វើការនៅរដូវប្រាំង ឬក៏យ៉ាងម៉េច? អ៊ីចឹងហើយបានជាខ្ញុំសួរ ដើម្បីឲ្យគាត់ឆ្លើយបញ្ជាក់ឡើងវិញ ពីព្រោះគាត់ៗបានឆ្លើយថា គាត់ធ្វើការពេលយប់នៅរដូវប្រាំង។ អ៊ីចឹងហើយបានជាខ្ញុំសួរគាត់ទៅ ឲ្យគាត់បញ្ជាក់។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** អ៊ីចឹងខ្ញុំសួរម្ដងទៀតថា លោកស្រី តើលោកស្រីធ្វើការនៅពេលយប់ហ្នឹង ធ្វើការនៅរដូវប្រាំងមែនទេ?

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ចាស ខ្ញុំធ្វើការនៅរដូវប្រាំង។ ខ្ញុំបាន – សូមទោស ខ្ញុំបានបញ្ជាក់ថាខ្ញុំទៅទំនប់១មករាហ្នឹងប្រហែលជាចុងខែ១ ឬដើមខែ២។ ដូច្នេះខ្ញុំពេលចូលឆ្នាំហ្នឹង មិនមែនខ្ញុំត្រឡប់មកពាក់កណ្ដាលចូលឆ្នាំទេ គឺរាប់ពីពេលដែលខ្ញុំទៅហ្នឹង បើសិនយើងរាប់ខែ២, ខែ៣ ក៏អាចខ្ញុំត្រឡប់មកខ្ទង់ខែ៥ ខែអីដែរ។ ខ្ញុំគ្រាន់ថាក្នុងរយៈអំឡុងពេល៣ខែតែប៉ុណ្ណោះ។ ក្នុងទំនប់១មករា គឺខែប្រាំង។ ខ្ញុំចង់និយាយទូទៅថានៅរបបនោះ ពេលភ្លៀង ពេលថ្ងៃក្ដៅស្ទើរខែវស្សាពេលណាក៏ត្រូវធ្វើការដែរ មិនសម្រាកទេ។

[០៩:៥៦:៥៩]

**ស៖** ឥឡូវយើងនិយាយអំពីសារធាតុនៃសំណួរ។ តើលោកស្រីចាំទេថា នៅពេលដែលលោកស្រីធ្វើការនុំងមានភ្លៀងធ្លាក់ទេ? គឺប្រហែលជាខ្ញុំគិតទៅ អាចចុងពេលដែលលោកស្រីធ្វើការចុងក្រោយហ្នឹងប្រហែលជាអាចមាន អាចចូលទៅដល់រដូវវស្សាហើយ។ តើលោកស្រីអាចបញ្ជាក់ឡើងវិញម្ដងទៀតបានទេ?

**ឆ៖** នាងខ្ញុំមិនសូវចាំដែរ ប៉ុន្តែមានអាចជួបភ្លៀង អាចជួប ប៉ុន្តែមានភ្លៀងក៏ត្រូវតែទៅធ្វើការ តែនាងខ្ញុំចាំអត់ច្បាស់កន្លែងនោះ។

**ស៖** សូមអរគុណ។ ក្នុងរយៈពេលដែលលោកស្រីធ្វើការ៣ខែហ្នឹង គេមានឲ្យថាប៉ុន្មានថ្ងៃឈប់សម្រាកម្ដងអីទេ?

**ឆ៖** នាងខ្ញុំអត់ដែលបានឈប់ទេ ប្រហែលជាចូលឆ្នាំអាចគេឈប់១ថ្ងៃ ឬក៏នាងខ្ញុំចាំអត់សូវច្បាស់ដែរ តែនៅថ្ងៃចូលឆ្នាំប្រហែលជាគេមានប្រជុំគេអ៊ីចឹង នាងខ្ញុំអាចឈប់។ គេកំណត់ថាឲ្យឈប់១ថ្ងៃ២ថ្ងៃ ឬក៏ក្នុង១ខែឈប់ម្ដងអី កន្លែងភូមិខ្ញុំនៅអត់ដែលបានឈប់ទេ ភូមិផ្សេងខ្ញុំអត់ដឹងដែរ តែកន្លែងខ្ញុំអត់ ធ្វើរហូត។

[០៩:៥៨:៤០]

**ស៖** សូមអរគុណ។ មុននេះបន្តិច លោកនិយាយថាមាន -- លោកស្រីសន្លប់នៅលើការដ្ឋានហ្នឹង។ អ៊ីចឹងខ្ញុំចង់ដឹងថាហេតុដូចម្ដេចបានជាលោកស្រីសន្លប់ តើលោកស្រីអស់កម្លាំងខ្លាំងពេកមែនទេ?

**ធ៖** ចាស ពិតមែនហើយ ខ្ញុំអស់កម្លាំង ហើយខ្ញុំគេងអត់ឆ្អែត ញ៉ាំអត់ឆ្អែត ហើយសុខភាពនាងខ្ញុំមិនសូវល្អដែរ ពេលនោះ នាងខ្ញុំក៏ដួលសន្លប់ទៅ។ ពេលនោះ គឺគេសែងនាងខ្ញុំទៅរោងសម្រាក។

**ស៖** សូមអរគុណ។ តើរបបអាហារនៅក្នុងរយៈពេល៣ខែហ្នឹង ដូចៗគ្នារហូត ឬក៏មានការប្រែប្រួល មានកើនឡើងអីដែរ? អ៊ីចឹងលោកស្រីអាចរៀបរាប់ទេថាលោកស្រីហូបអ្វីខ្លះនៅពេលនោះ?

**ធ៖** នៅពេល៣ខែនាងខ្ញុំ ស្រុកភូមិនាងខ្ញុំខាងក្រចេះនេះរាងហូបរាងគ្រាន់បើជាងភូមិខ្លះ។ នាងខ្ញុំទំនេរនាងខ្ញុំទៅដងទឹក នាងខ្ញុំលួចស្ទូរដើរទៅក្មេងៗ -- ជួបអ្នកធ្វើការហ្នឹង នាងខ្ញុំបាយ មានបាយ មានបបរ ហើយសម្លល្ពៅ ហើយនិងត្រឡាច និងគេចែកអំបិលតិចៗទៅ។ ប៉ុន្តែរាល់ពេលគឺល្ពៅ ត្រឡាចជានិច្ច គឺបន្លែនោះដឹកពីភូមិមក។ មានអ្នកសេដ្ឋកិច្ចគេដឹកពីភូមិយើងនៅ សង្កាត់យើងនៅយកមកឲ្យកន្លែង -- មកដល់កន្លែងការដ្ឋាន។ បាយគេគឺមិនមែនហូបតាមចិត្តទេ គឺគេចែករបបយើង គេចែកតាមវែក។ ហើយនៅក្នុងប្រហែលជា១០ថ្ងៃ ឬក៏នាងខ្ញុំមិនចាំដែរ មានបបរស្ករៗអង្ករដំណើបជាមួយស្ករ ជូនទៅទ្រាប មានបង្អែមខ្លះ។ ហើយនាងខ្ញុំបានចាំមួយទៀតនៅពេលថ្ងៃចូលឆ្នាំខ្មែរ គេមានទឹកកកៗហ្នឹង ដូចជា ពីរដើម គេដាក់ក្នុងធុងសាំងឲ្យពួកខ្ញុំញ៉ាំ ហើយដាក់ទៅរលាយអស់ហើយមានត្រជាក់អីផង ដូចជាម្តងនាងខ្ញុំទឹកឃើញ នៅចាំកន្លែងហ្នឹង។

[១០:០១:៥៤]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកស្រីថា លោកស្រីធ្លាក់ខ្លួនឈឺ។ តើលោកស្រីអាចបញ្ជាក់បានទេថា លោកស្រីឈឺទេ -- ឈឺញឹកញាប់ទេ ហើយកាលដែលលោកស្រីដួលសន្លប់នៅការដ្ឋានហ្នឹងតែម្តងហ្នឹងទេ ឬក៏មានច្រើនដង?

**ធ៖** នាងខ្ញុំដួលតែម្តងទេ។ នាងខ្ញុំអត់សូវឈឺប៉ុន្មានទេ តែចុងក្រោយនាងខ្ញុំឈឺបន្តិចបន្តួចក្តៅខ្លួនបន្តិចបន្តួច ឬក៏អស់កម្លាំង ឬក៏វិលមុខអីបន្តិចបន្តួច សម្ងំហើយនាងខ្ញុំទៅធ្វើការហើយ។ ពីព្រោះនាងខ្ញុំមិនសូវចេះនៅ ឲ្យតែនាងខ្ញុំធ្វើរួច ដើររួច នាងខ្ញុំទៅរហូត ឲ្យនាងខ្ញុំឈឺធ្ងន់អត់ដែលធ្ងន់ខ្លាំង ថ្ងៃនុំងប្រហែលជាសម្រាក១ថ្ងៃ, ២ថ្ងៃ នាងខ្ញុំត្រឡប់ទៅធ្វើការវិញ។ ពេលនាងខ្ញុំឈឺមានពេទ្យៗ គេនោះពេទ្យអស់ចេះទេ ពេទ្យគេមានតែឲ្យថ្នាំដូចអាចម៍ទន្សាយអ៊ីចឹង ញ៉ាំមិនត្រូវ។ ពេលខ្ញុំឈឺហ្នឹង មានពូម្នាក់ធ្វើការជាមួយខ្ញុំនុំង ខ្ញុំចាំ គាត់ឈ្មោះ ពូគង់ គាត់ឲ្យថ្នាំពីភ្នំពេញទៅឲ្យខ្ញុំញ៉ាំមួយគ្រាប់។ គាត់ថា “អ្អែងទាល់តែញ៉ាំថ្នាំហ្នឹងហើយ អ្អែងក្តៅ អ្អែងនេះអ៊ីចឹង។” ពេលនោះ ខ្ញុំក៏បានធូរស្បើយ ហើយថ្នាំពេទ្យឲ្យរបស់ខាងខ្មែរក្រហមឲ្យខ្ញុំអត់ញ៉ាំៗអត់ត្រូវ ព្រោះមូលៗខ្មៅៗ។ ហើយគេអត់មានពិនិត្យមើលអី យើង

ឈឺអីម៉េចៗ មានមើលឈាម មើលអីអត់ទេ គេដឹងតែចែកៗ ហើយអ្នកពេទ្យនោះក៏អត់មានអ្នកចេះដឹងយ៉ាងម៉េចមើលថាម៉េចៗ ខ្ញុំអត់យល់ដែរ។

[១០:០៣:៥៩]

**ស៖** សូមអរគុណ។ នៅក្នុងរយៈពេលដែលលោកស្រីធ្វើការ ៣ខែនៅទំនប់ហ្នឹង តើមានអ្នកផ្សេងទៀតដែលនៅក្នុងកងរបស់លោកស្រីហ្នឹងឈឺដែរ -- ឈឺទេ?

**ឆ៖** ចាស មាន។ មានឈឺ ជួនកាលគេកោសខ្យល់អីអ៊ីចឹងទៅ ប៉ុន្តែគេអត់ឲ្យយើងមករោងទេ យើងកោសនៅកៀនៗកន្លែងធ្វើការហ្នឹងទៅ។ កោសហើយស្រួល ធ្វើការវិញទៅ។ បើអ្នកខ្លាំងក៏គេឲ្យមកសម្រាកទៅ តែភាគច្រើនកោសហើយគឺធ្វើការវិញ។ ហើយបើមានអ្នកឈឺខ្លាំង គេឲ្យនៅសម្រាកនៅជិតរោង ពេទ្យនោះនៅជិតរោងកន្លែងគេង។ ហើយបើខ្លាំងមើលមិនជា គេច្រើនតែបញ្ជូនមកតាមភូមិ តាមស្រុក ផ្ទះវិញហ្នឹង គេមានពេទ្យគេ គឺពេទ្យគេនៅវត្ត វត្តហ្នឹងមានដាំថ្នាំ មានអីខ្លះ។ ពេលថ្ងៃក្រោយមកទៀតមក នាងខ្ញុំធ្លាប់គេងនៅពេទ្យវត្តដែរ ពេលក្រោយមកពីទំនប់វិញ នាងខ្ញុំធ្លាប់។

**ស៖** តើលោកស្រីអាចរៀបរាប់កន្លែងពេទ្យនៅក្នុងវត្តហ្នឹងបានទេ?

**ឆ៖** ចាស នុំងមិនមែនខាងទំនប់១មករា ពេលខ្ញុំមកផ្ទះវិញ ខ្ញុំធ្វើការនៅកន្លែងផ្សេង ដល់នាងខ្ញុំឈឺ ខ្ញុំមកគេងវត្តហ្នឹង នៅដូចជាសាលាឆាន់ គឺតម្រង់ -- គឺយើងសម្រាកតាមរនាបពេទ្យនៅវត្តហ្នឹងទៅ។ ហើយមានគ្រូខ្មែរ ខ្ញុំនៅចាំ កាលហ្នឹងខ្ញុំនៅគេងនៅវត្តចំប៉ក់ គ្រូខ្មែរដាំទឹកថ្នាំឲ្យពួកខ្ញុំញុំា ចាស់ៗ។ អ្នកណាឈឺអីអ៊ីចឹងទៅ អ្នករាកអ្នករូសទៅ មានសំបកត្របែកសំបកអីអ៊ីចឹងទៅ អ្នកឈឺផ្សេង ផ្សេងទៅ ហើយនាងខ្ញុំធ្លាប់ នាងខ្ញុំរាកមួលខ្លាំង។ ពេទ្យគេហ្នឹងនៅតាមភូមិៗ កាលហ្នឹងនៅតាមភូមិ នៅក្នុងវត្តនេះគេមានដបគេ ដបគេដូចជាដបទឹកក្រូចយើងសេដាពីមុនហ្នឹង គេដាក់ទឹកថ្នាំក្នុងហ្នឹង ហើយគេយកទឹកហ្នឹងចាក់ពោះនាងខ្ញុំ។

[១០:០៦:៥៣]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីទំនប់១មករាវិញ តើលោកស្រីចាំទេថាមានអ្នកធ្វើការនៅក្នុងកងរបស់លោកហ្នឹង គេបញ្ជូនទៅមន្ទីរពេទ្យទេ?

**ឆ៖** ពេលឈឺខ្លាំង គេថាគេបញ្ជូនទៅមន្ទីរពេទ្យភូមិឃុំដែលអ្នកនៅ អ្នកចេញពីភូមិណា គេច្រើនឲ្យទៅហ្នឹង។ តែនាងខ្ញុំអត់ដឹងគេយកទៅភូមិណា តែក្នុងភូមិនាងខ្ញុំ ដូចអត់មានអ្នកឈឺធ្ងន់ទេ តែភូមិផ្សេងមាន គឺគេយកត្រឡប់មកខាងផ្ទះ។ នៅការដ្ឋានអត់មានមន្ទីរពេទ្យអីធំ សម្រាកផង។

**ស៖** សូមអរគុណ។ តើលោកស្រីដឹងទេ ថាអ្នកឈឺដែលគេបញ្ជូនទៅភូមិខ្លួនឯងវិញហ្នឹង មានត្រឡប់មកធ្វើការនៅទំនប់១មករាហ្នឹងវិញទេ?

**ឆ៖** ចាស អត់ដែលត្រឡប់មកវិញទេ ពីព្រោះអីចាពេលខ្លី៣ខែ។ អត់ដែលឃើញត្រឡប់មកវិញ។

**ស៖** សូមអរគុណ។ តើលោកស្រីធ្លាប់ចូលរួមក្នុងកិច្ចប្រជុំអ្វីទេ នៅពេលដែលលោកស្រីធ្វើការនៅទំនប់១មករា? ខ្ញុំសួរម្តងទៀត ប្រហែលជាលោកស្រីស្តាប់មិនឮ តើលោកស្រីធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយទេ នៅការដ្ឋានទំនប់១មករា? លោកស្រីស្តាប់ខ្ញុំឮទេ?ៗ ខ្ញុំសួរម្តងទៀត តើលោកស្រីធ្លាប់ចូលរួមប្រជុំដែរឬទេ នៅពេលដែលលោកស្រីធ្វើការនៅទំនប់១មករា?

[១០:១០:០០]

**ឆ៖** ចាស ខ្ញុំធ្លាប់ចូលរួមប្រជុំ។ ប្រជុំតាមកង តាមស្រុក ហើយពេលខ្លះមានមីទ្ទិង គេហៅមីទ្ទិង ចូលរួមធំ។

**ស៖** ខ្ញុំនឹងសួរសំណួរខ្លីៗ ពាក់ព័ន្ធទៅនឹងការប្រជុំទាំងនេះ។ ខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំទាំងអស់នេះ?

**ឆ៖** នាងខ្ញុំអត់ស្គាល់ដែរ គេហៅថាកម្មាភិបាលគេធំចុះមក ហៅអង្គការចុះមក បក្សចុះមក។ នាងខ្ញុំឆ្ងល់ដែរ អង្គការអីហ្នឹង បក្សអី កាលនៅតូច នាងខ្ញុំឆ្ងល់ចេះតែសួរ នាងៗខ្ញុំអត់ដឹងដែរ ខាងណា។ ហើយដែលពេលនាងខ្ញុំនៅនោះ នាងខ្ញុំអត់ដែលឃើញមេដឹកនាំទាំងអស់ដែលមកនៅទីនេះទេ អត់ដែលស្គាល់ អត់ដែលដឹងទេ នៅក្នុងរបបពភ្នំ មិនដឹងថាអ្នកណាជាអ្នកមេដឹកនាំកាន់កាប់ក្នុងរបបពភ្នំនោះ នាងខ្ញុំអត់ដឹង អត់ស្គាល់។ ស្គាល់តែមុខប្រធានភូមិ ប្រធានកង ប្រធានអីចឹងទៅ កម្មាភិបាលភូមិភាគខ្លះទៅនាងខ្ញុំអត់ស្គាល់ ឃើញតែមុខមកម្តងម្កាល ហើយនាងខ្ញុំអត់យល់ដែរ។ មិនដឹងថាអ្នកណាកាន់កាប់របបនោះ អត់ដែលឃើញចុះតាមភូមិស្រុក អត់ដែលសោះ។ មិនមែនតែនៅការដ្ឋាន នាងខ្ញុំអត់ដែលឃើញសោះ។

[១០:១១:២៩]

**ស៖** សូមអរគុណ។ តើកិច្ចប្រជុំហ្នឹង គេធ្វើញឹកញាប់ទេ? ហើយពេលដែលគេប្រជុំហ្នឹង គេប្រជុំនៅពេលថ្ងៃ ពេលកំពុងធ្វើការ ឬក៏ប្រជុំក្រោយពីធ្វើការចប់?

**ឆ៖** ភាគច្រើនៗតែប្រជុំពេលចប់ធ្វើការ។ ទាល់តែមានការចាំបាច់ បានយកម៉ោងធ្វើការ កម្រ

មាន មានមើលមីទ្ទិងអាចយកម៉ោងធ្វើការប្រជុំ ហ្នឹងយើងអាចសម្រាក។ ប្រជុំតាមកង តាមភូមិ តាមក្រុមតូចៗ ស្រុកពួកខ្ញុំឧស្សាហ៍ប្រជុំ បើមីទ្ទិង នាងខ្ញុំជួបម្ដង ឬក៏ពីរ នាងខ្ញុំអត់ចាំ ប្រហែលជាម្ដងហើយ ឬក៏ពីរហ្នឹងអស់ហើយ។ ប្រជុំធំរួមអ្នកទំនប់១មករាទាំងអស់គ្នាហ្នឹង ហ្នឹងមីទ្ទិងធំ។ បើតាមកងឧស្សាហ៍ប្រជុំណាស់ អត់ខានទេ បើក្រុមតូចៗហ្នឹងប្រជុំញឹកញាប់។

**សៈ** ឥឡូវខ្ញុំនិយាយអំពីកិច្ចប្រជុំក្នុងក្រុម។ អ៊ីចឹងលោកស្រីចាំទេថា ពេលដែលប្រជុំក្នុងក្រុមតូចៗហ្នឹង តើគេនិយាយអំពីអ្វីខ្លះ?

[១០:១២:៤៦]

**ឆៈ** ប្រជុំតូចៗហ្នឹងគឺនិយាយពីការងារ ជំរុញការងារធ្វើឲ្យលឿនជាងគេ ធ្វើឲ្យស្រុកយើងហ្នឹងបានលឿនជាងគេ ឆាប់ហើយជាងគេ ស្រុកគេណាគេសម្រាក ឬក៏គេធ្វើម៉េចធ្វើយូរ យើងឲ្យបានលឿន។ ចង់ៗដូចថា ឲ្យយើង -- ស្រុកយើងហ្នឹងឈានមុខគេអ៊ីចឹង។ ហើយមួយទៀតគេ – ខ្ញុំសុំនិយាយពីរឿងការភាសានៅរបបនោះ ភាសាខ្មែរក្រហម ទ្រឹស្ដីរបស់គាត់ៗចូលចិត្តថា “ស្វ័យទិតៀន” ស្វ័យទិតៀនហ្នឹង គឺឲ្យមើលគ្នាទៅវិញទៅមកដើម្បីកែលម្អ។ តាមពិតគឺចាំចាប់កំហុស ហើយចូលចិត្តប្រើពាក្យ “ភ្នែកម្នាស់ អង្គការភ្នែកម្នាស់ ហើយកងប្រវត្តិសាស្ត្រហ្នឹង គឺវិលៗ បើយើងនេះមិនទាន់ប៉ះដៃគឺដៃ ប៉ះជើងគឺជើង”។ ហើយចូលចិត្តនិយាយពាក្យ បើស្រែកជយឃោស “ជយោ! មហាលោតផ្លោះមហាអស្ចារ្យ” ហើយឲ្យយើងធ្វើការហ្នឹងទៅ ក្បាលអ្នកណាសក់អ្នកហ្នឹងហើយ ណំាកុំនឹកម៉ែឪ នៅឯណោះអីផ្សេងអ៊ីចឹង។ ហើយខ្ញុំមិនយល់ដែរ ហើយ “ទុកមិនចំណេញ ដកចេញមិនខាត ឥឡូវហ្នឹងយើងត្រូវតែប្រឹង យើងត្រូវតែអ៊ីចឹង ហើយលើកឲ្យឆាប់ហើយអ៊ីចឹង”។ ហើយបើប្រជុំពីរឿងនេះទៀត ឲ្យយើងប្រឹងធ្វើស្រែ ក្នុងមួយហិកតាឲ្យបាន៣តោន គឺនិយាយតែពីរឿងធ្វើការ ឬរឿងលោតផ្លោះមហាអស្ចារ្យហ្នឹង ជំរុញពីការងាររហូត។ ហើយអ្នកឈឺហ្នឹង មានគេហៅឈឺគ្រុនទន្សាយ អីល្មមៗគឺត្រូវឲ្យយើងទៅធ្វើការ កុំឲ្យយើងទម្រន់។ របបនេះគឺអត់មាន ថាយើងរំដោះបានហើយ គឺអត់មានអ្នកខ្ជិលច្រអូស អ្នកពុករលួយ គេតាមសង្កេតមើលយើង បើយើងខ្ជិល បើយើងម៉េចៗ គេថាយើងនាយទុនសក្តិភូមិអីអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានរយៈពេលប្រហែល១៥នាទីទៀត សួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រី សុវិដា អម្បាញ់មិញយើងបាននិយាយអំពីការរៀបរាប់អំពីកិច្ចប្រជុំមួយចំនួន ហើយលោកស្រីបានពន្យល់ថា មានធ្វើការប្រជុំនៅក្នុងក្រុមរបស់លោកស្រី ហើយនិងប្រជុំធំជាងហ្នឹងទៀតដែលជាលក្ខណៈលើកលែងម្តងម្កាល។ តើលោកស្រីអាចរៀបរាប់អំពី គេហៅមីទ្ទិង អម្បាញ់មិញលោកស្រីបានប្រើពាក្យ "មីទ្ទិង" ដែលថាមិនសូវញឹកញាប់ទេ ដែលគេតែងតែប្រជុំនៅថ្នាក់លើ។ អ៊ីចឹងលោកស្រីអាចរៀបរាប់លម្អិតអំពីមីទ្ទិងនេះបានដែរឬទេ?

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ចាស មីទ្ទិង គឺនិយាយតែពីរឿងការងារ បង្កបង្កើនផល រឿងដូចដែលស្រដៀងពីក្រុមកងអីប្រជុំអ៊ីចឹង ដូចគ្នាដែរ និងជំរុញការងារ ធ្វើប៉ុននេះទៅ ប៉ុននោះឆ្នាំក្រោយយើងធូរធារទៅ បងប្អូនយើង

ហូបចុកអីគ្រប់គ្រាន់ទៅ សល់ពីហូបចុកទៅជួយអង្គការទៅ គឺនិយាយតែពីរឿងជំរុញពីការងារហ្នឹង។ អត់មានរឿងអីផ្សេងពីហ្នឹង មានតែរឿងការងារ។ យើងរំដោះបាន ប្រទេសយើងរំដោះបានមកហើយ យើងត្រូវតែតស៊ូ ខិតខំ ពីថ្ងៃនេះទៅលែងមានអីណារត់ភ័យ ឬក៏អ៊ីចឹង។ នាងខ្ញុំចាំបានតែប៉ុណ្ណឹង ហើយជូនគេស្រែក ជយោៗអ៊ីចឹងទៅ បដិវត្តន៍អ៊ីចឹងទៅ ស្រែកជយឃោស មហាលោតផ្លោះ មហាអស្ចារ្យ នាងខ្ញុំលើកដៃតាមគេទៅ អង្គុយគ្នាច្រើនហ្នឹង តែប្រជុំដាក់មេក្រូ។ នាងខ្ញុំដឹងបានតែប៉ុណ្ណឹង។

[១០:៣៥:៤០]

**ស៖** សូមអរគុណ។ លោកស្រីនិយាយថាមិនមានអ្នកណាអាចរត់រួចទេ អ៊ីចឹងខ្ញុំសួរលោកស្រីថាតើមានគេឃ្លាំមើលលោកស្រីទេ នៅលើការដ្ឋានហ្នឹង?

**ឆ៖** នៅការដ្ឋានហ្នឹង គេចែកជាក្រុម ជាពួក។ អ៊ីចឹងអ្នកនៅក្នុងក្រុមហ្នឹង គឺមើលការងាររបស់ពួកយើងធ្វើការ អ្នកណាខ្ជិល អ្នកណាយ៉ាងម៉េចៗហ្នឹង។ ហើយពេលខ្លះ ខ្ញុំឃើញមានដូចជាគេហៅថាទាហានកងឈ្លប ស្លៀកពាក់ខ្មៅដើរម្តងម្កាល។ ឧទាហរណ៍ដូចថាប៉ុន្មានថ្ងៃអ៊ីចឹង ឃើញដើរកាត់តាមទំនប់អ៊ីចឹងទៅ គ្រប់កន្លែងអ៊ីចឹងទៅ។ អាហ្នឹងគេឈ្លប គេតាមមើល បើសិនជានៅតាមភូមិវិញ គឺមានកងឈ្លបតាមក្រោមផ្ទះរហូត ពួកប្រជាជន១៧មេសា បើនៅកងចល័តអ៊ីចឹង គេតាមមើលនៅកន្លែង។ តែយើងអត់ស្គាល់គេនេះ គេដើរអ៊ីចឹង។

**ស៖** សូមអរគុណ។ តើនៅសម័យនោះ លោកស្រីមានបានសង្កេតឃើញថាឈ្លប ឬក៏យោធាហ្នឹងមានអាវុធដែរឬទេ? ហើយលោកស្រីមានចាំដែរឬទេ អំពីវត្ថុមានរបស់ឈ្លបទាំងអស់ហ្នឹង មានអាវុធឬក៏អត់?

**ឆ៖** នាងខ្ញុំចាំថា ដូចជាមានស្ពាយកាំភ្លើងវែង អត់កាំភ្លើងខ្លីដូចយើងទេ កាំភ្លើងដូចវែង។

**ស៖** សូមអរគុណ។ តើមានមីក្រូដែរឬទេនៅលើការដ្ឋាន? ហើយគេនៃធ្វើការប្រកាស ឬក៏គេចាក់ចម្រៀងអីជាដើមនោះ?

[១០:៣៧:៣៩]

**ឆ៖** ចាស មាន១មីក្រូជានិច្ចកាលនៅពេលធ្វើការគឺចម្រៀង។ តែចម្រៀងច្រៀងរហូត គឺចម្រៀង។ ខ្ញុំសូមនិយាយតាមការពិត ចម្រៀងច្រើនតែចម្រៀងបដិវត្តន៍ យើងរំដោះ យើងធ្វើអី១ មហាលោតផ្លោះ មហាអស្ចារ្យ វេទនាអ៊ីចឹងពីបដិវត្តន៍ និយាយទៅចម្រៀងគេ គឺចម្រៀងច្រៀងកំដររហូត។ បើរឿងចម្រៀងស្នេហាអត់មានទេ ខ្ញុំចាំ ចម្រៀងច្រើនតែបដិវត្តន៍អ៊ីចឹង បដិវត្តន៍កម្ពុជាសែងសុរិយា

អ៊ីចឹងទៅ ភូមិយើងរំដោះទៅ ឬក៏និយាយពីរឿងតស៊ូ រឿងអី មិត្តបង មិត្តយើងអីអ៊ីចេះអ៊ីចុះអ៊ីចឹង។

**ស៖** តើគេចាក់ចម្រៀងបដិវត្តន៍ហ្នឹងញឹកញាប់ប៉ុនណាដែរ ឬគេចាក់រាល់ថ្ងៃ ឬក៏យ៉ាងណា?

**ឆ៖** ចាក់រាល់ថ្ងៃ ហើយនៅលើការដ្ឋានគឺចាក់ជានិច្ចកាល។

**ស៖** តើគេមានផ្សាយសារអ្វីផ្សេងទៀតក្រៅពីចាក់ចម្រៀងហ្នឹងដែរឬទេ តាមមីក្រូហ្នឹង?

**ឆ៖** អត់ដែលឮសូរផ្សាយអីផង ហើយវ៉ាដ្យូក៏ដូចអត់ដែលឮដែរ អត់មានតែចម្រៀង ធម្មតាតែប៉ុណ្ណឹង។ បើមានផ្សាយអីឬក៏អី គេហៅប្រជុំ ឬប្រកាសបងប្អូនយ៉ាងម៉េចៗ ខ្ញុំលើកថាប្រជុំធំអ៊ីចឹងប្រកាសមីក្រូ ឬក៏មានបញ្ហាអី ខ្ញុំចាំអត់បានទេ ខ្ញុំចាំចម្រៀង ខ្ញុំតាមៗស្តាប់ចម្រៀងរហូត។

[១០:៤០:00]

**ស៖** តើលោកមានចាំ -- លោកស្រីមានចាំអំពីសេចក្តីណែនាំទាក់ទងនឹងសន្តិសុខដែរឬទេ ដែលគេប្រាប់ទៅអ្នកធ្វើការនៅលើការដ្ឋាននោះ ឲ្យប្រុងប្រយ័ត្នជាដើមហ្នឹង លោកស្រីមានចាំដែរឬទេ?

**ឆ៖** គេអត់មានប្រកាសរួមធំទេ តែប្រធានកងប្រធានអីហ្នឹង ដូចជាអត់មានប្រកាសអីទេ។ គ្រាន់តែប្រាប់ថា យើងរែក យើងដើរធ្វើម៉េចៗអ៊ីចឹង ពេលខ្លះក៏មានអ្នករអិលដួល មានអ្នកអីអ៊ីចឹងដែរ។ គ្រាន់តែប្រាប់ថា ប្រយ័ត្នប្រយែង ឬក៏អីនៅក្នុងក្រុមខ្លួនគ្នាឯងប៉ុណ្ណឹង។ ព្រោះអីអត់មានស្អីក្រៅពីការងារដែលមានគ្រោះថ្នាក់ពីលើការងារដូចជា នាងខ្ញុំអត់ដែលជួបប្រទះដែរ។ មុតចប មុតអីបន្តិចបន្តួចហ្នឹងជារឿងធម្មតា។

**ស៖** នៅពេលដែលលោកស្រីនិយាយថា មានគេឈរដេកអីជាដើមនោះ តើលោកស្រីមានធ្លាប់ឃើញមានគេគ្រោះថ្នាក់ដែរឬទេ?

**ឆ៖** មាន ជួនកាលមានគ្រោះថ្នាក់ថ្លោះជើង គ្រេចជើងអ៊ីចឹង យើងទៅរអិលអាចរអិលអាចអីអ៊ីចឹង។ កន្លែងខ្លះជីកទៅក៏វាជ្រៅទៅក៏មានចេញទឹក វាអាចអ៊ីចឹង ព្រោះនាងខ្ញុំធ្លាប់ ជួនកាលរែកទាំងអាក្នុងអាគេជីកទៅចេញទឹកមានភក់ៗ អ៊ីចឹងទៅ។ ខ្លះដួលបន្តិចបន្តួចអ៊ីចឹងទៅ។ បើថាឲ្យដល់ស្លាប់ដូចជាអត់មានទេ កាលទំនប់១មករា កន្លែងពួកខ្ញុំអ៊ី្ន។ កន្លែងផ្សេងខ្ញុំអត់ដឹងដែរ ចាស។

[១០:៤២:០៤]

**ស៖** ខ្ញុំសូមអរគុណ។ តើលោកស្រីមានចាំថា ធ្លាប់បានឃើញឥស្សរជនជាក់លាក់ណាមួយក្នុងរយៈពេល៣ឆ្នាំ -- ៣ខែ (សូមទោស) ដែលលោកស្រីធ្វើការនៅទំនប់១មករានុ៎ងដែរឬទេ គេមកធ្វើទស្សនកិច្ចអីនៅទីនុ៎ងណា?

**ធ៖** ចាស ខ្ញុំធ្លាប់ឃើញម្តង។ ពេលនោះឃើញ នាងខ្ញុំកំពុងរែកដីទាំងអស់គ្នា គេឲ្យយើងរែកស្វាហាប់ឡើង កុំឲ្យយើងឃើត ឲ្យរហ័សរហួនដៃជើង ទឹកមុខឲ្យញញឹមរីករាយពេលឃើញគេមក។ គេដើរមកប្រាប់មុនអ៊ីចឹងណ៎ា ដល់ហើយបានមានប្រធានកងប្រធានក្រុមអ៊ីចឹងប្រាប់ថា ឲ្យយើងស្វាហាប់ រែកឲ្យលឿនៗឡើង មានអង្គការ កម្មាភិបាលធំៗគេចុះមកមើលអ៊ីចឹង។ ពេលនោះ ខ្ញុំឃើញគ្នាគេចំនួនប្រហែលជាក្រោម១០នាក់ អត់ដល់១០នាក់ដែរ។ ដើរមកជិតនាងខ្ញុំដែរ ហើយឃើញមានគេថតរូបដែរ ហើយស្លៀកពាក់ខោអាវខ្មៅ បង់កក្រមា សៗ។ របៀបដូច សដូចចិន វៀតណាមអីអ៊ីចឹង សៗ ហើយក៏មានខ្មែរយើងនៅក្នុងហ្នឹងដែរ សៗ តែខ្ញុំអត់ស្គាល់លោក ប៉ុល ពត លោកណាមុខម៉េចអត់ស្គាល់ តែខ្ញុំបានឃើញ យើងក៏អត់ហ៊ានមើលមុខគេដែរ។ យើងដឹងតែរែកដីលឿនៗ គេអត់ឲ្យយើងសម្រាក អត់ឲ្យយើង -- ឧទាហរណ៍ថា សព្វថ្ងៃយើងរែកមានដើរឃើតបន្តិចខ្លះអ៊ីចឹងណ៎ា ដល់ពេលមកគឺយើងប្រឹងរត់តែម្តង ប្រឹងឲ្យលឿន។ ហើយគាត់មកប្រហែលជាមួយស្របក់ធំក៏គាត់ត្រឡប់ទៅវិញទៅ។ ម្តងតែប៉ុណ្ណឹង។ ហើយក៏នាងខ្ញុំគិតឆ្ងល់ថា អ្នកណាគេចេះតែសួរពួកបងៗ គេថា អត់ដឹងដូចគ្នាអូន។

[១០:៤៣:៥៧]

**ស៖** តើនៅពេលណាមួយលោកស្រីធ្លាប់ឃើញ មានក្រុមថតកុនមួយនៅលើការដ្ឋានហ្នឹងដែរឬទេ?

**ធ៖** នាងខ្ញុំដូចអត់ដែលឃើញថតកុនទេ ប៉ុន្តែរូបភាពនោះ ហាក់ដូចជាឃើញនៅពេលបញ្ចាំងក្នុងទូរទស្សន៍ពេលរាល់ថ្ងៃ ឃើញដូចជាមាននៅ -- បញ្ចាំងក្នុងទូរទស្សន៍ហាក់ដូចជារូបភាពហ្នឹងដូចនាងខ្ញុំធ្លាប់ឃើញ ប៉ុណ្ណឹង។ តែនាងខ្ញុំអត់ដឹងថា គេថតជាកុន ឬក៏គេថតអី ខ្ញុំអត់ដឹងដែរ។ ឃើញពេលរែកដី ហើយនិងគេឈរអ៊ីចឹង សកម្មភាពហ្នឹងស្រដៀងពួកខ្ញុំនៅលើទំនប់១មករា។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនទៀត បន្តមកទៀតពេលព្រះរាជអាជ្ញានឹងចោទសំណួរ។ លោកស្រីនិយាយថា នៅកន្លែងដែលលោកស្រីសម្រាកពេលយប់នោះមិនមានទឹកទេ ហើយលោកស្រីថាត្រូវទៅរកទឹក។ អ៊ីចឹងលោកស្រីអាចពន្យល់អំពីលក្ខខណ្ឌអនាម័យនៅលើការដ្ឋាននៅទំនប់នុំងបានដែរឬទេ ហើយនិងលក្ខខណ្ឌអនាម័យនៅកន្លែងលោកស្រីស្នាក់នៅជាដើម?

[១០:៤៥:៣២]

**ធ៖** ចាស លក្ខខណ្ឌនៅកន្លែងការដ្ឋាន គេមានទឹកដាំនៅនឹងខ្ទះត្នោត។ ពួកខ្ញុំយកទៅដងទឹកក្តៅ

អ៊ីចឹងទៅ ញ៉ាំទៅ។ ជួនកាលអស់ ហើយកន្លែងគេង១អត់មានទេ មានតែមានទឹកដាំនៅរោងបាយដែរ តែទឹកងូតអត់មានទេ។ នាងខ្ញុំដើរកាត់ទៅ នាងខ្ញុំងូតទឹកអណ្ដូងនៅជិតភូមិ១អ្នកស្រុកគេនៅកន្លែងជិតកំពង់ថ្ម នៅកំពង់ថ្មហ្នឹងហើយបានទៅគេងនៅកន្លែងការដ្ឋានហ្នឹងហើយ កន្លែងគេង នៅកន្លែងគេង មិនមែនកន្លែងការដ្ឋានទេ។ ហើយកន្លែងគេងហ្នឹងអត់មានទឹកងូតទេ តែបង្គន់គេធ្វើនៅកន្លែងគេង គឺគេជីក១បង្គន់ដីហ្នឹង គេដាក់ឈើ ហើយគេមានស្លឹក។ នាងខ្ញុំនឹកឃើញ។ ហើយនៅកន្លែងការដ្ឋានគេមានធុងសាំង គេដាក់ឲ្យយើងឡើងទៅបត់ជើងនៅក្នុងធុងសាំង។ តែពេលខ្លះនាងខ្ញុំខ្លាចធុងសាំងខ្ពស់ នាងខ្ញុំទៅបត់ក្នុងព្រៃ តែគេអត់ឲ្យយើងបត់ព្រៃទេ គេឲ្យបត់ធុងសាំង ដើម្បីយកធ្វើជី។ ហើយនៅកន្លែងគេងហ្នឹងហើយពួកខ្ញុំអត់ដែលមានសាប៊ូ អត់ដែលមានថ្នាំដុះធ្មេញ អត់ដែលមានអ្វីដែលសម្អាតខ្លួនកាយ គឺអត់ដែល គេអត់មានរបបឲ្យយើងទេ។ ហើយនាងខ្ញុំពេលទៅហ្នឹង ដូចគេចែកខោអាវឲ្យនាងខ្ញុំបានមួយសម្រាប់ពណ៌ខ្មៅ តែប៉ុណ្ណឹង។ ហើយមានខោអាវខ្លួនឯងចាស់១ខ្លះទៅ តែខោអាវក៏អត់មានច្រើនដែរ បន្តិចបន្តួចទៅ ហើយសម្អាតខោអាវក៏គ្មានដែរ គឺបោកទឹកទទេ។ ជួនកាលមានសំបកស្លា ឬក៏ស្លឹកស្វាយទៅជំនួសនឹងធ្មេញអ៊ីចឹងទៅ។ ហើយខ្លួន នាងខ្ញុំដឹងថាមាននទោងសាញ ពេលណាមានឃើញអ៊ីចឹង យើងបេះយកងូតលាងខ្លួនដែរ។ ទាំងអស់គ្នាហ្នឹង គ្មានមានអ្នកណាសំអាតទេ ខ្លួនរស់នៅដូចឋានរកអ៊ីចឹង គួរឲ្យខ្លាចគួរឲ្យខ្ពើម តែក្រាសសិតសក់ហ្នឹងស្ទើរតែគ្មានផង។ ខោអាវរហែកគ្រប់១គ្នា១ ជួនកាលពួ១ គាត់ឲ្យខ្ញុំដេរម៉ោងសម្រាកអីបន្តិចបន្តួច ខ្ញុំជួយដេរបន្តិច១បានដែរ។ អំបោះក៏អត់មានដែរ មានបារយើងហ្នឹង អាបារគេហៅបារនីឡុងហ្នឹងហូតពីហ្នឹងមក ឬក៏អាស្លឹកត្នោតមានតែសរសៃម៉េចហ្នឹង គឺដេរអាបារយើង ដូចបារអីហ្នឹង មិនដឹងគេបានពី -- មានមក មានបន្តិចបន្តួចយកតាមភូមិមកអ៊ីចឹងចែកគ្នាហូតដែរទៅ។ ខ្លះក៏នៅមានសល់អំបោះ អ្នកចាស់ អ្នកប្រជាជនមូលដ្ឋាន ព្រោះកាលជំនាន់នោះ គេចែកចេញជាពីរ ប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋាន។ មូលដ្ឋានចាស់ ប្រជាជនចាស់ ហើយចែកចេញជាពីរទៀត មូលធន និងអ្នកក្រ។ ហើយពួកគេហ្នឹងមានសិទ្ធិជាងពួកខ្ញុំ ពួកគេច្រើនមានអ្វី១ច្រើនជាងពួកខ្ញុំ។ ពួកខ្ញុំជួនកាលអាចសុំពីគេអីមកដេរ ខ្ចីគេបន្តិចបន្តួចទៅ។

[១០:៤៨:៤០]

**សៈ** សំណួរចុងក្រោយរបស់ខ្ញុំ។ តើនៅក្នុងកាលៈទេសៈណាដែរ ដែលលោកស្រីចេញពីទំនប់១មករានោះ? ខ្ញុំចង់ដឹងថាតើលោកស្រីចេញចាកចេញពីនុំងមក តែម្នាក់ឯងទេ ឬក៏លោកស្រីចេញមកជាក្រុម ជាមួយអ្នកដទៃទៀត? តើលោកស្រីអាចពន្យល់អំពីកាលៈទេសៈនៃការចាកចេញពីទំនប់១មករា

ជូនតុលាការបន្តិចបានទេ?

**ឆ៖** នាងខ្ញុំចេញមក គឺចេញមកទាំងអស់គ្នានៅតាមភូមិឃុំពួកនាងខ្ញុំ ត្រឡប់មកផ្ទះវិញ មកទាំងអស់គ្នា។ ពេលនោះនាងខ្ញុំនៅចាំ ពេលចេញមកហ្នឹងគេដាំបាយ។ គេដាំបាយ គេមានត្រីអាំងកាប់មួយដុំៗម្នាក់ចែកគ្នាញ៉ាំតាមផ្លូវមក។ ញ៉ាំបាយត្រីអាំងហ្នឹង ត្រីងៀតៗដុំៗ ម្តងហ្នឹង។ ហើយនាងខ្ញុំអត់ប៉ានញ៉ាំទេ នាងខ្ញុំអាណិតម៉ាក់ប៉ាខ្ញុំនៅផ្ទះ នាងខ្ញុំទុកត្រីមួយដុំហ្នឹងយកមកឱ្យគាត់នៅផ្ទះ។ ហើយគាត់ថាចុះម៉េចកូនឯងមិនញ៉ាំ? ញ៉ាំមួយអី? ខ្ញុំថា អត់ទេ ញ៉ាំសុំអំបិលគេញ៉ាំ កូនឆ្អែតហើយ នៅនុំងសម្បូរចេះភរគាត់ កុំឱ្យគាត់គិតថាខ្ញុំនៅពិបាក ខ្ញុំគេសួរ គាត់សួរខ្ញុំ គឺខ្ញុំតែងតែថាខ្ញុំហ្នឹងអត់អីទេ ដូចគេដូចឯងស្រួល។ តែខ្លួនខ្ញុំតូច ខ្ញុំសម្ពាធខ្លាំងមែនទែន។ តែខ្ញុំអត់ផ្ទត់ណាស់ជំនាន់នោះ។ ត្រឡប់មកផ្ទះវិញ នៅតាមភូមិ តាមស្រុករៀងខ្លួន អ្នកនៅភូមិណាមកភូមិហ្នឹងទៅ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធានសូមអរគុណ ខ្ញុំសូមជម្រាបជូនថា លោកស្រី សុវិដា គាត់បានត្រៀមនឹងថ្លែងទុក្ខរបស់គាត់ ហើយគាត់នឹងអាន ហើយគាត់មានអត្ថបទហ្នឹងវែងដែរ។ គាត់ត្រូវការពេលប្រហែលជាជាង១០នាទីលោកប្រធាន។ អ៊ីចឹងសូមឱ្យជួយគ្រោងពេលវេលានេះ ដើម្បីទុកពេលឱ្យគាត់អាន លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ បាទ សូមអញ្ជើញ!

[១០:៥១:២៤]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំតំណាងសហព្រះរាជអាជ្ញាជាតិឈ្មោះ សុង ឆវ័ន្ត មានសំណួរខ្លីដើម្បីសាកសួរលោកស្រី។ ហើយដោយសារពេលវេលាផងដែរ អ៊ីចឹងខ្ញុំ

ចង់ឲ្យលោកស្រីព្យាយាមឆ្លើយឲ្យខ្លីៗចំទៅនឹងសំណួរ។ ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិច ចង់សួរពាក់ព័ន្ធទៅនឹងឪពុកម្ដាយរបស់លោកស្រី។ តើឪពុកនិងម្ដាយរបស់លោកស្រីគាត់ធ្វើការ ឬបំពេញការងារអ្វីដែរ មុន១៧ មេសា ៧៥?

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ម្ដាយខ្ញុំមេផ្ទះ ឪពុកខ្ញុំគាត់និយាយពីមុនមកវាពាក់ព័ន្ធរហូតមក។ ពុកខ្ញុំគាត់ធ្លាប់ជាខ្មែរឥស្សរៈ។ បន្តមកទៀតគាត់ៗធ្វើទាហាន ដល់ក្រោយធ្វើទាហាននៅជាមួយទ្រង់ ចន្ទរង្សី-ត្រីប៉េអ៊ី យើងបន្ទាយច្បារមនកំពង់ស្ពឺ។

[១០:៥២:២៧]

**ស៖** តើលោកស្រីដឹងទេថា ពេលគាត់ធ្វើទាហានហ្នឹង គាត់មានតួនាទី ឬក៏មានស័ក្តិប៉ុន្មានដែរ?

**ឆ៖** គាត់ពីមុនមកគាត់ធ្លាប់ជាអ្នកនេះដែរ តែក្រោយមកទ្រង់ -- ចាប់ពីឆ្នាំ៧០មកទ្រង់ឲ្យគាត់ធ្វើជាកុងតាប អូដេ ហៅអូដេ។

**ស៖** គាត់ធ្វើការហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** គាត់មានទីតាំងនៅបន្ទាយច្បារមនយើងហ្នឹង។

**ស៖** ចាស ហើយគាត់ធ្វើការដល់ពេលណាដែរ? គាត់ធ្វើ--

**ឆ៖** គាត់ធ្វើរហូតដល់ពេលបែកភ្នំពេញ។ មុនបែកភ្នំពេញ៧ថ្ងៃ គាត់ជិះកប៉ាល់ហោះអេក្លូកុកទ័រ គាត់មកភ្នំពេញ។ មកបាន៧ថ្ងៃ បែកភ្នំពេញ ហើយគាត់ចុះឡើងៗភ្នំពេញរហូតជាមួយពួកខ្ញុំ។ ពួកខ្ញុំនៅភ្នំពេញ កំពង់ស្ពឺនោះផ្ទះខ្ញុំនៅៗទីនោះៗប្រហែលបី អ៊ីចឹងគាត់នៅក្នុងបន្ទាយជាមួយទ្រង់។ គាត់មាន -- និយាយទៅគាត់មានស័ក្តិតាំងពីជំនាន់សីហនុមក តែគាត់មិនដែលចង់ឲ្យអ្នកណាដឹងរឿងស័ក្តិ រឿងអីរបស់គាត់ ព្រោះគាត់ដឹងរបបហ្នឹងយ៉ាងម៉េចៗ ខ្លាចពេលប្រែក្រឡាស់ទៅ តែអ្នកស្គាល់គាត់ នៅតែគេស្គាល់។

[១០:៥៤:១០]

**ស៖** ចុះពេលដែលជម្លៀសទៅហ្នឹង តើគាត់ព្យាយាមបង្ហាញពីប្រវត្តិរូបរបស់គាត់ ឬក៏លាក់បាំងប្រវត្តិរូប ឬគាត់ធ្វើយ៉ាងណាដែរ?

**ឆ៖** ប៉ាគាត់តែងតែលាក់ប្រវត្តិរូប។ តែម៉ាក់ខ្ញុំគាត់ហាក់ដូចជាជឿជាក់ថា ជំនាន់នោះនៅពេលដែល -- ខ្ញុំនិយាយ ខ្ញុំអាចនិយាយបានទេ គាត់ដឹងថាពេលខ្មែរក្រហមហ្នឹង គាត់ដឹងថាសម្ដេច សីហនុ

ហ្នឹងជា មេ -- គាត់ដូចថាបង្កើតខ្មែរក្រហមដែរ។ ពេលនុ៎ងប៉ាខ្ញុំក៏ចប់ពីឥស្សរៈហ្នឹង គាត់ក៏ចង់ចូលទៅក្នុងពេលនុ៎ងដែរ។ អ៊ីចឹងម៉ាក់ខ្ញុំគាត់ចេះតែទន្ទឹងថា ប្រហែលជាមានពេលវេលា គាត់នៅចង់ប្រាប់គេថាពីមុនមកប៉ាធ្លាប់អ៊ីចឹង គាត់ចង់ប្រាប់អ៊ីចឹងណ៎ា ដល់ពេលហើយប៉ាខ្ញុំមិនឲ្យនិយាយទេ។ ប៉ាក់ស័ក្តិក្រោយៗប៉ាឲ្យកប់រូបថតចោលអស់ តែម្ដាយខ្ញុំគាត់អត់ទេ ស្ដាយ គាត់ចៀរក្បាលប៉ាខ្ញុំនៅអ៊ីចឹង។ រួចខោអាវអីយកទៅកប់នៅកៀនស្វាយអស់ ចេញទៅប៉ាអត់ឲ្យយកអីវ៉ាន់ទៅទេ។

**ស៖** ចាស សូមអរគុណ។ បើនៅពេលវេលាខ្ញុំនឹងត្រឡប់មកប្រធានបទនេះម្ដងទៀត។ និយាយដល់ ពេលដែលលោកស្រីទៅដល់ទំនប់១មករា គឺលោកស្រីមុននេះបានឆ្លើយជាមួយនឹងសហមេធាវីនាំមុខថា លោកស្រីបានទៅដល់វត្តបារាយណ៍ជាន់ដែក។ អ៊ីចឹងខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា ពេលលោកស្រីទៅដល់ទំនប់១មករា លោកស្រីស្នាក់នៅកន្លែងណា? ហើយឈ្មោះអី? ចាំទីតាំងទេ?

[១០:៥៥:៥៤]

**ឆ៖** នាងខ្ញុំ មិនមែនទៅសម្រាកនៅក្នុងវត្តហ្នឹងទេ តែនៅជិត ឆ្ងាយពីវត្តហ្នឹងប្រហែលប៉ុន្មានរយម៉ែត្រដែរ។ នាងខ្ញុំអត់ចាំភូមិទេ តែដឹងថាកំពង់ថ្មនៅលើផ្លូវជាតិ កំពង់ថ្ម។ នៅជិតខ្លោងទ្វារហ្នឹង ផ្ទះប្រជាជនហ្នឹង គេឲ្យយើងសម្រាកនៅផ្ទះប្រជាជន។

**ស៖** តើការដែលសម្រាកហ្នឹង គឺនៅក្បែរវត្តបារាយណ៍ជាន់ដែកដែរ ឬក៏យ៉ាងម៉េច? ប្រហែលជាប៉ុន្មានដែរ?

**ឆ៖** នាងខ្ញុំស្មានអត់ត្រូវដែរ ព្រោះអីពេលងូតទឹកអណ្ដូង ពួកបងៗថា "កុំទៅជិតវត្តហ្នឹង អត់បានទេ" អត់ឲ្យពួកខ្ញុំទៅទេ ហើយពួកខ្ញុំងូតនៅឆ្ងាយ ពួកបងៗខ្លះគេចាំយួរ អណ្ដូងមួយអ៊ីចឹង ដូចថាភូមិមួយៗ អណ្ដូងវាវាងឆ្ងាយដែរ គ្នាច្រើននោះ ដល់ចាំគ្នាអ៊ីចឹងទៅ គេក៏ដើរទៅឆ្ងាយហ្នឹង គេហាមអត់ឲ្យទៅនុ៎ងទេ។ តែមានអ្នកខ្លះគេទៅ គេទៅគេឃើញសកម្មភាព តែគេអត់និយាយអី គេថា "កុំទៅកន្លែងហ្នឹងមិនឲ្យយើងនេះទេ ទៅវិញ"។ គាត់ភ័យញ័រទទ្រាក់ទទ្រើតមកវិញ ហើយពួកខ្ញុំក៏អត់ដែលបានទៅឃើញវត្តហ្នឹង ឬក៏គេធ្វើសកម្មភាពអីហ្នឹង ក៏ខ្ញុំអត់ដែលឃើញដែរ។ ខ្ញុំបានឮដំណឹងតាមបងៗអត់ឲ្យពួកខ្ញុំទៅងូតហ្នឹង ទ្រាំចាំគេទៅ។

[១០:៥៧:២៣]

**ស៖** តើអ្នកទាំងនោះមានបានប្រាប់លោកស្រីទេថា ហេតុអ្វីកុំឲ្យទៅវត្តបារាយណ៍ជាន់ដែកហ្នឹង ឬក៏មានការបារម្ភពីរឿងអីដែរ?

**ឆ៖** គេថា គេបានឃើញមាន ប្រហែលជាមួយក្រុមប្រាំនាក់ បួនដប់នាក់អត់សូវច្រើនទេ តែគេឲ្យធ្វើការ ឃើញកាប់អុស ចងច្រវាក់ជើងហ្នឹងតគ្នាអ៊ីចឹង។ រួចទៅអ្នកខ្លះឃើញគេកាត់ដោះស្រីៗហ្នឹងព្យួរនៅតាមទ្វារហ្នឹងឈាមកក្លាក់។ រួចថា "កុំទៅ កុំចង់ដឹង" គេខ្សឹបគ្នា គេមិនឲ្យខ្ញុំក្មេងដឹងទេ។ ខ្ញុំគ្រាន់តែបានឮតិចៗ តាមគេប្រាប់គ្នាអ៊ីចឹង ហើយគេថា "កុំចង់ស្លាប់អូន កុំដឹងអូន កុំ"។

**ស៖** ចាស សូមអរុណ។ នៅក្នុងទំនប់១មករានេះដែរ នៅពេលដែលលោកស្រីបញ្ជាក់ថា លោកស្រីបានធ្វើការ៣ខែនៅក្នុងការដ្ឋានទំនប់១មករានោះ។ ខ្ញុំចង់ដឹងថា ស្ថានភាពទឹកដែលលោកស្រីថា ទៅដងទៅឲ្យគេបរិភោគហ្នឹង តើទឹកហ្នឹងយ៉ាងម៉េចដែរ? ហើយទៅដងនៅកន្លែងណា?

**ឆ៖** មានរោងមួយនៅក្នុងការដ្ឋានហ្នឹង គេដាំទឹកសម្រាប់ពួកការដ្ឋាន។ គេដាំជាខ្ទះអ៊ីចឹងទៅជូនគេចាក់ចូលធុងទៅ យើងទៅ យើងទៅដងពីកន្លែងរួមហ្នឹងមក ឲ្យពួកកន្លែងក្រុមយើងញ៉ាំ។ ដូចថាអ្នកមានប៊ីដុងទៅ អ្នកនោះមានបំពង់ទៅ ឬក៏មានធុងអីធំទៅ ខ្ញុំរែកទៅណាស់ មានដងរែក ខ្ញុំដាក់ពាក់រែកអ៊ីចឹងទៅ។ ខ្ញុំយកមកឲ្យគេទៅ អស់ទៅខ្ញុំទៅដងទៀតទៅ ព្រោះគេយល់ថាខ្ញុំតូច ក៏ខ្ញុំធ្វើការអត់បានច្រើនអីដែរ ប្រើទៅដងទឹកឲ្យគេញ៉ាំទៅ ហើយទំនេរពីដងទឹក រែកដីវិញទៀត។

**ស៖** តើស្ថានភាពទឹកពេលនោះ វាជាទឹកស្អាត ឬទឹកយកពីកន្លែងណាដែរ? ហើយទឹកហ្នឹងពេលដែលលោកស្រីនិយាយថា គេដាំឲ្យហូបហ្នឹង តើគេដាំឲ្យហូបគ្រប់គ្នា ឬក៏យ៉ាងម៉េច?

[១០:៥៩:៣៥]

**ឆ៖** គេដាំនោះ គេដាំសម្រាប់ពួកការដ្ឋានទាំងអស់ហ្នឹង ក៏ប៉ុន្តែទឹកហ្នឹង នាងខ្ញុំអត់ដឹងថាទឹកអីទេ តែនៅស្រុកហ្នឹងច្រើនយកពីស្រះ ពីស្ទឹង ពីអូរអ៊ីចឹងមកប្រើ ដូចអត់មានទឹកម៉ាស៊ីនទេនៅស្រុកហ្នឹង។ ទឹកអូរត្រពាំងអីអ៊ីចឹងទៅ យកមកដាំទៅមានល្អក់អ៊ីចឹងទៅ ខ្លះទៅអីទៅ។ ហើយបើអ្នកខ្លះស្រែកខ្លាំងមានទឹកអីក្រឡុកណា ក៏ខ្ញុំអត់ដឹងដែរយ៉ាងណាម៉េច គេផឹកឬក៏អី ខ្ញុំអត់យល់។ តែខ្ញុំ ខ្ញុំព្យាយាមញ៉ាំទឹកក្តៅ ខ្ញុំខ្លាចឈឺ តែពុះមិនពុះយ៉ាងម៉េច នាងខ្ញុំអត់ដឹង នាងខ្ញុំដងមកទុក។ ហើយមកកន្លែងគេងមានគេដាំនៅរោងហ្នឹងដែរ ជួនទៅដាំទៅដណ្តើមគ្នាអស់ក៏អស់ទៅ។

**ស៖** ចុះស្ថានភាពអនាម័យយ៉ាងម៉េចដែរ តើពេលហូបចុកហ្នឹងស្អាត ឬក៏មានរុយមានសត្វល្អិតអីដែរ?

**ឆ៖** ពេលកន្លែងបរិភោគហ្នឹង វាមិនស្អាតទេ យើងមានទឹកទេ យើងដាក់ចាននៅនឹងក្រោមទៅបើមានចំបើង ឬស្លឹកឈើអី យើងទ្រាប់ចានយើងទៅ។ បើពេលណាភ្លៀងវិញ ជួនកាល – បើសិនមិន

មែនកន្លែងហ្នឹងទេណា៎ កន្លែងផ្សេងទេណា៎ ការដ្ឋានផ្សេងភ្លៀង គឺវាយើងញ៉ាំអ៊ីចឹង។ ហើយអាទឹកអាចានហ្នឹងវាមានអីស្អាត គគ្រិចទាំងអស់ហ្នឹង មានសាប៊ូមានអីលាងទេ។

**ស៖** ចាស អរគុណ។ ពាក់ព័ន្ធទៅនឹងអំឡុងពេលដែលកំពុងតែធ្វើការនៅទំនប់នោះ តើប្រជាជនគាត់មានសិទ្ធិនិយាយស្តី ជជែកគ្នាលេងធម្មតា ហើយគាត់ ពេលដែលហត់នឿយគាត់ចង់សម្រាកដោយខ្លួនឯង គាត់អាចអង្គុយសម្រាកបាន ឬក៏យ៉ាងណាដែរស្ថានភាពពេលនោះ?

**ឆ៖** មិនអាចសម្រាកចិត្តខ្លួនឯងបានទេ បើយើងសម្រាកគេជិតហ្នឹងគេហត់ដូចគ្នាដែរ គេទារសម្រាក អ៊ីចឹងមិនសម្រាកទាំងអស់គ្នា គេមិនអាចឲ្យបានទេ គេមានម៉ោងពេលឲ្យយើងសម្រាក។ ហើយពេលនិយាយស្តី មិនអាចនិយាយជាក្រុមច្រើនបានទេ អត់បាននិយាយអីច្រើនជាមួយទេ ហើយក៏អត់បានលេងសើចអីច្រើនដែរ គេមិនឲ្យ -- និយាយទៅដូចជាគេហៅថាដាំដើមគ យើងនិយាយអីតែមិនស្រួល យើងមានបញ្ហា អ៊ីចឹងអត់ហ៊ាននិយាយអីច្រើនទេ។

[១១:០២:១៣]

**ស៖** ចង់សួរបញ្ជាក់លោកស្រីទាក់ទងទៅនឹងការកំណត់អំពីផែនការដែលត្រូវធ្វើ។ តើអ្នកណាជាអ្នកវាស់ចែកកំណត់ ដីដែលត្រូវជីកដែលត្រូវរែកហ្នឹង? ហើយបន្ទាប់ពីធ្វើហើយហ្នឹង តើអ្នកណាជាអ្នកត្រួតពិនិត្យមើល ថាតើធ្វើហើយត្រឹមត្រូវដែរឬទេ?

**ឆ៖** មានតំណាងឲ្យពួកខ្ញុំស្រុកព្រែកប្រសព្វ ខ្ញុំចាំប្រធានដែលក្នុងការដ្ឋានហ្នឹងឈ្មោះ សៀង ឈ្មោះ ពូសៀង ខ្ញុំនៅចាំខ្លះ។ ហើយគាត់ហ្នឹងអ្នកវាស់វែង ដែលស្រុកព្រែកប្រសព្វយើងប៉ុន្មានម៉ែត្រអ៊ីចឹងៗទៅ នែ៎សង្កាត់ឫស្សីកែវ សង្កាត់ចំបក់ សង្កាត់ជ្រោយអំពិល សង្កាត់អ៊ីចឹងតៗគ្នាអ៊ីចឹងទៅ អ្នកណាធ្វើអ៊ីចឹងទៅ។ ប៉ុន្តែដល់ពេលហើយ គាត់ហ្នឹងគាត់ជួយមើលកុងត្រូល គេវាស់គេវែងអីអ៊ីចឹងទៅណាថា បាតប្រឡាយហ្នឹងប៉ុន្មានម៉ែត្រអីអ៊ីចឹង ទំនប់លើកប៉ុន្មានម៉ែត្រអ៊ីចឹង។ ហើយក្រោយមកទៀតមានអ្នកណាពីលើទៀត ខ្ញុំដូចជាមិនសូវដឹងដែរ ខ្ញុំក្មេងអាចដឹងតែរែកច្រើនជាង តែខ្ញុំគ្រាន់តែចាំថាតែប៉ុណ្ណឹង ឈ្មោះអ្នកមើលខុសត្រូវពួកខ្ញុំ។

**ស៖** លោកស្រីចាំទេថាឈ្មោះ សៀង ហ្នឹងគាត់ជាប្រជាជន ឬក៏ជាមេក្រុម មេកង មេពួកអីដែរ?

**ឆ៖** គាត់ហ្នឹងគឺជាប្រជាជនចេញពីភូមិក្នុងស្រុកព្រែកប្រសព្វដែរ ប៉ុន្តែខ្ញុំមិនដឹងគាត់នៅភូមិណាទេ។ ប៉ុន្តែជាប្រជាជនទេ តែគេតាងគាត់ជាប្រធានកងមើលខុសត្រូវពួកខ្ញុំ មួយស្រុកព្រែកប្រសព្វ។

**ស៖** ចុះអ្នកណាជាអ្នកសម្រេចថា ការងារហ្នឹងឥឡូវហើយៗប៉ុណ្ណឹង ឥឡូវយើងបន្តទៅធ្វើនៅកន្លែងថ្មី ឬកន្លែងខាងមុខមួយទៀតហ្នឹង អ្នកណាជាអ្នកប្រាប់ អ្នកណាជាអ្នកកំណត់?

**ឆ៖** ប្រហែលជាលោក សៀង ហ្នឹងហើយ ៗគាត់ពាក់ព័ន្ធជាមួយខាងណាទៀត ខ្ញុំអត់យល់ដែរកន្លែងហ្នឹង។ ខ្ញុំដឹងតែគេថា ទៅទៀតៗទៅ ពូសៀង ថាហើយៗ ធ្វើបានត្រឹមត្រូវ អ៊ីចឹងទៅទៀតទៅ។ ជួនទៅបង្ហើយអ៊ីចឹង ទាំងយប់លើសម៉ោងក៏មានដែរ អាចអ៊ីចឹង។

**ស៖** ចាស សូមអរគុណ។ នៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅទំនប់១មករាហ្នឹង តើលោកស្រីមានដឹង ឬសង្កេតដោយផ្ទាល់ថា ពេលដែលធ្វើការហ្នឹងមានឃើញបាត់មនុស្សទេ? បាត់ហ្នឹងមានន័យថា ទៅហើយ អត់មានដែលឃើញត្រឡប់មកវិញ។

[១១:០៥:០៨]

**ឆ៖** ពេលបាត់ហ្នឹង ដូចគេថា កន្លែងភូមិ ឬក៏នៅតាមភូមិ ឬក៏កន្លែងការដ្ឋានផ្សេង គេត្រូវយកមនុស្សទៅធ្វើការហ្នឹង គេនៅការងារហ្នឹងគេសម្រុកខ្លាំងអ៊ីចឹងទៅ ដូចជាបាត់ដែរ តែនាងខ្ញុំអត់បានទៅសួរនាំ គ្រាន់តែឮបងៗខ្សឹបគ្នាថា គេដកប៉ុន្មាននាក់អីទៅអីអ៊ីចឹងណ៎ា តែអត់ដែលឃើញមកវិញទេ ឲ្យជួយការងារតាមភូមិ ឬការដ្ឋានផ្សេងអ៊ីចឹងណ៎ា។ ខ្ញុំនៅតូច ខ្ញុំបានតែស្ដាប់គេប៉ុណ្ណឹង។ អាហ្នឹងដឹងហើយបាត់អ្នកនេះខ្ញុំដឹងដែរ តែជាមិនដឹងជាគេទៅណា ក៏យើងមិនដឹងដែរ។

**ស៖** ចាស អរគុណ។ ចុះនៅក្នុងអំឡុងពេលលោកស្រីធ្វើការហ្នឹងមានដែលសង្កេតឃើញមានបងប្អូនខ្មែរអ៊ីស្លាមធ្វើការជាមួយគ្នា ឬក៏ដឹងថាមានពួកគាត់នៅកន្លែងហ្នឹងដែរទេ?

**ឆ៖** មាន ខ្មែរអ៊ីស្លាមគេជម្លៀសមកនៅក្នុងភូមិ ជាមួយភូមិពួកខ្ញុំអ៊ីចឹង ក៏មានគេធ្វើការជាមួយគ្នាដូចខ្មែរយើងអ៊ីចឹង។ ធម្មតា ដូចគេអត់ប្រកាន់ថាអី ធ្វើដូចគ្នា។ ត្រូវមក១មករា ដូចជាមានខ្មែរអ៊ីស្លាមមកដែរ ម្នាក់ពីរនាក់អីអ៊ីចឹង យើងទៅណេះអ៊ីចឹងលាយគ្នាអ៊ីចឹង ធម្មតាដូចតែយើងអ៊ីចឹង។

**ស៖** ចុះការហូបចុករបស់ពួកគាត់យ៉ាងម៉េចដែរ ដូចគ្នានឹងប្រជាជនធម្មតា ឬក៏មានការគោរពបែងចែកការហូបចុករបស់ពួកគាត់ដែរ?

[១១:០៦:៣៩]

**ឆ៖** ពិបាកដែរពួកចាម គាត់អត់ហូបសាច់ជ្រូក។ ដល់ពេលជួនកាលសម្លសាច់ជ្រូកអ៊ីចឹងទៅមានគេទឹកត្រី គេចាក់ឲ្យតិចទៅ អំបិលអ៊ីចឹងទៅ អាចគ្នាក្រៅអីអ៊ីចឹងណ៎ាបន្តិចបន្តួចអ៊ីចឹងទៅ សុំក្រៅ។ ខ្ញុំអត់សួរដឹងចាម ដឹងតែពេលញ៉ាំ ជួនកាលញ៉ាំជាមួយចាមអ៊ីចឹង ចាមគេអត់ញ៉ាំសាច់ជ្រូកអ៊ីចឹងទៅ គេ

ញ៉ាំទឹកត្រី ឬក៏គេមានស្អីគេទៀត ខ្ញុំអត់ដឹងដែរ តែគេអត់ដែលធ្វើម្ហូបសម្រាប់ចាមទេ អត់មានទេ។ តែបើអាកំប៉ិកកំប៉ុក ទឹកត្រីអំបិលអីក្រែងលោគេមាន ទឹកជ្រក់ត្រសក់អីអ៊ីចឹងទៅ គេអាចលាក់ទុក ខ្ញុំអត់ដឹងដែរ។

**ស៖** ចាស អរគុណ។ ត្រឡប់ចូលមកដល់ប្រធានបទមួយ ដែលទាក់ទងទៅនឹងបងស្រីរបស់លោកស្រី។ នៅក្នុងឯកសារដែលលោកស្រីបានផ្តល់ឲ្យមកតុលាការ គឺឯកសារ D22/2531 ដែលមាន ERN ជាភាសាខ្មែរ 00552159, ERN ជាភាសាអង់គ្លេសមានលេខ 01063843 និងERN ជាភាសាបារាំងមានលេខ 01095759។ នៅត្រង់នោះលោកស្រីបាននិយាយរៀបរាប់អំពីបងស្រីលោកស្រី ដែលត្រូវគេបង្ខំឲ្យរៀបការ លោកស្រីបាននិយាយថា ខ្ញុំដកស្រង់៖ “នៅដើមឆ្នាំ១៩៧៧ ពួកវាបានបង្ខំឲ្យបងស្រី អាយុ១៦ឆ្នាំឲ្យរៀបការជុំគ្នា២១គូ”។ ខ្ញុំចង់សួរលោកស្រីថា តើពេលដែលគេបង្ខំបងស្រីលោកស្រីរៀបការហ្នឹង លោកស្រីនៅទីណាដែរពេលនោះ?

[១១:០៨:៣៧]

**ឆ៖** ពេលនោះនាងខ្ញុំនៅភូមិ។

**ស៖** ភូមិ ឃុំអ្វីដែរ?

**ឆ៖** ភូមិឃុំឫស្សីកែវលើ នៅផ្ទះ។ នៅភូមិឫស្សីកែវលើ ស្រុកព្រែកប្រសព្វហ្នឹង នៅជាមួយឪពុកម្តាយ ជាមួយបងទាំងអស់គ្នា។

**ស៖** ចាស អរគុណ។ តើបងស្រីលោកស្រីមានឈ្មោះអ្វីដែរ បើលោកស្រីអាចបញ្ជាក់ប្រាប់បានទេ?

**ឆ៖** បងស្រីនាងខ្ញុំឈ្មោះ លី ស៊ីវយ៉េន។

**ស៖** ហើយពេលនោះ លោកស្រីបានបញ្ជាក់ថា មានការបង្ខំឲ្យរៀបការ។ សូមលោកស្រីបញ្ជាក់អំពីស្ថានភាពពេលនោះ ថាតើអ្នកណាមកប្រាប់ រៀបចំយ៉ាងម៉េច ហើយស្ថានភាពពេលនោះ វាកើតឡើងដោយរបៀបណាដែរ?

[១១:០៩:៤៥]

**ឆ៖** ពេលនោះគេហៅប្រជុំពេលយប់ នាងខ្ញុំទៅប្រជុំទាំងអស់គ្នាហ្នឹង។ ដល់ប្រជុំហើយ គេថាអង្គការដាក់ពីលើមកឲ្យមានគូស្រករអីអ៊ីចឹង។ ហើយនាំគ្នាឆ្ងល់ គេថាអ្នកមានគូស្រករហ្នឹងមានឈ្មោះហើយ ពេលប្រជុំហើយ ឲ្យពួកអ្នកដែលនេះត្រឡប់ទៅផ្ទះវិញ អ្នកមានគូ -- អ្នកមានឈ្មោះនៅហ្នឹង

សិន។ ដល់ហើយគេប្រកាសឈ្មោះ ហើយក៏អត់ដឹងគូជាមួយអ្នកណាដែរ អត់ទាន់ដឹងទេ។ ដល់ប្រកាសឈ្មោះទៅ ខ្ញុំក៏អត់ទៅផ្ទះ ខ្ញុំនៅជាមួយបងខ្ញុំចាំមើល ដល់ហើយមួយៗឆ្លល់សួរទៅ ក៏គេប្រាប់ទាំងយប់នេះ អ្នកនេះគូជាមួយអ្នកនេះ អ្នកនេះគូជាមួយអ៊ីចឹងទៅ។ ក៏ម៉ាក់ខ្ញុំដឹងទៅ ក៏ខ្ញុំរត់ចុះរត់ឡើងអ៊ីចឹង នៅតូចនោះ ប្រាប់អ៊ីចឹងទៅ។ ម៉ាក់ខ្ញុំគាត់ព្រឹកឡើងអីៗ ខ្ញុំអត់ដឹងដែរ រឿងគាត់ចាស់ៗ ខ្ញុំទៅធ្វើការបាត់ទៅ បែបគាត់ទៅប្រាប់គេហើយ។ គាត់ថា បងអត់ទាន់ចង់ឲ្យបងរៀបការ ព្រោះគាត់នៅក្មេងពេក អត់ដឹងអ៊ីចឹង ហើយគាត់ថាមានគូមានអ៊ីចឹងទៅ។ គេថាគេឲ្យធ្វើអីធ្វើហ្នឹងទៅ កុំឲ្យយើងរឹងទទឹងណ៎ា រឹងទទឹងទៅក្រែងលោ ម៉េចទៅខ្ញុំអត់យល់ដែរ។ អាហ្នឹងដូចពាក្យគេថា "កង់ប្រវត្តិសាស្ត្រកំពុងតែវិល យើងមកខ្ទាស់គេ ប៉ះដៃៗហើយ ប៉ះជើងៗហើយ" គឺខ្ញុំចង់និយាយអ៊ីចឹងទៅណ៎ា។ ហើយបើយើងរឹងជាមួយអង្គការ ដល់អ៊ីចឹងក៏បងខ្ញុំសម្រេចចិត្តការ ពេលហ្នឹងក៏អត់មានអ្នកណាប្រកែកបាន ការទាំងអស់គ្នា។ តែគេអត់មានការអីទេ គេចុះមកប្រជុំអ៊ីចឹង នេះខ្ញុំសួរបងខ្ញុំទេណា ខ្ញុំគេអត់ឲ្យចូលទេ។ គេប្រកាសឈ្មោះទៅថា បងខ្ញុំ លី ស៊ីវយ៉េន អ៊ីចឹងជាមួយប្ដីគាត់ឈ្មោះ គឹម ឆាត។ តែប្ដីគាត់ហ្នឹងពីមុនក៏ធ្លាប់អតីតខាងពីឡូត ឬខាងអីកំពុងរៀននៅភ្នំពេញដែរណ៎ា គាត់ដូចជាបញ្ញវន្តអ៊ីចឹងនិយាយទៅ ខ្ញុំអត់សូវនេះច្បាស់ដែរ។ ហើយដល់ពេលហើយ គេហៅឈ្មោះមួយគូៗអ៊ីចឹងគ្រប់២១គូ ហើយគេចែកខោអាវ ចែកកន្ទេល ចែកមុង ភួយ។

[១១:១១:៤៣]

**ស៖** តើបងស្រីលោកស្រីមានប្រាប់លោកស្រីទេថា គាត់ពេញចិត្តរៀបការ ឬក៏គាត់មិនពេញចិត្តទេក្នុងការរៀបការហ្នឹង?

**ឆ៖** ពេលហ្នឹងបងស្រីខ្ញុំថាអត់ការទេ អត់ការ ប្រាប់ខ្ញុំថាអត់ការទេ ហើយមនុស្សអត់ស្រឡាញ់គ្នាផងចាប់ការ ហើយពូហ្នឹងគាត់នៅជាប់ផ្ទះខ្ញុំ។ រួចខ្ញុំបង្ខំគាត់ថា បងៗឯងការទៅ បាននៅភូមិ នៅជាអ្នកវ៉ៃយកណ្ដាលជាមួយម្ដាយឪពុកអ៊ីចឹងទៅណា។ បងខ្ញុំថា អត់ទេ អត់ការ ប្រកែករហូត ហើយទៅគេចាប់ការ គាត់ក៏ការទៅ។

**ស៖** ចុះក្រោយមកទៀតមានរឿងអ្វីកើតឡើងចំពោះបងស្រីរបស់លោកស្រី?

**ឆ៖** នៅពេលដែលគាត់ការរួច ខ្ញុំចាំប្រហែលជាខ្ទង់ខែ២ តាមមើល ខ្ញុំៗចេញទៅទំនប់១មករាហ្នឹង ប្រហែលជាដើម -- ខ្ញុំចាំអត់ច្បាស់ដែរកន្លែងហ្នឹង។ ខ្ញុំចេញទៅ ដល់ខ្ញុំចេញទៅខ្ញុំត្រឡប់មកវិញ ខ្ញុំឃើញ គេបង្អត់បាយបងខ្ញុំ អត់មានធ្វើអី អត់មានបានអីទាំងអស់។ ហើយបងខ្ញុំ ពេលហ្នឹងគាត់ដូចជា

មានទម្ងន់១ខែ ឬក៏អីទើបដែរដំបូងណ៎ា តែឮសួរម៉ាក់ខ្ញុំគាត់ថា ប្រហែលជា -- វាអត់ត្រូវគ្នាពីរបីខែហើយ ថាអត់ត្រូវចុះដំណេកអីម៉េចហ្នឹង ប៉ុន្មានខែខ្ញុំអត់ដឹងដែរថា តាំងពីការមកវាអត់ វានៅគេងជាមួយគ្នាអីចឹង តែវាអត់នៅជាមួយគ្នាអីអីចឹងណ៎ា។ ដល់ពេលអីចឹង ក្រោយមកគាត់ទៅធ្វើការដូចគាត់មានបែបមានទម្ងន់ម៉េច គេរករឿងពេកទៅ ក៏គាត់នៅ គេថាគេតាមដាន យប់ឡើងគេតាមដានតាមផ្ទះ យើងមិននៅអីអីចឹង ខ្លាចគេរករឿង។ ដល់ពេលហើយ ក៏គាត់ស្រឡាញ់គ្នា ត្រូវគ្នាទៅ គាត់ដូចជាការបាត់ដំបូងៗដូចគាត់ចាញ់អីចឹង។ ហើយឮសួរថា -- ខ្ញុំអត់ដឹងថា -- ខ្ញុំអត់បានសួរម្ដាយខ្ញុំច្បាស់ថា គេបង្អត់គាត់ពេលណាទេ។ មកដល់ខ្ញុំឮ ហើយខ្ញុំធ្លាក់ថ្លើមក្ដុកទៅ ខ្ញុំដឹងថាហេតុអីក៏អីចឹងៗ ខ្ញុំខឹងគាត់ណាស់ហេតុអីក៏ឲ្យទៅជា គេមិនឲ្យរបបអីចឹង បងអី -- បងខ្ញុំបានអីហូប។ ពេលនោះខ្ញុំឈឺ ខ្ញុំមកវិញខ្ញុំឈឺ ខ្ញុំក្ដៅខ្លួនខ្លាំងណាស់ គេឲ្យមកផ្ទះបាន៣ថ្ងៃ។

[១១:១៤:០៩]

**ស៖** ក្នុងឯកសារដដែលដែលខ្ញុំបានលើកមុននេះ លោកស្រីថាបងស្រីលោកស្រីមានទម្ងន់កូនក្នុងពោះប្រហែលជា៤ខែ ហើយត្រូវគេយកទៅសម្លាប់។ សូមលោកស្រីជួយរៀបរាប់ពីស្ថានភាពពេលនោះយ៉ាងម៉េចដែរ រឿងហេតុនេះ?

**ឆ៖** ពេលនោះគេចុចឈ្មោះឲ្យគាត់ជាមួយប្ដីគាត់ហ្នឹងប្ដូរភូមិ គេឲ្យទៅនៅភូមិផ្សេង។ ដល់ពេលគាត់ -- ដល់ហើយគាត់មានទម្ងន់ខែ៧ហើយ ពេលគាត់ទម្ងន់ហ្នឹង មិនមែនពេលនេះទេណ៎ា ទម្ងន់៤ខែហ្នឹង ខែ៧។ ហ្នឹងខ្ញុំដឹងពីម្ដាយមីងប្រាប់វិញ ខែ៧ ប្រហែលថ្ងៃ២១ដល់២៣ គេទុកឃុំសម្លាប់ហ្នឹង។ ហើយបងស្រីខ្ញុំហ្នឹង ក៏ទៅៗ គាត់មានទម្ងន់ ម្ដាយខ្ញុំគាត់អាណិតៗ បងខ្ញុំទាំងប៉ាអីហ្នឹងថា -- ប៉ាខ្ញុំអត់នៅទេ ប៉ាខ្ញុំទៅធ្វើការនៅដល់បឹងរៃទល់ដែនកំពង់ចាម ជិតស្រុកពាមប្រស្នាអីកន្លែងសម្ដេចហ្នឹង ដល់ពេលហើយគាត់ចាំចម្ការ។ ម៉ាក់ខ្ញុំនេះគាត់ទៅសុំគេថា ចង់ឲ្យបងស្រីខ្ញុំ -- ប៉ុន្តែមុននឹងមានជម្លៀសលើកទីមុនមួយសាដែរ តែមានពូម្នាក់មេកងគាត់ថា “កុំអាលសិន ចាំខ្ញុំត្រឡប់ពី១មករាមកវិញ”។ អីចឹងក្នុងភូមិហ្នឹង គាត់ជម្លៀសម្ដងបន្តិចៗចេញពីភូមិអ្នកចាស់ហ្នឹងទាល់តែអស់ទៅនៅក្នុងព្រៃ កន្លែងចាញ់។

[១១:១៥:៣២]

ពេលហ្នឹងជម្លៀសពេលបងខ្ញុំហ្នឹងទៅ ម៉ាក់ខ្ញុំទៅសុំៗ ហើយឲ្យគេតាមទៅយកប៉ាខ្ញុំមកជុំគ្នាទាំងអស់យកទៅ។ ពេលហ្នឹងខ្ញុំត្រឡប់ពី១មករាមកបាន៣ថ្ងៃ ខ្ញុំត្រូវចេញទៅធ្វើការនៅ – មានស្ទឹងមួយធំគេហៅបឹងធំ នៅក្រោយហ្នឹងប្រហែលជាភូមិកោះស ស្ទឹងទ្រ ស្ទឹងធំអីហ្នឹង។ ពេលហ្នឹងខ្ញុំអត់ដឹងទេ

ហើយគេតាមយកតែប៉ា រួចពួកហ្នឹងគេដឹងអ៊ីចឹង គេអត់ឲ្យទៅតាម។ ខ្ញុំថាមានទូកណា អុំទៅយកខ្ញុំ ឆ្ងាយឆ្លងទៅច្រើនគីឡូដែរ។ ដល់អ៊ីចឹងបងស្រីខ្ញុំក៏ទៅ ទៅពេលហ្នឹងគេប្រមូលអីវ៉ាន់អីទាំងអស់ យក ទាំងម្ដាយ ទាំងឪពុកខ្ញុំហ្នឹងប្រមូលយកទៅ ទាំងប្រជាជនច្រើនគ្នាណាស់ ច្រើនណាស់ ហើយយកឡាន អាឡានយើងហ្នឹងឃ្លុបៗហ្នឹងណ៎ា ដាក់ក្នុងឡាន បិទអស់ឲ្យដឹងថា ចេញពីណាទៅណាទេ យកទៅដាក់ នៅភូមិ -- គេហៅថា សាលាចិននៅក្នុងចំបក់ហ្នឹង។ ហើយប្រមូលខោអាវ មាសពេជ្រ របស់របរដោះ ចេញ មានប៉ុន្មានស្អីទុកម្ដុំទាំង អស់ឲ្យទៅតែខ្លួនទេ។ ពេលហ្នឹងបងស្រីខ្ញុំគាត់ៗពាក់ពីរជាន់ អាវពីរជាន់ ណ៎ា។ ខ្ញុំអត់បានឃើញតែបានដំណឹងពី បងសៀង ត្រូវបងថ្លៃ អ៊ិន យ៉េង អ្នកចម្រៀងប្រាប់ខ្ញុំពេល ក្រោយមកៗភ្នំពេញវិញនេះ។ គាត់ថា បងខំ -- គាត់កងចល័តដើរកាត់តាមភូមិហ្នឹងមក គេឲ្យគាត់ ចេញពីភូមិមួយទៅភូមិមួយ ធ្វើការពីការដ្ឋានមួយទៅការដ្ឋានមួយ គាត់ដើរមកគាត់ឃើញ គាត់ថាៗ "គេយកទៅអស់ហើយ នៅបងអ្អែងមួយក្រោយគេហ្នឹង ហើយម៉ាក់អ្អែងអង្គុយឱបប្អូន" ថាម៉ាក់ខ្ញុំអង្គុយ ឱបប្អូនខ្ញុំ ហើយប្អូនខ្ញុំប្រហែលជា៧ឆ្នាំ ៨ឆ្នាំទេ។ ហើយបងស្រីខ្ញុំហ្នឹង វាចាប់ប្រទាញបងស្រីខ្ញុំឲ្យ ស្រាតខោអាវចេញក្រៅឲ្យអស់ប្រមូល បងស្រីខ្ញុំគាត់មានខោអាវតិច គាត់ធ្វើដេរទុកឲ្យកូននោះ ទាញ គ្នាហ្នឹង ហើយក៏បងគាត់មើលថា យកកាំភ្លើងវ៉ៃបងខ្ញុំយកអីវ៉ៃបងខ្ញុំហ្នឹង ហើយអូស។ គាត់ថា អាណិត បងអ្អែងណាស់ ហើយគាត់ឈរមើលសកម្មភាពធ្វើហ្នឹងណ៎ា។ ហើយដល់ពេលហើយដាក់បងខ្ញុំបញ្ជូន ឡានទៅ ម្នាក់មានតែមួយចង្កេះៗទេ យកទៅញាត់នៅវត្តជ្រោយអំពិល ទម្លាក់នៅវត្តជ្រោយអំពិលទី១ នោះ ទី១ ទី២ នៅជើងភ្នំសុពណ៌កាឡីហ្នឹង។

[១១:១៧:៣៤]

ដល់យកទៅហ្នឹង គេដាក់ឃុំៗ គេសម្លាប់ស្រីៗមុន ក្មេងមុន គេទុកប្រុសៗមានកម្លាំងគេដាក់ក្នុង វិហារ គុហារៗ ហើយបិទបង្អត់បាយ។ បង្អត់បាយពេលហ្នឹងគេសម្លាប់៣ថ្ងៃ គេចាក់មីក្រូគ្រប់ទិញ ពេញហ្នឹងទាំងអស់ ទ្រហឹងអឺងអាប់ គ្មានអ្នកស្រុកណាឮសំឡេងទេ។ តែមីងខ្ញុំគាត់នៅជិតភូមិសម្លាប់ ហ្នឹង គាត់អត់សម្រាន្តទេ គាត់នៅលបស្ដាប់ឮល្វើយៗ "អ៊ុយ!" គាត់ឮសូរ។ ទាស់ ទុំ គាត់បានមកដាក់ ពាក្យបណ្ដឹងដែរហ្នឹង តែគាត់នៅជិតភូមិ ហើយខ្ញុំអត់ដឹងទេ ខ្ញុំនៅក្នុងព្រៃនោះ។ ហើយពេលហ្នឹងបង មួយ បងសៀង ហ្នឹងគាត់តាំងពីឃើញមក គាត់កើតអាជំងឺដូចជា សរសៃប្រសាទ ដូចឆ្កួតដូចអីអ៊ីចឹង គាត់សម្រាន្តនៅវត្តចំបក់ គេលើកជើងគាត់ឡើងអី តែគាត់អត់បាននិយាយប្រាប់មីងខ្ញុំទៀត។ ហើយខ្ញុំក៏ អត់ដឹងរឿង ទើបតែដឹងនៅពេលបែកភ្នំពេញនេះ ជួបគាត់មួយភ្លែតនៅច្បារអំពៅ។ ហើយថា -- ខ្ញុំអត់

ដឹងទេ គេលាក់នឹងខ្ញុំរហូត។ បើសិនជាខ្ញុំដឹងពេលនោះ គេមានគេអ្នករទេះហ្នឹង គេសួរថា ពេលមកប្រជុំវិញ ពេលក្រោយមកគេប្រជុំ គេសួរថា អ្នកណាមានម្តាយឪពុកយកទៅសម្លាប់អ៊ីចឹង ឲ្យលើកដៃ គេនឹងយក -- មិនយកទៅសម្លាប់ទេ គេជម្លៀសចេញពីភូមិហ្នឹង គេទៅតាម។ ហើយអ្នកស្រុកហ្នឹង ខ្ញុំសួរគេថា គេអាណិតខ្ញុំ គេថាអត់មានទេ ម៉ាក់អ្នែងនៅភូមិហ្នឹងទេ។ ខ្ញុំលាក់រឿងហ្នឹងរហូត ដល់ចុងក្រោយ ខ្ញុំទៅដល់ការដ្ឋានមួយគេហៅ រលំព្នៅ។

[១១:១៩:០៥]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោកស្រី។ ដោយសារពេលវេលា លោកប្រធានខ្ញុំសូមបន្តវេទិកានេះ ឲ្យទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអរគុណលោកប្រធាន សូមអរគុណលោកស្រី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រីសាក្សី ខ្ញុំចង់ឲ្យលោកស្រីបញ្ចប់ទៅលើអ្វីដែលលោកស្រីចង់និយាយ។ លោកស្រីបាននិយាយអំពីមរណភាពរបស់បងស្រីលោកស្រី។ តើមានសមាជិកគ្រួសាររបស់លោកស្រីដទៃទៀតនៅជាមួយបងស្រីរបស់លោកស្រីដែរឬទេ នៅពេលនោះ? ហើយតើពួកគាត់មានអ្វីកើតឡើងដែរ?

[១១:១៩:៥៤]

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ពេលនោះមានប៉ាខ្ញុំ មានម្តាយខ្ញុំ ប្អូនខ្ញុំ ទាំងអស់រលីង នៅសល់តែនាងខ្ញុំម្នាក់គត់ដែលនៅឆ្ងាយ គេទៅយកមិនទាន់។ នាងខ្ញុំកាលហ្នឹងនៅតូចណាស់។ ខ្ញុំអាណិតគាត់ចាស់ៗពីរនាក់នោះ។ ពេលខ្ញុំទៅហ្នឹង ខ្ញុំក្តៅខ្លួន គាត់ថាកុំឲ្យកូនទៅឲ្យកូននៅផ្ទះវិញ ខ្ញុំអត់ព្រម ទារចេញ។ ខ្ញុំស្លាប់ជាមួយគាត់ទាំងអស់ប្រហែលជាខ្ញុំផុតទុក្ខហើយ ខ្ញុំរស់នៅ ខ្ញុំពិបាកជាងស្លាប់ទៀត។

**ស៖** សូមអរគុណលោកស្រី។ នៅពេលដែលលោកស្រីត្រូវការពេលវេលា លោកស្រីអាចផ្អាកបន្តិចសិន ហើយប្រាប់ខ្ញុំនៅពេលដែលលោកស្រីអាចបន្តទៅមុខទៀតបាន។

**ឆ៖** ចាស នាងខ្ញុំបន្តបាន។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី -- សាក្សីទី១ ដែលមកផ្ដល់សក្ខីកម្មទាក់ទងទៅនឹងទំនប់១មករា គាត់គឺជាមេភូមិ ដែលគ្រប់គ្រងការដ្ឋាននៅទំនប់១មករា ហើយគាត់ប្រាប់ថាប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី គឺទទួលបានប្រព្រឹត្តដូចៗគ្នា មិនខុសគ្នាទេ។ តើលោកស្រីអាចផ្ដល់មតិ ឬក៏បញ្ចេញមតិទាក់ទងទៅលើចំណុចនេះបានដែរឬទេ?

[១១:២២:១០]

**ឆ៖** ចាស បាទ។ ធ្វើការដូចគ្នា ក៏ប៉ុន្តែប្រជាជនថ្មីគ្មានសិទ្ធិទេ ដូចអ្នកទោសអ៊ីចឹង ដូចជាសត្រូវហើយពួកប្រជាជនមូលដ្ឋានហ្នឹងគេលើកអ្នកដែលជនក្រីក្រ ឬក៏មានចែកជាពីរហ្នឹងមកកាន់អំណាច គឺធ្វើបាបពួកខ្ញុំ។ អ្នកថ្នាក់លើគាត់មិនស្គាល់មុខពួកខ្ញុំ តែពួកក្រោមនេះធ្វើបាបពួក១៧មេសា។ ចាំតែបន្តិចទៀត ពួក១៧មេសាស្លាប់ទាំងអស់ ហើយហាក់ដូចជាគ្នាសត្រូវអី ដូចទុកពួកខ្ញុំហ្នឹងជាសត្រូវស្លូពូជជាមួយនឹងពួកគាត់។ ធ្វើអីក៏ខុសៗ។

**ស៖** សូមអរគុណ។ ខ្ញុំចង់បញ្ជាក់បន្តិចអំពីឪពុករបស់លោក។ ខ្ញុំយល់មិនច្បាស់អំពីឋានៈរបស់គាត់។ តើគាត់ជាយោធា ឬក៏ជាអ្នករដ្ឋការ? តើគាត់ជានាយទាហាន ឬក៏ជាអ្នករដ្ឋការដែរ? លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** គាត់ជាទាហាន។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកស្រីដែលបានមកផ្ដល់សក្ខី-កម្មនៅទីនេះ ហើយខ្ញុំចង់សួរបន្តិចទៀតទាក់ទងទៅនឹងបទពិសោធន៍៣ខែនៅទំនប់១មករា។ ខ្ញុំចង់ឱ្យលោកស្រីពន្យល់ប្រាប់ថាតើការរស់នៅពេលនោះ វាមានលក្ខណៈយ៉ាងដូចម្ដេចដែរ? ខ្ញុំចង់ពិភាក្សាអំពីសិទ្ធិដែលលោកស្រីដែលមាន។ តើលោកស្រីមាន អាចថាមានសិទ្ធិត្រឡប់មកផ្ទះ ត្រឡប់មកភូមិនៅពេលយប់បានឬទេ? ឬក៏តើលោកស្រីអាចទៅណាមកណាបានតាមចិត្ត ឬក៏អាចធ្វើដំណើរដោយសេរីបានដែរឬទេ?

[១១:២៤:១០]

**ឆ៖** ពុំអាចធ្វើដំណើរតាមចិត្តបានទេ គ្មានសិទ្ធិ។ នៅ៣ខែ ខ្ញុំអត់បានមកផ្ទះទេ។ ទាំងអស់គ្នាមិនមែនតែពួកខ្ញុំទេ។ អ្នកនៅភូមិឫស្សីកែវលើទាំងអស់ អត់មានអ្នកណាបានត្រឡប់មកផ្ទះ ទាល់ដល់គ្រប់គម្រប់៣ខែ។

**ស៖** តើលោកស្រីអាចធ្វើពិធីបុណ្យសាសនា ដូចជាបុណ្យព្រះពុទ្ធសាសនា ឬក៏ដូចជាថា

ជនជាតិចាមអាចគោរពតាមជំនឿសាសនារបស់ពួកគាត់បានដែរឬទេ នៅពេលនៅការដ្ឋាននោះ?

**ឆ៖** អត់មានទេ អត់មានៗវត្ត អត់មានអ្វីទាំងអស់ ហើយក៏គោរព ក៏អត់មានដឹងដែរ តែពេលគេងប្រហែលស្ងាត់ៗ គេលួចគោរពអត់ដឹង តែបើកចំហាគឺអត់មាន។

**ស៖** តើលោកស្រីមានសិទ្ធិនិយាយដោយសេរីបានដែរឬទេ? តើលោកស្រីអាចជជែកជាមួយមិត្តភក្តិដោយសេរី ឬក៏លោកស្រីអាចតវ៉ានៅក្នុងការប្រជុំទាមទារបន្ថយម៉ោងការងារអ្វីបានដែរឬទេ?

**ឆ៖** មិនអាចតវ៉ាទាមទារម៉ោងពេលការងារអត់បានទេ តែនិយាយមួយមិត្តភក្តិនិយាយបាន បើនិយាយឲ្យច្រើនអត់បានទេ និយាយបានតិចៗ និយាយច្រើនអត់បានទេ។

**ស៖** នៅក្នុងកងរបស់លោកស្រី ថាតើកងលោកស្រីទាំងអស់សុទ្ធតែជានារី ដែលធ្វើការនៅទំនប់១មករាហ្នឹង? តើកងលោកស្រីជាកងនារីឬ?

[១១:២៦:២១]

**ឆ៖** កងនាងខ្ញុំមានបុរសដែរ មាននារីលាយគ្នា ចាម ខ្មែរ ចិន ទាំងអស់។

**ស៖** តើគេអនុញ្ញាតឲ្យគ្រួសារនៅជាមួយគ្នាដែរឬទេ? ឧទាហរណ៍ដូចជាប្ដីប្រពន្ធអាចស្នាក់នៅជាមួយគ្នា ហើយនៅជាមួយកូនអីបានដែរឬទេ?

**ឆ៖** នៅការដ្ឋាន ពួកខ្ញុំអត់មានអ្នកមានប្ដីប្រពន្ធទៅផង សុទ្ធតែនៅលីវ ខ្ញុំអត់ឃើញមានដឹងផងនៅហ្នឹង។

**ស៖** តើនៅពេលនោះ លោកស្រីអាចមានសិទ្ធិថា ចង់ធ្វើការ ឬក៏មិនចង់ធ្វើការបានដែរឬទេ? ព្រោះលោកស្រីនិយាយថា លោកស្រីសម្រេចចិត្តថាទៅធ្វើការនៅទីនោះថា ប៉ុន្តែចង់ដឹងថាតើលោកស្រីមានសិទ្ធិអាចថា ចង់ឈប់ធ្វើការត្រឡប់មកវិញបានដែរឬទេ?

**ឆ៖** មិនមានសិទ្ធិទេ តែទៅហើយធ្វើទាល់តែចប់បានមានសិទ្ធិមកវិញ។

**ស៖** លោកស្រីនិយាយថា លោកស្រីមកពីស្រុកព្រែកប្រសប់។ ថាតើស្រុកព្រែកប្រសប់ហ្នឹងនៅក្នុងរបបខ្មែរក្រហមស្ថិតនៅក្នុងតំបន់អីដែរ? តំបន់ទីប៉ុន្មានដែរ?

**ឆ៖** ក្នុងភូមិភាគបូព៌ា។ ខ្ញុំអត់ដែលដឹងតំបន់ ដឹងថាបូព៌ា។

[១១:២៨:២៣]

**ស៖** តើលោកស្រីអាចរៀបរាប់បានទេ នៅក្នុងកិច្ចប្រជុំដែលកិច្ចប្រជុំលើកដំបូងដែលលោកស្រីនិយាយថា នៅក្នុងកិច្ចប្រជុំហ្នឹងលោកស្រីសម្រេចចិត្តថាទៅទំនប់ហ្នឹង ប៉ុន្តែនៅក្នុងកិច្ចប្រជុំហ្នឹងគេ

និយាយអំពីអ្វីខ្លះ? លោកស្រីអាចរៀបរាប់បានទេ?

**ឆ៖** កិច្ចប្រជុំពេលរៀបចាត់តាំងចេញទៅទំនប់១មករាមែនទេ? គេប្រជុំ គេត្រូវចាត់ឲ្យចូលរួមទូទាំងប្រទេសនៅទំនប់១មករា។ អ៊ីចឹងនៅក្នុងភូមិហ្នឹងគឺត្រូវចូលរួមចំណែកដែរ ប៉ុន្មាននាក់អ៊ីចឹងទៅ ហើយបើអ្នកនៅសល់ប៉ុន្មានហ្នឹងក៏ត្រូវគេឲ្យទៅការដ្ឋានផ្សេង ដូចជានៅក្នុងស្រុកព្រែកប្រសប់ហ្នឹង អ្នកខ្លះទៅឆ្ងាយ ទៅផ្សេងដល់ – មានអ្នកខ្លះទៅដល់ជិតចម្ការលើ យើងខាងស្វាយទាបទៀត តាមខ្ញុំឮ ពេលបែកហើយ។ ហើយអ៊ីចឹងទៅមួយវគ្គៗ នាងខ្ញុំគិតថា នាងខ្ញុំចង់ទៅលើកទំនប់ ព្រោះអីហើយទៅតាមអូរកំបុត អូរអីនោះ គេពិបាកជាងពួកខ្ញុំទំនប់១មករាទៀត។ គេញ៉ាំបបរលាយព្រលិត យកមកពេលជួបគ្នាបាននិយាយថា ពួកខ្ញុំទំនប់១មករាហ្នឹងរាងបានហូបអីគ្រាន់បើជាងពួកនៅភូមិអូរកំបុត រលំធ្នៅ។ បើយើងមិនទៅគង់គេចាត់ទៅ អ៊ីចឹងខ្ញុំសម្រេចថា ទៅខាងហ្នឹង។

[១១:២៩:៥៤]

**ស៖** សូមអរគុណលោកស្រី។ តើមានអ្នកប្រកែកអត់ព្រមទៅដែរឬទេ?

**ឆ៖** ដូចអត់មានអ្នកប្រកែកទេ។ បើសិនជាអ្នកហ្នឹងមានបញ្ហាឈឺ ឬក៏អ្វីគេទុកចាំយកទៅការដ្ឋានមួយទៀតនៅពេលជា។ បើអ្នកប្រកែក អត់មានអ្នកប្រកែកទេ បើមានអ្នកស្ម័គ្រចិត្តមាន។ អត់ហ៊ានទេខ្លាចស្លាប់។

**ស៖** លោកស្រីឮថា ម្ហូបអាហារនៅទំនប់ហ្នឹងវាប្រសើរជាងការដ្ឋានដទៃទៀត ប៉ុន្តែខ្ញុំចង់ដឹងថាក្នុងរយៈពេល៣ខែដែលលោកស្រីនៅទំនប់ នៅការដ្ឋានទំនប់ហ្នឹង លោកស្រីមានម្ហូបអាហារហូបគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** ហូបអត់គ្រប់គ្រាន់ទេ។ ឃ្លាន ហូបអត់គ្រប់ទេ សុទ្ធតែ -- សម្លសុទ្ធតែទឹក។ គ្មានសាច់គ្មានអីទេ។ នៅការដ្ឋានផ្សេងរឹតតែពិបាកជាងហ្នឹងទៀត សុទ្ធតែទឹកបបរ។

**ស៖** នៅក្នុងចម្លើយកន្លងមក គេសួរលោកស្រីអំពីចំណីអាហារ ហើយនិងម្ហូប ហើយលោកស្រីនិយាយថា លោកស្រីបានបាយដំណើប ហើយញ៉ាំល្ពៅជារៀងរាល់១០ថ្ងៃម្តង។ ប៉ុន្តែខ្ញុំចង់ដឹងថា តើលោកស្រីបានរបបបាយដំណើប ហើយល្ពៅហ្នឹងនៅពេលណាដែរ ឬក៏នៅកន្លែងណាដែរ?

**ឆ៖** បើនៅក្នុងការដ្ឋាន។ ឧទាហរណ៍ថា១០ថ្ងៃអ៊ីចឹង គេធ្វើបង្អែម នេះជាបង្អែមទេ គេចែកម្នាក់មួយវែកអីអ៊ីចឹងទៅ បន្តិចៗម្នាក់អ៊ីចឹង។ គេយកពីភូមិដែលយើងនៅភូមិឫស្សីកែវអ៊ីចឹង គេយកពីភូមិ ពីស្រុកយើងហ្នឹង យកមកផ្គត់ផ្គង់ក្នុងការដ្ឋានកន្លែងយើង ភូមិយើងហ្នឹង គ្រប់កន្លែងទាំងអស់ក្នុង

ការដ្ឋាន។

[១១:៣២:០៧]

**ស៖** ខ្ញុំជិតអស់ពេលហើយ ប៉ុន្តែខ្ញុំនៅសល់សំណួរមួយចុងក្រោយទៀត។ នៅពេលដែលលោកស្រីនិយាយអំពីអាយុ គឺលោកស្រីនៅពេលនោះអាយុ១២ឆ្នាំ ប៉ុន្តែនៅពេលអាយុ ១២ឆ្នាំហ្នឹង លោកស្រីមានកម្ពស់ប្រហែលប៉ុន្មានដែរ?

**ឆ៖** នាងខ្ញុំតូច កម្ពស់ប្រហែលជា១,២ម៉ែត្រអី ២តឹក ៣តឹក តូចស្គម នាងខ្ញុំមានរូបថតពេលនាងខ្ញុំ មុននឹងបែកភ្នំពេញ តូច។ ហើយអ្នកដែលបងៗហ្នឹង អង្គុយមើលមុខខ្ញុំហ្នឹង នាំគ្នានិយាយថា "ហេតុតែអូនឯងអាយុវែង ចេះម៉េចបានចេញទៅការដ្ឋាន បើនៅជាមួយឪពុកម្ដាយ ប្រហែលស្លាប់បាត់ហើយ តូចប៉ុណ្ណឹងអ្នកណាគេឲ្យមក។" គេនាំគ្នានិយាយពីខ្ញុំគ្រប់គ្នាពេលបែកមកហ្នឹង។ ហើយខ្ញុំក៏មិននឹកថា ខ្ញុំហ្នឹងទៅធ្វើការទីនោះបាន។ តែខ្ញុំជាក្មេងមិនចេះនៅស្ងៀម ខ្ញុំចូលចិត្តធ្វើការ គីឡូខ្ញុំបើគិតទៅជំនាន់នោះប្រហែលជា ៣០គីឡូអីបន្តិចទេ តូចៗស្គម។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំអស់ពេលហើយ ដូច្នេះសូមអរគុណលោកប្រធាន។ សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

[១១:៣៣:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំ ខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យ

បានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយដំបូងនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុម អ៊្ហ៎! សុំៗ បាទ សូមបង្អង់បន្តិចសិន ចៅក្រមមានសំណួរ។

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរតែមួយទេ ដើម្បីចោទសួរទៅលោកស្រី។ កាលពីព្រឹកមិញនេះ លោកស្រីបានឆ្លើយថា លោកស្រីកត់សម្គាល់ឃើញថា មានការបាត់ខ្លួននៅការដ្ឋានទំនប់១មករា។ តើលោកស្រីអាចជម្រាបបានទេថា ការបាត់ខ្លួនហ្នឹងកើតឡើងញឹកញាប់ទេ? គឺខ្ញុំចង់ដឹងថា តើមានមនុស្សច្រើនទេដែលបានបាត់ខ្លួននោះ?

[១៣:៣២:២៧]

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ចាស នៅពេលដែលធ្វើការជាមួយជិតគ្នានៅភូមិសង្កាត់ នៅស្រុក មិនច្រើនទេ តិចតួចទេច្រើនតែប្រុសៗ។ គេថាប្តូរកន្លែងការងារទីតាំងទៅជួយកន្លែងថ្មី ឬក៏ទៅធ្វើកន្លែងការដ្ឋានចាស់ ឬជួយជាកម្លាំងធ្វើការប៉ុណ្ណឹង តែអីទៀតខ្ញុំអត់បានដឹងទេ ព្រោះអត់ដែលឃើញមកភូមិ ហើយគេហ្នឹងក៏ខ្លះក៏អត់នៅភូមិខ្ញុំ តែច្រើនប្រុសៗ។

**ស៖** អ៊ីចឹងលោកស្រីចាំពីអ្នកដែលបាត់ខ្លួនហ្នឹងទេ? តើអ្នកដែលបានបាត់ខ្លួនហ្នឹងជាអ្នក ១៧

មេសា ឬជាអ្នកមូលដ្ឋាន?

**ឆ៖** ជាអ្នក១៧មេសា។ គាត់ចាស់ៗដូចជាពូៗអ៊ីចឹង ខ្ញុំធ្លាប់ឃើញគាត់អ៊ីចឹងទៅ ដល់ក្រោយមកគេថា គេនឹងប្តូរផ្លាស់ការងារឲ្យទៅជួយកន្លែងថ្មី អ៊ីចឹងទៅ។ បើប្រធានកង ខ្ញុំដូចអត់ដែលឃើញទៅណាទេ នៅដដែល។ ស្រីៗក៏ច្រើននៅហ្នឹងដដែល។ ពេលនោះទើបនឹងចាប់ផ្តើមបន្តិចម្តងទេ ដល់ពេលផុត៧៧ទៅមុខ ហ្នឹងបានបាត់ច្រើន។

**សៈ** កាលពីព្រឹកមិញលោកស្រីបាននិយាយអំពីលក្ខខណ្ឌការងារ និយាយអំពីសម្លៀកបំពាក់ និងការលំបាកនៅក្នុងការប៉ះសម្លៀកបំពាក់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើគេមានឲ្យចែកស្បែកជើងអីឲ្យទេ?

[១៣:៣៤:៤៥]

**ឆ៖** អត់មានចែកស្បែកជើងទេ។ ហ្នឹងចំពោះគេ ខ្ញុំអត់ដឹងថាគេចែក ចំពោះខ្ញុំអត់ដែលបានរបបស្បែកជើងទេ ពេលខ្ញុំទៅពីផ្ទះទៅ ម្តាយខ្ញុំគាត់យកអ្វីទៅដូរបានរបៀបកៅស៊ូស្បែកម៉ូតូ គាត់ចោះឲ្យពាក់ហ្នឹងទៅ ខ្ញុំពាក់អាដូចកង់ឡានអ៊ីចឹង តែវាអត់មានកង់ឡានទេ មានម៉ូតូ។ គេប្រជាជនមូលដ្ឋានគេមានស្បែកជើងកង់ឡានហ្នឹងពាក់ ហើយប្រជាជនថ្មីខ្លះក៏អត់មានស្បែកជើងដែរ ខ្ញុំឃើញដើរជើងទទេហើយខោអាវរហែក។ ខ្ញុំអត់ដែលបានរបបស្បែកជើង ខ្ញុំបានខោអាវម្តង ពេលមក៧មករាហ្នឹង --ទំនប់១មករា។ នៅភូមិក៏គេអត់ដែលចែកឲ្យខ្ញុំដែរ ខោអាវ គេថាម៉ាក់ខ្ញុំមានខោអាវឲ្យស្លៀកហើយ ចែកអ្នកអត់ៗ។ ហើយមានមួក ខ្ញុំភ្លេចប្រាប់ពីរឿងមួក។ មួកពេលហ្នឹងប្រើមួកដូន មួកដូនហ្នឹងស្រួចក្បាលអ៊ីចឹងមក រីកអ៊ីចឹង ម៉ាក់ខ្ញុំគាត់យកអាវភ្លៀង យកពីខ្ញុំនៅក្មេងហ្នឹង គាត់ធ្វើមានគេអ្នកស្រុក គេចេះធ្វើគាត់ដូរអីគេដាក់អាវភ្លៀងហ្នឹងពីលើទៅ ហើយមានដូនហ្នឹងពាក់ធ្វើការ គេពាក់អ៊ីចឹងត្រដាក់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកស្រី ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

[១៣:៣៦:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វិុចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរលោកស្រី។ ជាដំបូង ខ្ញុំចង់សួរអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ គឺD22/2531។ នៅក្នុងពាក្យសុំតាំងខ្លួននេះ លោកស្រីបាននិយាយអំពីហេតុការណ៍ឆ្នាំ៧៥ដល់៧៩ ហើយលោកស្រីក៏បាននិយាយអំពីទីតាំងដែលមានការប្រព្រឹត្តបទឧក្រិដ្ឋ។ ប៉ុន្តែខ្ញុំកត់សម្គាល់ឃើញថា លោកស្រីមិនបាននិយាយអំពីការដ្ឋានទំនប់១មករា ថាជាទីតាំងឧក្រិដ្ឋឡើយ គឺលោកស្រីមិនបាននិយាយទាល់តែសោះអំពីទំនប់១មករានេះ។ ខ្ញុំចង់ដឹងថា ហេតុអ្វីទើបនៅឆ្នាំ២០១០ នៅពេលដែលលោកស្រីដាក់ពាក្យសុំតាំងខ្លួននោះ លោកស្រីមិនបាននិយាយថា លោកស្រីធ្វើការទំនប់១មករានោះ?

[១៣:៣៨:១៣]

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ខ្ញុំរៀបរាប់ពាក្យបណ្តឹងនោះ ខ្ញុំមិនបានរៀបរាប់អស់ទេ គេឲ្យនិយាយគោលខ្លីៗ។ បើឲ្យខ្ញុំបកស្រាយវែង មិនមែនតែទំនប់១មករាទេ ក្តៅ មានក្តៅជាងហ្នឹងទៀត រលំញ្ចៅ មានអីទៀត អត់ញុំាអីមានបបរហុត មានច្រើន ច្រើនខ្លាំងណាស់។ តែគាត់អត់បានរៀបរាប់ប្រាប់ដឹង គាត់សួរចំណុច១មករាមានទៅអត់ ដល់ខ្ញុំបើឃើញក្រដាសហ្នឹងមាន១មករា ខ្ញុំថាទំនប់ហ្នឹងខ្ញុំធ្លាប់ទៅ៣ខែ ហើយនៅច្រើនជាងហ្នឹង។ បើមានពេលច្រើន ខ្ញុំបកស្រាយឲ្យច្រើន ហើយមានវាយសម្លាប់មនុស្សនៅរលំញ្ចៅមួយទៀត ខ្ញុំឃើញនឹងភ្នែក។ ហើយថ្ងៃនោះក៏យកខ្ញុំទៅសម្លាប់ដែរ តែដោយយប់ហ្នឹងនៅរលំញ្ចៅ យកអ្នកជាប់ខ្ញុំទៅសម្លាប់ អូ.ខេ រួចខ្លួនដល់ថ្ងៃនេះ។

**ស៖** សូមអរគុណអ្នកស្រី។ នៅក្នុងព័ត៌មានបន្ថែមរបស់អ្នកស្រី គឺចុះថ្ងៃទី២២ មេសា ២០១៤ គឺឯកសារ E307/6.1.6។ អ្នកស្រីបាននិយាយអំពីការងារនៅទំនប់១មករា យើងសង្កេតឃើញថា រយៈពេលនេះ គឺប្រហែលជាពីរបីខែនៅពេលដែល -- នៅក្រោយមានការបំបែកកិច្ចដំណើរការនីតិវិធីដែលសម្រេចថា និយាយអំពីទំនប់១មករា។ តើមានអ្នកណាម្នាក់ទៅជួបលោកស្រី ហើយស្នើលោកស្រីឲ្យ

បំពេញព័ត៌មានបន្ថែម? ហើយនៅពេលដែលគេជួបហ្នឹង គេស្នើឲ្យលោកស្រីនិយាយអំពីទំនប់១មករាដែរឬទេ?

**ឆ៖** ចាស មាន។ ពេលហ្នឹងមេធាវីនៅម្ដុំ -- ឲ្យទៅជួបជុំគ្នានៅទួលគោក។ ហើយដល់ពេលហើយ គេយកគម្រោងសួរឲ្យប៉ុន្មាន ០៤ ខ្ញុំអត់ដឹងដែរ ០៣ ឬ០៤ អីមានពាក់ព័ន្ធនឹងទំនប់។ ដល់ហើយខ្ញុំ -- សួរខ្ញុំៗថា អ្នខ្ញុំធ្លាប់ទៅទំនប់១មករាហ្នឹង៣ខែ ពេលក្រោយមកទៀត។

[១៣:៤០:៤២]

**ស៖** សូមអរគុណអ្នកស្រី។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីសក្ខីកម្មដែលអ្នកស្រីផ្ដល់នៅព្រឹកមិញនេះ។ ប្រសិនបើខ្ញុំយល់មិនខុសទេ អ្នកស្រីនិយាយថា អ្នកស្រីសម្រេចចិត្តទៅធ្វើការនៅទំនប់១មករា។ តើនៅពេលនោះ អ្នកស្រីចាំទេ តើៗឪពុកម្ដាយអ្នកស្រីយល់ឃើញយ៉ាងម៉េចដែរ? តើពួកគាត់យល់ស្របជាមួយអ្នកស្រីដែលអ្នកស្រីស្ម័គ្រចិត្តទៅធ្វើការនៅទំនប់ហ្នឹង ឬមួយក៏ពួកគាត់មិនយល់ស្របទេ ពួកគាត់ប្រឆាំង?

**ឆ៖** ពួកគាត់មិនយល់ស្របទេ គាត់ចង់ថាឲ្យខ្ញុំនៅធ្វើការនៅភូមិហ្នឹងទៅ។ ក៏ប៉ុន្តែខ្ញុំមានព័ត៌មាននៅក្នុងពួកកងចល័តភូមិហ្នឹងនិយាយថា ឥឡូវហ្នឹងការងារក្ដៅគគុកហើយ គេត្រូវដកទៅខាង១មករា អ្នកនៅក៏ត្រូវទៅខាងអូរកំបុត រលំធ្លោ ការដ្ឋានគឺសឹងគ្រប់ទីកន្លែងហើយ បើយើងមិនទៅខាងហ្នឹង ក៏គេត្រូវចាប់ទៅកន្លែងផ្សេងទៀតដែរ។ ហើយខ្ញុំសួរគេថា នៅរលំធ្លោធ្វើអី -- នៅ១មករាធ្វើអ្វីខ្លះ? គេថារែកដី កាប់ប្រឡាយ អ៊ីចឹងខ្ញុំចង់ទៅហ្នឹង ព្រោះខ្ញុំអត់ចង់ចុះទឹកស្ទូង មានឈ្លើងតោង ហើយក្នុងព្រៃមានសត្វតូចៗខាំ។ ហើយក្រៅពីរូបខ្ញុំ ក៏គេចាត់ទៅទាំងអស់ នៅតែវ័យកណ្ដាលនៅក្នុងភូមិ និងចល័តភូមិ នៅប្រហែលជាមិននៅ គេងតាមក្រោយភូមិឆ្ងាយៗ។ ហើយខ្ញុំក៏សម្រេចចិត្តទៅដើម្បីឲ្យថានៅក្នុងក្រុមគ្រួសារខ្ញុំហ្នឹងមានកម្លាំងមួយស្រួចជួយការងារធ្ងន់ធ្ងរ ការងារដែលក្ដៅគគុកប៉ុនណា ក៏ខ្ញុំស្ម័គ្រចិត្តទៅជាមួយពួកគេ អាចរួចខ្លួនក្នុងក្រុមគ្រួសារ។

[១៣:៤២:២៩]

**ស៖** តើអ្នកស្រីចាំទេថា ឪពុកម្ដាយអ្នកស្រីគាត់ពិបាកចិត្ត គាត់មិនសប្បាយចិត្តដែលអ្នកស្រីមិនស្ដាប់យោបល់របស់គាត់? តើពួកគាត់ពិបាកចិត្តទេ នៅពេលដែលអ្នកស្រីសម្រេចចិត្តទៅទំនប់១មករានោះ?

**ឆ៖** គាត់ពិបាកចិត្ត តែក៏គាត់ -- បងៗចេះតែប្រាប់ថា ទោះបីខ្ញុំមិនចេញទៅពេលនេះ ក៏ពេល

ក្រោយ ក៏ខ្ញុំត្រូវតែចេញបន្តបន្ទាប់គ្នាឆ្ងាយដូចគ្នាដែរ។ ហើយទៅជាមួយពួកគាត់ បងៗនៅក្នុងភូមិដែលរាប់អានជាមួយម្ដាយខ្ញុំ គាត់ថាអត់អីទេ គេជួយមើលឲ្យ ថានៅតូចណាស់ទៅធ្វើអី។ ខ្ញុំចង់ទៅ ព្រោះអីខ្ញុំចង់ចូលដើម្បី -- ខ្ញុំមើលសភាពការណ៍ដូចជាតានតឹងបន្តិចម្ដងៗ ផ្ទះអ្នកណាដែលអត់មានការងារធ្វើច្រើន ឈឺ ឬក៏ចាស់ គេចេះតែបញ្ជូនចូលទៅកន្លែងថ្មី ផ្លាស់កន្លែងថ្មីគឺកន្លែងចាញ់ គេថា “ទុកមិនចំណេញ ដកចេញមិនខាត”។ អ៊ីចឹងគេត្រូវប្រើពាក្យអ៊ីចឹងៗមក គេត្រូវយកទៅធ្វើការនៅ -- យកទៅនៅកន្លែងថ្មី ចេញពីភូមិគេ។ អ៊ីចឹងភូមិគេហ្នឹងត្រូវការមនុស្សឧស្សាហ៍ មនុស្សព្យាយាម មនុស្សការងារច្រើនក្ដាប់មនុស្សការងារក្ដៅគគុកណាស់ និយាយទៅ មនុស្សសកម្ម។

**ស៖** សូមអរគុណ។ នៅព្រឹកនេះ អ្នកស្រីក៏បាននិយាយផងដែរថា នៅពេលនោះប្រជាជនគេគិតថាអ្នកស្រីក្មេងពេក មិនគួរទៅធ្វើការនៅការដ្ឋាន១មករាទេ។ តើប្រជាជនដែលគេគិតថាអ្នកស្រីក្មេងហើយគេប្រាប់ហ្នឹង ជាអ្នកណាដែរ អ្នកស្រីនៅចាំទេ?

[១៣:៤៤:១៧]

**ឆ៖** ច្រើនគ្នា ច្រើនទាំងចាស់ ទាំងក្មេង មកគេថា អូយ! ប៉ុណ្ណឹងចេះទៅកងចល័តធ្វើការអីហើយអ្នកនៅភូមិចេះតែថាដែរ តូចតែមួយមករកអី នៅបេប៊ីហ្នឹងមកធ្វើអី ចេះតែលេងខ្ញុំហ្នឹង។ រួច -- ចុះនៅភូមិក៏ខ្ញុំធ្វើការៗហាត់ដូចតែគ្នា ហើយទៅព្រៃទៅអីទៀត ឆ្លងទូកទៀត ខ្ញុំអត់ចេះហែលទឹកទៀត។ ឆ្លងបឹងមួយធំនៅក្រោយភូមិខ្ញុំហ្នឹង មានបឹងធំណាស់ ទទឹងធំជាងទន្លេមេគង្គទៀត ហើយជិះទូក។ នាងខ្ញុំអត់ចេះហែល ហើយទៅធ្វើការនៅក្រោយៗភូមិហ្នឹង ស្ទូងដក ចុះទឹកភក់ ហើយខ្ញុំចង់ទៅលើកដី ហាត់ក៏ហាត់ទៅកុំឲ្យពិបាកសត្វល្អើង សត្វអីតោងអ៊ីចឹង។

**ស៖** ខ្ញុំយល់ ប៉ុន្តែអ្នកស្រីចាំច្បាស់ទេថា អ្នកណាខ្លះដែលនិយាយពាក្យហ្នឹង តើជាអ្នកភូមិនៅជាមួយអ្នកស្រី? តើអ្នកស្រីចាំទេថាអ្នកណាអ្នកប្រាប់អ្នកស្រីបែបនេះ?

**ឆ៖** មានភូមិចាស់ ស្គាល់ម្ដាយខ្ញុំក៏និយាយ ហើយបងៗប្រជាជន១៧មេសាច្រើននិយាយ ប៉ុន្តែពួកខ្ញុំច្រើនរាប់ -- មានសិទ្ធិនិយាយជាមួយពួក១៧មេសាច្រើនជាង ប្រជាជនមូលដ្ឋានគេមានសិទ្ធិជាងខ្ញុំ។ អ៊ីចឹងពួកខ្ញុំអត់ហ៊ាននិយាយអីទេ ខ្លាចខុស ហើយគេក៏មិននិយាយអីច្រើនជាមួយពួកខ្ញុំដែរ។ គ្រាន់តែពួកដំណើរចាស់ៗជាមួយម្ដាយខ្ញុំថា កូននៅតូចណាស់ ខ្ញុំអ៊ីចឹង។ តែបើពួកធំៗនិយាយច្រើន ១២មេសា ច្រើនជាង។

**ស៖** តើអ្នកស្រីចាំទេថា ឪពុកម្ដាយរបស់អ្នកស្រីមានតវ៉ាទៅមេភូមិអំពីបញ្ហាដែលអ្នកស្រីស្ម័គ្រចិត្តទៅធ្វើការនៅទំនប់១មករាទេ?

[១៣:៤៦:២១]

**ឆ៖** គាត់អត់មានតវ៉ាគេទេ អត់។

**ស៖** អ្នកស្រី ខ្ញុំមានសំណួរបន្ថែមមួយចំនួនទៀតទាក់ទងទៅនឹងស្ថានភាពការងារនៅទំនប់១មករា។ សាក្សីមួយចំនួនដែលបានមកដល់អង្គជំនុំជម្រះ ហើយនិងអង្គុយកន្លែងដែលអ្នកស្រីអង្គុយនេះ ពួកគេបានផ្ដល់ចម្លើយថា ការឈប់សម្រាកពេលបាយថ្ងៃត្រង់ គឺចាប់ពីម៉ោងដប់មួយៗ ឬក៏ដប់មួយដល់ ឬក៏ម៉ោងមួយដល់ម៉ោងពីរ ម៉ោង -- គឺដប់មួយដល់ម៉ោងមួយ ឬក៏ដប់មួយដល់ម៉ោងដប់ពីរ -- ដល់ម៉ោងពីរ។ តើនេះជាការផ្ដល់សក្ខីកម្មត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំអត់ចាំម៉ោងទេនៅនោះ ខ្ញុំអត់មានម៉ោងមើល អត់ចាំ។ ពេលគេឈប់ៗនឹងគេទៅ ដល់គេថា អំ! ថ្ងៃគេវាយរគាំង គេមានជួងគេ។ តែខ្ញុំអត់ដឹង គេវ៉ៃជួងទៅយើងដឹងសម្រាកទៅ។ ដល់ពេលគ្រាន់ថា ពេលវេលាវាខ្លីញ៉ាំបាយហើយអ៊ីចឹងហើយ ញ៉ាំទឹកហើយអង្គុយតែមួយភ្លែតវ៉ៃជួងទៀតហើយ អត់មានបានលក់អីបន្តិច អត់ដែល។ បានខ្ញុំគិតថាពេលវាខ្លី តែខ្ញុំអត់ដឹងពេលវេលាថា កំណត់ប៉ុន្មានទេ។ ខ្ញុំវានៅតូចពេកដែរកាលហ្នឹង ហើយខ្ញុំអត់ចេះគេងថ្ងៃទៀត។

[១៣:៤៧:៥៧]

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាជួងដែលគេវ៉ៃដើម្បីឱ្យទៅឈប់សម្រាកពេលបាយថ្ងៃត្រង់ហ្នឹង គឺមិនមែនសម្រាប់តែការ -- សម្រាប់តែក្រុមអ្នកស្រីទេ គឺគេវ៉ៃជួងសម្រាប់មនុស្សទាំងអស់នៅការដ្ឋានទាំងមូល តើអ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ឆ្លើយ អត់ទាន់ឆ្លើយផងអំមិញ!

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ចាស ពិត។ ពិតមែន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** សាក្សីខ្លះក៏បានផ្ដល់សក្ខីកម្មថា មានការឈប់សម្រាកនៅពេលព្រឹកផងដែរ គឺចន្លោះពី

ម៉ោងប្រាំពីរដល់ម៉ោងដប់មួយនៅពេលព្រឹកហ្នឹង គឺគេធ្វើការ ប៉ុន្តែនៅពាក់កណ្ដាល នៅចំពាក់កណ្ដាលហ្នឹងគេមានពេលឈប់សម្រាកមួយភ្លែត។ តើអ្នកស្រីចាំថាមានការឈប់សម្រាកបែបនេះទេ?

[១៣:៤៩:១៣]

**ផ៖** ខ្ញុំដូចជាប្រហាក់ប្រហែលទេ ពីព្រោះអីខ្ញុំច្រើនដើរទៅដងទឹក ដល់ដើរដកទឹកជូនកាលពេលគេសម្រាកអីអ៊ីចឹង ខ្ញុំអាចថាពេលខ្ញុំដងទឹក ខ្ញុំអត់ដែលសម្រាកនឹងគេ ម៉ោងគេសម្រាកគេប្រើយើងទៅដងទឹកក៏អាចដែរ។ តែខ្ញុំចាំតែពេលបាយ ពេលល្ងាច។

**ស៖** សូមអរគុណអ្នកស្រី។ ទាក់ទងនឹងការធ្វើការងារនៅពេលល្ងាច និងនៅពេលយប់វិញនោះមានសាក្សីខ្លះគាត់និយាយថា ការធ្វើការនៅពេលយប់គឺមិនជាញឹកញាប់ទេ គឺម្ដងម្កាល។ ហើយសក្ខីកម្មរបស់សាក្សីមួយរូប គាត់និយាយថា ការធ្វើការនៅពេលយប់ គឺនៅពេលតែខ្មើត នៅពេលខែភ្លឺ នៅខែនៅពេលខ្មើតប៉ុណ្ណោះ។ តើអ្នកស្រីចាំទេវាហេតុការណ៍បែបនេះកើតឡើង?

**ផ៖** នាងខ្ញុំចាំថា ពេលធ្វើការពេលយប់ ពេលខែភ្លឺអត់មានអុជចន្លុះអាចន្លុះមួយដូចភ្លើងគេនោះទេ។ តែពេលយប់ពួកខ្ញុំធ្វើការមានចន្លុះ។ តែខ្ញុំធ្វើការយប់ជាញឹកជាញាប់ មិនមែនម្ដងម្កាលទេកន្លែងពួកខ្ញុំ។

**ស៖** តើការងារនៅពេលយប់ហ្នឹង គេធ្វើការតែម្ដងម្កាលទេ ឬក៏គេធ្វើការញឹកញាប់ទៀងទាត់?

**ផ៖** គេធ្វើការ ខ្ញុំមិនសូវចាំច្បាស់ថាញឹកញាប់ តែខ្ញុំដឹងថាធ្វើយប់។ ខ្ញុំទៅញឹកញាប់ ពួកខ្ញុំទៅញឹកញាប់។ បើបងៗខ្លះជួបខ្ញុំ គាត់ថាធ្វើគ្នាពេលឈប់ទេ ឯងច្រឡំហើយ អត់មានឈប់ទេ ពេលយប់នោះពួកយើងយប់។ ហើយពេលណាសម្រុករហូតដល់ម៉ោងដប់ក៏មានដែរ ពេលណាយើងធ្វើយឺតអ៊ីចឹងខ្លាច កាលគេដាក់ផែនការឲ្យយើងយឺតជាងខាងស្រុកគេខាងអ៊ីចឹង យើង របស់យើងសម្រុកធ្វើហើយ។ គេណោះ គេលឿនជាង ដាក់ផែនការ ឧទាហរណ៍ថា១ខែឲ្យហើយ យើងរៀងយឺត គឺយើងត្រូវតែធ្វើ។ ខ្ញុំចាំ។

[១៣:៥១:៣៨]

**ស៖** ចម្លើយរបស់អ្នកស្រី គឺធ្វើឲ្យខ្ញុំឈានទៅដល់ប្រធានបទបន្ទាប់ទៀត គឺថាចំពោះការងារគេអត់មានការបែងចែកកូតាជាក់លាក់នោះទេ។ ប៉ុន្តែអ្នកស្រីចាំទេថាក្នុងក្រុមរបស់អ្នកស្រី គឺមានការបែងចែកបរិមាណការងារ ថាតើប៉ុន្មានម៉ែត្រគូបក្នុង១ថ្ងៃដែលត្រូវជីកអ្វីដែរឬទេ? តើអ្នកស្រីចាំអំពីចំនួនម៉ែត្រគូបដែលគេបែងចែកឲ្យក្រុមអ្នកស្រីដែរឬទេ? តើមានទេ?

**ធ៖** មាន ប៉ុន្តែដូចជាមិន ខ្ញុំអត់ចាំដែររឿងម៉ែត្រគូប។ បើថាគេវាស់គេកំណត់ថាប៉ុន្មានហើយប្រឡាយហ្នឹង ខ្ញុំនៅចាំស្រពេចស្រពិលដែរ ខ្ញុំនៅតូចដែរ ព្រោះខ្ញុំច្រើនតែទៅដងទឹកទៅ ហើយមករែកបានតិចៗគេប្រើខ្ញុំទៀតទៅ។ ខ្ញុំអត់ចាំថាគេដាក់ផែនការកំណត់ថាប៉ុន្មានម៉ែត្រគូបអីចឹង គ្រាន់ដាក់ជាក្រុមទៅ ខ្ញុំចេះតែរែកនឹងគេទៅ ខ្ញុំអត់យល់ អត់ដឹង។ គេថាថែមយប់ ធ្វើទៀតទៅ ទេហីទៅ។

**ស៖** នៅព្រឹកនេះ អ្នកស្រីនិយាយអំពីប្រធានក្រុមឈ្មោះ ស៊ីម -- ស៊ីង តើអ្នកស្រីធ្លាប់ឮគាត់គំរាមកំហែងដល់ប្រជាជន ឬក៏ដល់កម្មករដែលធ្វើការនៅទីនោះទេ?

**ធ៖** គាត់គ្រាន់តែប្រាប់ជំរុញពីការងារ តែគំរាមកំហែងខ្លាំងក្លាដូចជាអត់មានទេ។ គាត់ប្រាប់ថាពួកយើងខំសម្រុកឡើងឱ្យឆាប់ហើយ មើលខាងស្រុកគេៗហើយ យើងប្រឹងឱ្យបានលឿន និងប្រជុំជំរុញអីចឹងប៉ុណ្ណឹង ដូចខ្ញុំនិយាយអីចឹង។ គាត់អត់មានរើអត់មានអីទេកាលទំនប់១មករាហ្នឹង អត់ដែលមានរើស្លាប់អីនៅហ្នឹងទេ អត់ទេ។

[១៣:៥៣:៥៧]

**ស៖** អ្នកស្រីក៏បាននិយាយអំពីអ្នកធ្វើការក្នុងក្រុមអ្នកស្រីដែលឈឺ ហើយត្រូវបានគេបញ្ជូនទៅភូមិដើម្បីព្យាបាល ហើយពួកគាត់អត់ត្រឡប់មកវិញទេ ដោយសារតែអ្នកស្រីធ្វើការនៅហ្នឹងតែ៣ខែ។ តើអ្នកស្រីដឹងទេថាក្នុងក្រុមការងាររបស់អ្នកស្រីនោះ តើគេមានប្តូរវេនការងារគ្នាដែរឬទេ? ឬក៏ថាមានពលករ កម្មករដទៃទៀតមកពីភូមិអ្នកស្រីហ្នឹងមកប្តូរវេន មកប្តូរការងារគ្នាដែរឬទេ នៅក្នុងរយៈពេល៣ខែនោះ?

**ធ៖** ចាស អត់មានទេ ដូចអត់មានឃើញផង។ អត់មានឃើញប្តូរ អ្នកឈឺទៅភូមិព្យាបាលទៅ។

**ស៖** នៅព្រឹកនេះ អ្នកស្រីក៏បាននិយាយផងដែរអំពីម្ហូបអាហារដែលអ្នកស្រីនិងមិត្តរួមក្រុមការងាររបស់អ្នកស្រី គឺថាម្ហូបទាំងអស់ហ្នឹងគេយកពីភូមិមកឱ្យក្រុមអ្នកស្រី។ តើអ្នកស្រីចាំទេថា អ្នកណាជាអ្នកដឹកជញ្ជូន ឬក៏អ្នកណាជាអ្នកទទួលខុសត្រូវលើការយកម្ហូបអាហារពីភូមិមកការដ្ឋានហ្នឹងដែរឬទេ?

**ធ៖** ខ្ញុំដឹងមានអ្នកដឹកពីភូមិគឺអ្នកនៅបញ្ញា អ្នកដែលនៅភូមិខ្ញុំហ្នឹង ប្រជាជននៅភូមិខ្ញុំហ្នឹង ដូចគេ ថាគាត់នៅខាងសេដ្ឋកិច្ចអីចឹង អ្នកដឹកម្ហូប ដឹកអង្ករអីមកអីចឹង តែខ្ញុំអត់ស្គាល់គាត់។

**ស៖** តើអ្នកស្រីចាំទេថា គាត់ធ្វើ -- គាត់ដឹករាល់ថ្ងៃ ឬក៏ដឹកពីរថ្ងៃម្តង ឬក៏ដឹកមួយថ្ងៃពីរដង

អ៊ីចឹង អ្នកស្រីចាំទេ ថាគាត់ដឹកប៉ុន្មានដងដែរ?

[១៣:៥៦:១១]

**ឆ៖** មិនមែនដឹកញឹកទេ ខ្ញុំចាំតាមបើខ្ញុំដឹងប្រហែលជាប្អូនដប់ថ្ងៃអីអ៊ីចឹង មិនមែនញាប់ មិនញាប់ដឹករៀងយឺតបន្តិចដែរ មិនញាប់ពេកទេ មិនកៀកថ្ងៃគ្នាពេកទេ។ ប្រហែលជា១០ថ្ងៃអី ឃើញមកម្តងអ៊ីចឹង ១អាទិត្យ ២អាទិត្យ ១០ថ្ងៃអ៊ីចឹង។

**ស៖** តើគាត់ដឹករបស់របរផ្សេងក្រៅពីម្ហូបអាហារមកពីភូមិដែរឬទេ? ឧទាហរណ៍ដូចជាអីវ៉ាន់ ឬក៏របស់របរដែលអ្នកស្រី ហើយនិងក្រុមការងារអ្នកស្រីស្នើសុំ ឧទាហរណ៍ដូចជាខោអាវ មុង ឬមួយក៏គាត់ដឹកតែម្ហូបអាហារទេ?

**ឆ៖** ខ្ញុំអត់សូវដឹងដែរកន្លែងហ្នឹង ដឹងគាត់ដឹក បើដឹងតែគាត់ដឹកស្បៀងអាហារមកអ៊ីចឹង ប៉ុន្តែពេលហ្នឹងគាត់ដាក់សម្ភារៈពីហ្នឹងមកអី ខ្ញុំអត់ដឹងអីទៀតទេ ដឹងថាស្បៀងអាហារ ដឹងតែប៉ុណ្ណឹង។ ហើយខ្ញុំអត់ដែលចាប់អារម្មណ៍ទៅមើលទៅអីគាត់ គ្រាន់ថាដឹងមានអ្នកដឹក។

**ស៖** នៅពេលដែលមានអ្នកណាម្នាក់ឈឺ ហើយត្រូវយកទៅព្យាបាលនៅភូមិវិញ។ តើអ្នកដែលឈឺហ្នឹងគាត់ធ្វើដំណើរជាមួយនឹងអ្នកដែលដឹកស្បៀងហ្នឹង ឬមួយក៏គេមានមធ្យោបាយដឹកជញ្ជូនអ្នកឈឺហ្នឹងត្រឡប់ទៅវិញតាមមធ្យោបាយផ្សេង?

**ឆ៖** ភាគច្រើនៗតែដឹកជាមួយអ្នកដឹកស្បៀង ហ្នឹងតាមខ្ញុំយល់។ បើថារឿងផ្សេងដូចខ្ញុំអត់សូវដឹងដែរកន្លែងហ្នឹង ប៉ុន្តែបើមានមក ដូចនៅការដ្ឋានផ្សេង កាលខ្ញុំនៅផ្សេងពីការដ្ឋានហ្នឹង មានឈឺដឹកតាមអ្នកសេដ្ឋកិច្ចអ៊ីចឹងមក។

[១៣:៥៨:២៩]

**ស៖** នៅព្រឹកនេះអ្នកស្រីក៏និយាយថា អ្នកស្រីជឿថា មានៗពេទ្យដែលគេផ្តល់ថ្នាំឲ្យអ្នកស្រី នៅពេលដែលអ្នកស្រីឈឺ។ ហើយពេទ្យនោះគឺថា អត់មានការបណ្តុះបណ្តាលបានត្រឹមត្រូវអ្វីនោះទេ។ ដូច្នេះខ្ញុំចង់ដឹងថា ហេតុអ្វីបានជាអ្នកស្រី -- បានជានៅពេលនោះអ្នកស្រីគិតថា ពេទ្យហ្នឹងគឺអត់មានការបណ្តុះបណ្តាលអ្វីឲ្យត្រឹមត្រូវនោះ?

**ឆ៖** ពីព្រោះខ្ញុំដឹង ព្រោះពេទ្យអត់មានចេះ មានមើលថាយើងម៉េច មើលឈាម ឬក៏មានអីមើលស្ទង់ឈាមអីក៏អត់ដែរ។ បើថាយើងឈឺអ៊ីចឹងមានថ្នាំ ថារាកឲ្យរាកទៅ អាថ្នាំមូលៗដូចអាចម៍ទន្សាយហ្នឹង ប៉ុណ្ណឹង។ អត់មានស្ទង់កម្តៅ ឬក៏អត់មានដឹង ហើយអ្នកហ្នឹងចេញពី -- ពេទ្យហ្នឹងច្រើន

ចេញពីមូលដ្ឋានចាស់ កូនចៅប្រជាជនចាស់ ដូចថាម្នាក់ហ្នឹងអត់មានរៀនពេទ្យទេ តែគេៗឲ្យទៅធ្វើពេទ្យអ៊ីចឹង តែគេប្រាប់ គេមានរៀនវគ្គខ្លីមិនដឹង គេប្រាប់ថាត្រូវធ្វើចាក់ថ្នាំបន្តិចៗអ៊ីចឹង ឬក៏ធ្វើអីខ្ញុំអត់យល់ទេកន្លែងហ្នឹង។ តែអត់មានឃើញមានទៅរៀនពេទ្យអីធំ អ្នកហ្នឹងក៏មិនមែនជាអ្នកចេះដឹង ចេះអក្សរ ឬក៏ចេះអីខ្លាំងអត់ទេ។

[១៣:៥៩:៥១]

**ស៖** តើអ្នកស្រីបានដឹងអំពីការបណ្តុះបណ្តាល ឬក៏ការអប់រំនៅមន្ទីរពេទ្យស្រុក ឬក៏មន្ទីរពេទ្យនៅតាមវត្តនោះទេថា? តើអ្នកស្រីដឹងអំពីប្រវត្តិនៃការសិក្សា ឬក៏ប្រវត្តិនៃការបណ្តុះបណ្តាលផ្នែកពេទ្យរបស់ពួកគ្រូពេទ្យទាំងអស់នោះទេ?

**ឆ៖** ចាស អត់មានទេ។ ពេទ្យទាំងអស់នោះ អត់មានពេទ្យអីទេដូចជាមានតាៗចាស់ៗ គាត់ជាគ្រូខ្មែរ ដាំថ្នាំខ្មែរ។ បើនៅ ខ្ញុំដឹងខ្ញុំធ្លាប់គេងនៅវត្តចំបក់ ខាងវត្តចំបក់ហ្នឹង អ្នកប្រធានហ្នឹងឈ្មោះ តាវល្លី តាហ្នឹងរបៀបគ្រូខ្មែរ រួច តាសន ហ្នឹងអនុ។ ហើយ តាវល្លី ហ្នឹងគាត់ថ្នាំអ៊ីចឹង ហៅពួកអ្នកជំងឺញ៉ាំអ៊ីចឹងទៅ ហើយពេទ្យ -- បើមានពេទ្យខ្លាំងគេនោះ គេមានទឹកថ្នាំដូចខ្ញុំនិយាយព្រឹកមិញអ៊ីចឹង។ ដូចអត់មានអីឲ្យហួសផង អត់មានអីថ្នាំពិសេសផង ពេទ្យនោះគាត់អត់មានស្លៀកអីជាឯកសណ្ឋានពេទ្យដែរ ស្លៀកពាក់ខ្មៅធម្មតា។

**ស៖** តើប្រសិនបើខ្ញុំនិយាយថា នៅពេលដែលអ្នកស្រីឈឺ គេផ្តល់ការព្យាបាល ទោះបីថាល្អ មិនល្អក៏ដោយ ក៏គេផ្តល់នូវការព្យាបាលដល់អ្នកស្រី ព្រោះអ្នកស្រីជាប្រជាជនថ្មី។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៤:០១:៤២]

**ឆ៖** ចាសត្រឹមត្រូវ ក៏ប៉ុន្តែថ្នាំអត់មានប្រសិទ្ធិភាពទេ ប្រជាជនថ្មី គឺអត់មានទេ។

**ស៖** ខ្ញុំមានសំណួរខ្លះៗទៀតចុងក្រោយមុននឹងខ្ញុំបញ្ចប់ គឺសំណួរអំពីឪពុករបស់អ្នកស្រី និងបងថ្លៃប្រុសរបស់អ្នកស្រី។ អ្នកស្រីបាននិយាយថា អ្នកស្រីមិនដឹងអំពីឋានៈ ឬក៏ឋានន្តរសក្តិរបស់ឪពុកអ្នកស្រីហើយ ប៉ុន្តែមេភូមិគេដឹង។ ប៉ុន្តែមេភូមិគាត់ដឹងថា ឪពុកអ្នកស្រីហ្នឹងធ្វើទាហាននៅក្នុងសម័យលន់ នល់ តើអ៊ីចឹងមែនទេ?

**ឆ៖** ដូចជាគាត់អត់ដឹងផង ខ្ញុំអត់ដឹងដែររឿងហ្នឹង អត់មានអ្នកណានិយាយប្រាប់ផង គេលាក់ទាំងអស់។ អត់មានអ្នកណាប្រាប់ដល់ប្រធានភូមិឲ្យដឹងទេ។

**ស៖** ប្រហែលខ្ញុំស្តាប់សក្ខីកម្មរបស់អ្នកស្រីមិនត្រឹមត្រូវ ប៉ុន្តែនៅព្រឹកនេះ អ្នកស្រីនិយាយថា ទាំងអស់គ្នា គ្រប់គ្នាដឹងអំពីឋានន្តរសក្តិរបស់ឪពុកអ្នកស្រី។ តើនៅពេលដែលអ្នកស្រីនិយាយបែបនេះ មានន័យថា គេគ្រប់គ្នាដឹងថា ឪពុកអ្នកស្រីហ្នឹងជាយោធា លន់ នល់។ តើអ៊ីចឹងមែនទេ?

[១៤:០៣:២៦]

**ឆ៖** ប្រហែលជាគេសង្ស័យទេ តែបើឲ្យគេដឹងច្បាស់គេអត់ដឹងទេ។ ថ្ងៃមួយមានគេចាប់ខ្ញុំសួរ ឈ្មោះ ឈន ប្រធាននៅកន្លែងភូមិនៅ សួរថា "ប៉ាឯងពីដើមធ្វើអ្វី?" ខ្ញុំថា "គាត់អត់ធ្វើអីទេ គាត់លក់ដូរ ធ្វើស្រែធ្វើអ៊ីចឹង។" ក្នុងប្រវត្តិរូបអត់ដាក់អ៊ីចឹងទេ។ តែបងថ្លៃខ្ញុំប្រហែលជាគេសង្ស័យ ពីព្រោះគេឆែក ខោអាវ ឃើញមានខោអាវដូចពីឡុត។ គេឧស្សាហ៍ឆែកខោអាវក្នុងផ្ទះ ប្រជុំគេធ្វើប្រវត្តិរូបហើយ គេ ឆែកខោអាវ ឆែកសម្លៀកបំពាក់យើងមាននៅក្នុងផ្ទះអ៊ីចឹង ឧស្សាហ៍ឆែក។ ម្តាយខ្ញុំគាត់និយាយប្រាប់ ថាឆែកៗ មើលរើ ក្រែងលោមានខ្មាំងបង្កប់អីវ៉ាន់នៅក្នុងផ្ទះ ឧស្សាហ៍ឆែកណាស់ មិនមែនតែខ្ញុំ ទូទៅ ប្រជាជនទាំងអស់ឆែកគ្រប់ផ្ទះ ហើយនិងធ្វើប្រវត្តិរូបគ្រប់ផ្ទះ។ ប៉ាខ្ញុំគាត់ខំធ្វើការណាស់ គាត់អត់ដែល ឈប់ទេ គាត់ខ្លាចស្លាប់ ហើយក៏គាត់អត់ចង់ឲ្យគេតាមដានថាគាត់ហ្នឹងជាអ្វីដែរ។ តែប៉ាខ្ញុំគាត់ មុខរបរ គាត់នៅពីដើមនៅពីរកន្លែងដែរ គាត់ធ្វើពេទ្យ គាត់ចេះមើលចេះអី តែគាត់អត់ប្រាប់គេទេ។ តែមានអ្នក ណាឈឺអ៊ីចឹងគាត់ដឹងទាំងអស់ ជួយប្រាប់គេជិតខាងហ្នឹងត្រូវម៉េចៗអ៊ីចឹង។ តែគាត់មិនបានដុកទ័រទេ តែ គាត់ពេទ្យ។ ហើយលោកអត់មានដឹងទេ ប្រហែលជាគេសង្ស័យ តាមខ្ញុំគិត បើថាឲ្យខ្ញុំបើចំហ ផ្ទះខ្ញុំអត់ ទេ។

[១៤:០៤:៤៩]

**ស៖** ចុះបងថ្លៃរបស់អ្នកស្រី តើគេស្រាវជ្រាវ ហើយគេដឹងថា គាត់ជាពីឡុតនៅក្នុងរបប លន់ នល់ ហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ពេលគាត់ការហើយ ប៉ុន្មានថ្ងៃខ្ញុំចេញមកស្ទឹងជីនិតហ្នឹង ទំនប់១មករា។ ខ្ញុំ អត់សូវសួរនាំពីរឿងគាត់ផង ខ្ញុំអត់ដឹងច្បាស់ពីរឿងបងថ្លៃហ្នឹង។ បានឮពីអ្នកផ្សេងប្រាប់ខ្ញុំតិចៗ ខ្ញុំស្តាប់ ហើយ តែខ្ញុំអត់ចង់ស្តាប់ច្រើន រឿងដែលខ្ញុំពិបាកចិត្ត ខ្ញុំចេះតែដើរចេញឃ្លាំ ខ្ញុំអត់ចង់ស្តាប់។

**ស៖** ប៉ុន្តែតើត្រឹមត្រូវទេដែលថា ឪពុករបស់អ្នកស្រី ហើយនិងបងថ្លៃអ្នកស្រីហ្នឹងគាត់ធ្វើការ នៅតាម -- គាត់ៗធ្វើស្រែក្រោយថ្ងៃរំដោះឆ្នាំ៧៥ ដែរទេ?

**ឆ៖** ក្រោយថ្ងៃរំដោះ ៧ មករា -- រំដោះ ១៧ មេសា ៧៥ គឺគាត់ធ្វើស្រែធ្វើចម្ការតាមបទបញ្ជា

ខ្មែរក្រហម តាមភូមិតាមស្រុកហ្នឹង ធ្វើដូចប្រជាជនទូទៅ មានឈប់ មានសម្រាកអីណា អត់ទេ។

**ស៖** ប្រសិនបើអត្តសញ្ញាណរបស់គាត់មិនត្រូវបានគេដឹងអស់រយៈពេល២ឆ្នាំអ៊ីចឹង តើវាអាចទេថាមានអ្នកណាម្នាក់នៅក្នុងភូមិគេក្បត់គាត់ ហើយរាយការណ៍ទៅមេភូមិ ទៅអង្គការ ឬក៏ទៅអាជ្ញាធរណាមួយដែរទេ? វាអាចទេ?

[១៤:០៧:០៦]

**ឆ៖** ប្រហែលជាអាច តែខ្ញុំអត់ដឹងច្បាស់ ប្រហែលជាមានអាចរឿងហ្នឹង។ ប៉ុន្តែគ្រួសារខ្ញុំដំបូងគេយកបងថ្លៃខ្ញុំពីរនាក់បងខ្ញុំយកទៅសម្លាប់ទេ តែម្ដាយឪពុកខ្ញុំ ម្ដាយខ្ញុំអ្នកទៅសុំ ទៅនៅរស់នៅជុំកូន ហើយគាត់អត់ដឹងថាគេសម្លាប់ទេ ជំនាន់អត់ទាន់មានសម្លាប់សោះ ទើបមានលើកទី១ហ្នឹង ឆ្នាំ១៩៧៧ ហ្នឹង ថ្ងៃ២១ហ្នឹង សម្លាប់លើកទី១។ ពេលជម្លៀសគឺជម្លៀសទៅនៅក្នុងព្រៃស្រុកចាញ់ ដូចជាបាក់រទេះស្រុកអីខ្លះទេ ដូចជានៅក្នុងជ្រៅៗ។ ដល់ឆ្នាំហ្នឹង ពេលគេចុចហ្នឹង គាត់អត់ដឹងថាគេសម្លាប់ទេម្ដាយខ្ញុំនោះ គាត់គិតថា កូនបងខ្ញុំមានផ្ទៃពោះអ៊ីចឹង គង់តែជម្លៀសទៅបែកគ្នា អ៊ីចឹងសុំជម្លៀសទៅជុំគ្នា ព្រោះអីគេមិនឲ្យប្រជាជនថ្មីនៅក្នុងភូមិហ្នឹងទាំងអស់ទេ គេជម្លៀសម្ដងបន្តិចៗចេញពីភូមិទាល់តែអស់ ទៅនៅព្រៃ ស្រុកចាញ់។ អ៊ីចឹងគាត់គិតថា បងខ្ញុំអត់ចេះធ្វើអីម្នាក់ឯង កូនង៉ែតខ្ចីមានទម្ងន់ ក៏សុំទៅ ហើយទៅយកតាមយកប៉ាខ្ញុំនៅចាំចម្ការនៅដល់បឹងរៃ សង្កាត់រំលងគ្នាប្រហែលពីរបីសង្កាត់ នៅឆ្ងាយចូលទៅក្នុងព្រៃ។ ហើយរឿងហ្នឹងគឺខ្ញុំយល់ថា ប្រហែលជាគេមិនសង្ស័យថាប៉ាខ្ញុំធ្វើអីទេ ប្រហែលជារឿងគ្រោះថ្នាក់ដោយសារបងថ្លៃខ្ញុំ ជាមួយប្ដីប្រពន្ធគាត់ច្រើនជាង។

[១៤:០៨:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណអ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន សហការីមេធាវីរបស់ខ្ញុំ គាត់មានសំណួរខ្លះៗដែរ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ សុំអញ្ជើញ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណ។ លោកគោរពលោកប្រធាន សូមគោរពចៅក្រម និងអង្គសវនាការទាំងអស់។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ជម្រាបសួរលោកស្រី ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីនៅក្នុងក្រុមការពារក្តីរបស់លោក នួន ជា។ ខ្ញុំសុំមានសំណួរប្រហែលជាពីរ ឬបីសាកសួរលោកស្រីបញ្ជាក់បន្ថែម។លោកស្រីបានមានប្រសាសន៍មុននេះថា មានការយកមនុស្សចេញពីការដ្ឋានដោយប្រាប់ថាឲ្យទៅធ្វើនៅការដ្ឋានផ្សេងទៀត។ តើរឿងនេះ កើតឡើងនៅទីកន្លែងណានៅក្នុងការដ្ឋានណាដែរ?

[១៤:០៩:៤១]

**លោក សៀង សុវិដា៖**

**ឆ៖** នៅការដ្ឋាន ១មករា មានតិចតួចទេ។ តែបើ -- ខ្ញុំអាចឆ្លងកាត់ការដ្ឋានក្រៅពី ១មករា បានទេ?

**ស៖** បាទ ខ្ញុំចង់បញ្ជាក់សក្ខីកម្មរបស់លោកស្រីឆ្លើយថា វាមានការដកមនុស្សថាផ្លាស់ទៅធ្វើការនៅកន្លែងផ្សេងហ្នឹង។ តើកើតឡើងនៅក្នុងការដ្ឋានណា ដែលលោកស្រីផ្តល់សក្ខីកម្មមុននេះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ការដ្ឋាន១មករា នៅពេលលោកសួរៗ ពីការដ្ឋាន១មករា។

[១៤:១០:២៦]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ខ្ញុំចង់បញ្ជាក់លោកស្រីថា ដែលលោកស្រីមានប្រសាសន៍ ដោយសារលោកស្រីឆ្លងកាត់ការដ្ឋានច្រើន។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា សក្ខីកម្មរបស់លោកស្រីដែលមានប្រសាសន៍ហ្នឹងថា មានការដកមនុស្ស ថាផ្លាស់ទៅធ្វើការនៅការដ្ឋានផ្សេងៗ នៅទីកន្លែងផ្សេងហ្នឹង។ តើរឿងដែលលោកស្រីសង្កេតឃើញហ្នឹងមាននៅក្នុងការដ្ឋានណាមួយ ដែលការឆ្លងកាត់របស់លោកស្រីនេះ?

**ឆ៖** វាមានការដ្ឋានច្រើន ដូចជា ១មករា វាតិចតួចទេ ប៉ុន្តែខ្ញុំមិនដឹងថា គេធ្វើយ៉ាងម៉េចទេ។ តែបើការដ្ឋានដូចជា៖ រលំធ្លៅ, គោកម្លូ, វាលស្បូង, កោះសអី គឺបាត់ទៅគឺខ្ញុំដឹងថា គឺយកទៅសម្លាប់ ហ្នឹងច្បាស់ តែការដ្ឋាន១មករា ខ្ញុំអត់ច្បាស់ទេ គឺទើបតែលើកដំបូងដែលគេចាប់ផ្តើមរឿងនេះមនុស្សហ្នឹង តែ

ខ្ញុំអត់យល់ថា គេយកប្តូរមែនឬក៏យ៉ាងម៉េច អត់យល់។ តែបើរលំញ្ញៅគឺយកទៅ គឺយកទៅហើយ។ហ្នឹង ចំពោះខ្លួនខ្ញុំ ដែលខ្ញុំថានៅរលំញ្ញៅហ្នឹង ពេលយប់ហៅខ្ញុំហ្នឹង គឺយកនាងនៅជាប់ខ្ញុំហ្នឹង យកទៅវះពោះសម្លាប់តាមរទេះដឹកមនុស្សតាមសេដ្ឋកិច្ច មកយកម្ហូបអាហារហ្នឹង។ តែភ្លឺឡើងខ្ញុំនៅរស់ បាត់គេវិញនៅជាប់ខ្ញុំ។ គេជីកស្មៅ ជីកទាំងឫស គឺគេយកម្តាយឪពុកខ្ញុំទៅសម្លាប់ បងប្អូនសម្លាប់ គឺនៅសល់ខ្ញុំមួយ គឺគេបង្ហើយ តែថៃដន្យ ខ្ញុំអត់បានទៅ អ្នកផ្សេងជាប់ខ្ញុំទៅវិញ។

[១៤:១២:០០]

**ស៖** លោកស្រីមានប្រសាសន៍កាលពីព្រឹកមិញថា លោកស្រីធ្លាប់ដួលសន្លប់ម្តង តើការដួលសន្លប់ហ្នឹង លោកស្រីដួលសន្លប់នៅការដ្ឋានណាមួយដែរ?

**ឆ៖** នៅការដ្ឋាន១មករា។

**ស៖** លោកស្រីបានមានប្រសាសន៍បន្តទៀតថា លោកស្រីបានក្រោយពីដួលសន្លប់ គេបានសែងលោកស្រីយកទៅព្យាបាល។ លោកស្រីបានសម្រាក១ថ្ងៃ ឬ២ថ្ងៃ ហើយលោកស្រីត្រឡប់មកធ្វើការវិញ។ តើការត្រឡប់មកធ្វើការរបស់លោកស្រីវិញនេះ ជាការសម្រេចចិត្តរបស់លោកស្រី ឬមួយក៏គេបង្ខំឲ្យលោកស្រីមកធ្វើការ?

**ឆ៖** ប្រធានក្រុមគេសួរថា យើងអាចធ្វើការបានដែរឬទេ? ឥឡូវហ្នឹងស្រួលខ្លួនហើយនៅ? ខ្ញុំថា ចាស ខ្ញុំធ្វើការបាន ខ្ញុំមកវិញមក។

**លោក លីវ សុវណ្ណា៖**

បាទ ខ្ញុំបាទអរគុណលោកស្រី អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១៤:១៣:៣៣]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រី សៀង សុវិដា ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិ

របស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរបន្តិចបន្តួច ហើយខ្លីៗតែប៉ុណ្ណោះ ដើម្បីសម្រាប់បំភ្លឺពីលោកស្រី។ កាលពីព្រឹកមិញ លោកស្រីបាននិយាយថា នៅពេលដែលលោកស្រីបានទៅធ្វើការនៅទំនប់១មករា ជាដំបូងលោកស្រីត្រូវបានគេចាត់តាំងឲ្យទៅកន្លែងមួយ ដែលមិនសូវឆ្ងាយពីកន្លែងលោកស្រីដេកនោះទេ ប្រហែលជា១ ទៅ២គីឡូម៉ែត្រតែប៉ុណ្ណោះ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើលោកស្រីនៅទីនោះរយៈពេលប៉ុន្មានក្នុងរយៈពេល៣ខែ ដែលលោកស្រីទៅធ្វើការនៅទីនោះ ដែលលោកស្រីនិយាយថាប្រហែលជាពី១គីឡូ ឬ២គីឡូម៉ែត្រតែប៉ុណ្ណោះ ពីកន្លែងលោកស្រីសម្រាកហ្នឹង?

**លោកស្រី សៀង សុវិដា៖**

**ឆ៖** នេះខ្ញុំសម្រាកប្រហែលជា១ខែ ល្បាក់១ខែ ទម្រាំគេធ្វើរោងរួច រោងនៅភូមិត្នោត។

**ស៖** ដូច្នេះ បើសិនជាខ្ញុំមិនយល់ច្រឡំទេ គឺថាប្រហែលជា១ខែ លោកស្រីធ្វើការនៅកន្លែងនោះ ហើយបន្ទាប់មកទៀត ២ខែដែលនៅសល់នោះ គឺលោកស្រីធ្វើការនៅកន្លែងដែលឆ្ងាយជាងពីកន្លែងនោះបន្តិច អ៊ីចឹងមែនទេ?

[១៤:១៥:០៧]

**ឆ៖** ចាស ពិតមែនហើយ។

**ស៖** ខ្ញុំសូមបំភ្លឺអ្វីដែលលោកស្រីបាននិយាយកាលពីព្រឹកមិញដដែល។ ខ្ញុំហាក់ដូចជាយល់ថា លោកស្រីបានធ្វើការនៅលើទំនប់នោះ ប្រហែលជានៅខែកុម្ភៈ ហើយលោកស្រីថាលោកស្រីធ្វើការនៅទីនោះប្រហែលជា៣ខែ ហើយព្រឹកមិញនេះលោកស្រីបាននិយាយថា លោកស្រីបានចាកចេញនៅប្រហែលជាចូលឆ្នាំខ្មែរ។ អ៊ីចឹងខ្ញុំសូមសួរលោកស្រីបញ្ជាក់ ថាតើលោកស្រីបានចេញពីទំនប់១មករាហ្នឹងមុនចូលឆ្នាំខ្មែរ ឬក៏ក្រោយចូលឆ្នាំខ្មែរ?

**ឆ៖** នាងខ្ញុំបាននិយាយថា នាងខ្ញុំទៅទំនប់១មករាហ្នឹង មិនប្រាកដថាខែ១ ឬក៏ខែ២ទេ នាងខ្ញុំអត់ចាំ។ តែនាងខ្ញុំត្រឡប់មកផ្ទះវិញចូលឆ្នាំខ្មែររួចហើយ យូរដែរ មិនមែនឆាប់ទេ នាងខ្ញុំប្រហែលខ្ទង់ខែ៥ ឬក៏ចុង ឬក៏ក៏ពាក់កណ្ដាល នាងខ្ញុំអត់ចាំទេ។ តែមកត្រឡប់មកដល់ផ្ទះបែកពីគាត់មកបានតែបន្តិចហ្នឹងគេយកពួកគាត់ទៅសម្លាប់ មិនមែនខ្ញុំមកមុនទេ ប្រហែលជាក្រោយច្រើនដែរ ក្រោយខែ៤ ខ្ទង់ខែ៥ ខ្ញុំត្រឡប់មក ល្បាក់ប៉ុនខែប៉ុណ្ណឹង។ ខ្ញុំចាំអត់ច្បាស់កន្លែងហ្នឹង ខ្ញុំពិបាកយល់ដែរ ប៉ុនដឹងអំឡុងធ្វើ៣ខែ តែក្រោយចូលឆ្នាំៗរួច។

[១៤:១៦:៤០]

**ស៖** ឥឡូវខ្ញុំសូមការបញ្ជាក់បំភ្លឺមួយទៀត ទាក់ទងនឹងអ្វីដែលលោកស្រីបានរៀបរាប់ទៅលើទំនប់១មករានោះ។ លោកស្រីបាននិយាយថា កន្លែងដែលលោកស្រីហូបអាហារនៅពេលថ្ងៃនោះ មិននៅឆ្ងាយពីកន្លែងលោកស្រីធ្វើការនោះទេ។ ហើយលោកស្រីក៏បានលើកឡើងផងដែរ អំពីឆ្នាំងដែលគេដាក់ដាំទឹក កំសៀវដែលគេដាក់ដាំទឹក។ អ៊ីចឹងសំណួររបស់ខ្ញុំចង់ដឹង ថាតើទឹកដែលគេដាំហ្នឹងនោះ គឺដាំសម្រាប់តែក្រុមលោកស្រីធ្វើការដែលមកពីភូមិលោកស្រីនោះទេ ឬក៏ដាំហ្នឹងសម្រាប់កម្មករទាំងអស់ ឬអ្នកធ្វើការទាំងអស់នៅទំនប់១មករាតែម្ដង? ពីព្រោះថាមេក្រុមរបស់លោកស្រីជាអ្នកទទួលខុសត្រូវផ្នែកដាំទឹកហ្នឹង ឬក៏មានគេទទួលគ្រប់គ្រងរួមខាងដាំទឹកហ្នឹងឲ្យកម្មករហូបចុកទាំងអស់គ្នាតែម្ដង?

**ឆ៖** គឺមានរួម ដាំទឹករួម ដាំខ្ទះ មិនមែនដាំកំសៀវទេ ខ្ទះត្នោតធំ។ បើនៅចំកន្លែងគេងវិញ កន្លែងស្នាក់នៅ ហ្នឹងគេដាំតាមពួកខ្ញុំស្រុកព្រែកប្រសព្វ ម៉្លឹហ្នឹងគេដាំនៅរោងមួយផ្សេង។ នៅកន្លែងធ្វើការគឺដាំរួមទាំងអស់គ្នា គេដាំអ៊ីចឹង អ្នកណានៅជិតកន្លែងគេដាំហ្នឹងទៅ ក៏ទៅដងញុាំគ្រប់គ្នាទៅ អត់មានប្រធានភូមិដាំទេ -- អត់មានប្រធានក្រុមអីដាំទេ ធ្វើការទាំងអស់គ្នា អ្នកចុងភៅផ្សេង អ្នកដាំទឹកផ្សេង។

[១៤:១៨:២២]

**ស៖** ចំណុចចុងក្រោយមួយទៀតទាក់ទងទៅនឹងការរៀបចំក្រុម ខ្ញុំដូចជាយល់ថា ពេលដែលលោកស្រីទៅដល់នោះ គឺថាប្រហែលមានមនុស្ស១០នាក់ ដែលចេញមកតាមភូមិនីមួយៗ។ អ៊ីចឹងខ្ញុំចង់ដឹងថា កន្លែងដែលលោកស្រី -- គេចាត់តាំងលោកស្រីទៅនោះ គឺថាលោកស្រីធ្វើការនោះ តាមភូមិទេ គឺថាក្នុងក្រុមរបស់លោកស្រីហ្នឹង មានប្រហែលជា១០នាក់ទេ ឬក៏មានលើសពីហ្នឹងទៀត?

**ឆ៖** ពេលនោះគេបញ្ចូលគ្នាតាមសង្កាត់ តាម -- នៅក្នុងស្រុកបញ្ចូលគ្នាក្នុងសង្កាត់ពីភូមិៗមួយៗក្នុងសង្កាត់ឫស្សីកែវដូចគ្នាអ៊ីចឹង បញ្ចូលគ្នាទៅ ហើយនិងស្រុកហ្នឹង ដូចធ្វើឡុកឡំគ្នា ខ្ញុំចាំមិនច្បាស់ប្រហែលជានៅក្នុងមួយប៉ែកសង្កាត់ពួកខ្ញុំឫស្សីកែវ ចំបក់ ជ្រោយអំពិលអ៊ីចឹង ជុំគ្នាអ៊ីចឹង គ្នាប្រហែលជាច្រើនដែរ ធ្វើជុំគ្នាចូលគ្នាជុំគ្នាអ៊ីចឹងទៅ។ គ្រាន់តែថាយើងធ្វើមួយប្លុកអ៊ីចឹង ខាងយើងឫស្សីកែវអ៊ីចឹងទៅ ជិតជាប់គ្នាទាំងអស់អ៊ីចឹង ចង់អ្នកណាមកដក មករែកម៉េចៗទៅ ដូចជាខ្ញុំអត់សូវចាំកន្លែងហ្នឹង។ ប្រហែលជាតាមសង្កាត់ច្រើនជាង ធ្វើការរួមតាមសង្កាត់ច្រើនជាង តែជាប់គ្នារហូតអ៊ីចឹង នៅមួយប្លុកព្រែកប្រសប់ទាំងអស់ មួយប្លុកតែមួយ កន្លែងធំ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណលោកស្រី សៀង សុវិដា។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែសហភាគារបស់ខ្ញុំមានសំណួរមួយចំនួនសួរបន្ថែមបន្តលោកប្រធាន។ សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៤:២០:១០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ សូមជម្រាបសួរលោកស្រីដើមបណ្ដឹង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំមានសំណួរខ្លីមួយបញ្ជាក់ទៅលើការផ្ដល់សក្ខីកម្មរបស់អ្នកស្រីមុននេះ ជាមួយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ទាក់ទងទៅនឹងការបាត់ខ្លួន។ អ្នកស្រីបានឆ្លើយអំពីការផុតឆ្នាំ៧៧ ទៅមុខទៅបានមានការបាត់ខ្លួនច្រើន។ ហើយមុននេះអំមិញក៏អ្នកស្រីបានឆ្លើយថា នៅទំនប់១មករានោះ ពុំមានការបាត់ខ្លួនច្រើនទេ គឺអ្នកស្រីកត់សម្គាល់ទៅលើការដ្ឋានកន្លែងផ្សេង។ សំណួររបស់ខ្ញុំ ខ្ញុំចង់បញ្ជាក់ថា តើអ្នកស្រីដឹងថា ទំនប់១មករាចាប់ផ្ដើមកសាងនៅពេលណា ហើយបញ្ចប់នៅពេលណាទេ? អ្នកស្រីបានបញ្ជាក់អំពីពេលវេលាដែលអ្នកស្រីចូលមកធ្វើការរួចហើយ ហើយនិងបញ្ចប់ទៅវិញ ប៉ុន្តែខ្ញុំចង់ដឹងអំពីការចាប់ផ្ដើមនៃការកសាងទំនប់នោះតែម្ដង បើអ្នកស្រីដឹងអាចជម្រាបបានសូមអញ្ជើញ។

[១៤:២១:២៥]

**លោកស្រី សៀង សុវិដា៖**

**ឆ៖** ចាស ខ្ញុំដូចជាអត់ដឹងថា គេចាប់ផ្ដើមពីពេលណា។ ខ្ញុំមកធ្វើហ្នឹង គេមានគេធ្វើមុខខ្ញុំរួចទៅហើយ។ នៅពេលដែលខ្ញុំត្រឡប់ទៅវិញ ការដ្ឋានហ្នឹងក៏អត់ទាន់មានហើយអស់ដែរ នៅទៀត។ អ៊ីចឹងគេឲ្យពួកខ្ញុំត្រឡប់ទៅជួយធ្វើការនៅខាងស្រុកពួកខ្ញុំវិញ តែនៅនេះច្រើនខាងពួកបារាយណ៍ តាំងគោកពួកអីគេនៅបន្តទៀត ខ្ញុំអត់ដឹងទេ។ គេនៅស្រុកជិតៗហ្នឹង គេអាចចេញចូលផ្ទះគេបានណ៎ា ឧទាហរណ៍ថាគេនៅជិត។ ខ្ញុំឆ្ងាយ ពេលខ្ញុំទៅអត់ទាន់ហើយទេ ទំនប់ហ្នឹងអត់ទាន់សម្រេច។ ខ្ញុំអត់ -- កន្លែងហ្នឹងលោក ខ្ញុំអត់ដឹងច្បាស់ដែរ។

**សះ** អ្នកស្រីអាចបញ្ជាក់បានទេថា នៅពេលដែលអ្នកស្រីចេញពីការដ្ឋានហ្នឹង ចេញតែម្នាក់ឯង ឬក៏ចេញជាកងទាំងស្រុកទាំងមូលរបស់អ្នកស្រីតែម្តងបាទ?

**ឆះ** ចាស ចេញទាំងអស់ ទាំងស្រុកទាំងអស់។

**សះ** បាទ សូមអរគុណ។ ទាក់ទងនឹងចំណុចមួយទៀត ដែលអ្នកស្រីបញ្ជាក់អំពីការស្ម័គ្រចិត្តរបស់អ្នកស្រីមកធ្វើពលិកម្មក្នុងការមកធ្វើការងារក្នុងការដ្ឋានទំនប់១មករា។ ដោយអ្នកស្រីគិតឃើញថា វាអាចជាការជួយបន្ធូរភាពតានតឹងនៅក្នុងគ្រួសាររបស់អ្នកស្រី ដោយសារថាមានអ្នកទៅធ្វើការនៅក្នុងសមរភូមិក្តៅណាមួយអ៊ីចឹង បាទ។ ខ្ញុំចង់សួរអ្នកស្រីថា តើមានហេតុផលអ្វីដែលអាចឲ្យអ្នកស្រីគិតឃើញពីចំណុចនេះ នៅក្នុងខណៈពេលដែលអ្នកស្រីមានវ័យត្រឹម១២ឆ្នាំនៅពេលនោះបាទ?

[១៤:២៣:១៩]

**ឆះ** នាងខ្ញុំគិតៗថា ប្រធានកង ឬក្រុមនៅក្នុងភូមិជាមួយហាក់ដូចជា គាបសង្កត់ពួកប្រជាជន ១៧មេសា ទាំងប្រជុំទាំងអីក៏ដោយ ដូចជា ចង់ផ្តាច់ការជាមួយប្រជាជន ១៧មេសាខ្លាំងពីរឿងការងារ។ ហើយមានគេស៊ើបសួរៗពីប្រវត្តិអ្នកទីក្រុងភ្នំពេញហ្នឹង ពេលប្រជុំឡើងថា យើងធ្វើអី យើងរាយការណ៍ គេយកទៅរៀនសូត្រអីអ៊ីចឹង ឲ្យធ្វើការនេះនោះ។ ហើយខ្ញុំដើរជាមួយក្មេងកូនអ្នកស្រុកហ្នឹងដែរ ជួនកាលគេអាចមានដំណឹង គេនិយាយថា ឥឡូវអត់បានទេ យើងត្រូវតែខំធ្វើការ បើអត់ខំធ្វើការគ្រួសារណាអត់ខំធ្វើការ គេនឹងជម្លៀសឆ្ងាយទៅកន្លែងចាញ់ កន្លែងអីអ៊ីចឹង បើយើងធ្វើការល្អ គេទុកតែអ្នកណាចំណាប់ៗក្នុងភូមិទេ។ អ្នកមិនចំណាប់ប្រហែលគេបញ្ជូនចេញហើយ ព្រោះអីគេធ្វើផ្ទះធ្វើអីទៅក្នុងទៀត គេអត់ឲ្យនៅភូមិណែនគ្នាអ៊ីចឹង ហូបអង្ករហូបស្រូវអីវាអត់គ្រប់ អត់គ្រាន់អីអ៊ីចឹងបែងចែកទៅឆ្ងាយទៀតហើយ។ អ៊ីចឹងខ្ញុំមើលសភាពការណ៍ដូចជាតឹងទៅៗ ហើយដូចធ្វើបាបមនុស្សដូចជា អង្គាល់ហ្នឹងវាចាប់ផ្តើមធ្វើបាបដែរ ព្រោះអីខ្ញុំឃើញមានវៀតម្នាក់នៅក្នុងភូមិខ្ញុំ គាត់ឈ្មោះ លី ថុង ពេលហ្នឹងខ្ញុំនៅកងនៅចល័តភូមិទេ ខ្ញុំមិនទាន់ទៅទេ។ ពេលហ្នឹង ខ្ញុំឃើញពួកហ្នឹងអត់បានទេ ឥឡូវល្មមៗគេចាប់គេធ្វើបាបសម្លាប់ហើយ ហើយវៀត លី ថុង ហ្នឹងខ្ញុំនៅក្មេង ខ្ញុំអត់ដឹង ខ្ញុំចេះតែលេងជាមួយគាត់ហ្នឹងណា ពេលមកធ្វើការ ឃើញខ្លួនគាត់វើសុះ ខ្ញុំថា គាត់ចិនទេ និយាយខ្មែរអត់ច្បាស់ទេ និយាយខ្មែរប៉ែឡាំៗ។ ខ្ញុំថា ពូលី ថុង ម៉េចខ្លួនពូឯងម៉េចអ៊ីចឹង? គាត់ថា "ឆ្មាឆ្កែក្រញៅខាំគាត់"។ ដល់ហើយមានកូនអ្នកស្រុកខ្សឹបខ្ញុំថា "មិនមែនទេ គេយក -- យប់មិញហ្នឹងយកគ្នាទៅវៃសម្លាប់នៅកន្លែងដើមឈើកប់ម៉េចហ្នឹង" ហើយក៏ លី ថុង ហ្នឹងគ្នានៅរស់វិញទៅ ព្រឹកឡើងទៅធ្វើការ។ អ្នកវៃហ្នឹងប្រាប់ឈ្មោះអី? ថាឈ្មោះ

ឈឹង ឈ្មោះ អាប៊ុឈឹង។ ខ្ញុំឧស្សាហ៍ដឹង ព្រោះខ្ញុំនៅភូមិ ខ្ញុំដើរជាមួយក្មេងៗ មានរឿងអីពួកហ្នឹងគេចូលចិត្តប្រាប់ខ្ញុំ។ ដឹងរឿងគេនៅជិតហ្នឹង គេខ្សឹបខ្សៀវ តែអត់ឲ្យឮដល់ប្រធានធំៗណា ឮតែអ្នកគ្នាឯងក្រោមហ្នឹង។ រួចខ្ញុំក៏មានចិត្តនឹកឃើញអាណិតពូ លី ផុង អត់មាត់ទៅវិញ។ ដំបូងខ្ញុំអត់ដឹងស្មានតែគាត់ឆ្មាអីខាំមែន។ ដល់ហើយខ្ញុំដឹងបានរឿងហ្នឹងមួយ។ ហើយរឿងមួយទៀត--

[១៤:២៥:២៦]

**ស៖** បាទ--

**ឆ៖** ចាស ខ្ញុំសូមកាត់បន្តិច។ សូមរឿងមួយទៀត បងថ្លៃខ្ញុំ បងថ្លៃរបស់បងស្រីខ្ញុំ គាត់ចល័តតំបន់។ គាត់ជិះកាណូតកាត់តាមហ្នឹងមក ឮសួរ ដូចថាសុំគេចូលភូមិ។ ដល់ចូលភូមិដឹងថាបងស្រីខ្ញុំគេចាប់ជិតរៀបការ គាត់ចងដៃក្រម៉ាមួយ។ ហើយដល់ពេលហើយកាណូតគេទៅៗ គាត់នេះគេវៃសម្លាប់នៅវត្តឫស្សីកែវ អ្នកភូមិនិយាយប្រាប់។ ចាស ខ្ញុំដឹងបានប៉ុណ្ណឹង។

**ស៖** បាទ រឿងហ្នឹងនៅឆ្នាំណាដែរ លោកស្រីនិទានអំពីមិញហ្នឹង?

**ឆ៖** រឿងហ្នឹងនៅឆ្នាំ៧៧ ប្រហែលជាដើមឆ្នាំ៧៧ មុនខ្ញុំទៅ១មករា។ បើខ្ញុំត្រឡប់មកវិញ ខ្ញុំបាននៅផ្ទះតែ៣ថ្ងៃហ្នឹង ហើយខ្ញុំបែករហូតដល់ថ្ងៃហ្នឹង។

**ស៖** បាទ អ្នកស្រីអាចបញ្ជាក់ពីស្ថានភាពដែលថា មានអ្នកខ្សឹបប្រាប់អ្នកស្រីហ្នឹង ហើយអ្នកណាពិតប្រាកដដែលនិយាយជាមួយអ្នកស្រីអំពីការត្រូវធ្វើការងារ ដើម្បីគេចផុតពីការជម្លៀសទៅកន្លែងផ្សេងហ្នឹង កន្លែងឆ្ងាយ?

[១៤:២៦:៥០]

**ឆ៖** គេប្រាប់ខ្ញុំតែភាពតានតឹង និងគាបសង្កត់នៅក្នុងភូមិរឿងធ្វើបាបអ៊ីចឹងទេ។ តែគំនិតគិតថាខ្ញុំគិតថាទៅឆ្ងាយហ្នឹងដើម្បីឲ្យរួចខ្លួនហ្នឹង គឺគំនិតខ្ញុំគិតខ្លួនខ្ញុំ។ គិតថាខ្ញុំត្រូវតែឲ្យមានកម្លាំងស្រួចមួយនៅក្នុងផ្ទះ ព្រោះអីប៉ាខ្ញុំអត់មានកូនប្រុសទេ ហើយគាត់ចាស់ៗហើយ។ ហើយបងស្រីខ្ញុំគាត់រៀបការអ៊ីចឹងបងខ្ញុំស្រីខ្ញុំអាចនៅភូមិជាមួយម្ដាយខ្ញុំបាន។ អ៊ីចឹងខ្ញុំអាចចេញទៅអ៊ីចឹងទៅ ឬក៏ចង់អាចក្រែងលោបានជួបបងប្អូនដែលមកជុំគ្នាគ្រប់ខេត្តទាំងអស់អ៊ីចឹង ក៏មានចិត្តអ៊ីចឹងមួយ។ តែនៅភូមិ បើគេបញ្ជូនទៅធ្វើការនៅព្រៃទៀត ក៏បាត់ពីផ្ទះ តែនៅតែក្នុងព្រៃ។ អ៊ីចឹងទៅខាងនេះ ក្រែងលោអាចជួបបងប្អូនអីខ្លះ។ ចិត្តអ៊ីចឹង ហើយ--

**ស៖** សំណួររបស់ខ្ញុំទាក់ទងនឹងឈ្មោះមនុស្ស បើសិនជាអ្នកស្រីស្គាល់ ហើយអាចជម្រាបបាន

ថាអ្នកណាដែលជាអ្នកជួយណែនាំអ្នកស្រីឲ្យអ្នកស្រីសម្រេចក្នុងការធ្វើពលិកម្មផ្សេងៗហ្នឹង?

**ឆ៖** នាងខ្ញុំអត់ចាំដែរ ប៉ុន្តែគ្រាន់ថានាងខ្ញុំបាននិយាយជាមួយកូនក្មេងអ្នកស្រុកហ្នឹងប្រាប់ខ្ញុំហ្នឹង តែឥឡូវហ្នឹង គេក៏អ្នកខ្លះក៏នៅរស់ អ្នកខ្លះក៏ស្លាប់ តែគេមិននិយាយតែម្នាក់ទេ គេនិយាយច្រើនគ្នាប្រាប់។ គេធ្លាប់ធ្វើកងកុមារជាមួយខ្ញុំហ្នឹង ចាស។

[១៤:២៨:១១]

**ស៖** កុមារដែលមានវ័យប្រហាក់ប្រហែលអ្នកស្រីបាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** បាទ សូមអរគុណ។ ឈ្មោះ លី ថុង ដែលលោកស្រីរៀបរាប់អំមិញហ្នឹង រឿងហ្នឹងគឺកើតឡើងនៅក្នុងសហករណ៍របស់អ្នកស្រីមែនទេ?

**ឆ៖** នៅក្នុងភូមិនាងខ្ញុំផ្ទាល់។

**ស៖** អ្នកស្រីអាចបញ្ជាក់បានទេ ថាភូមិអី? ភូមិឬស្សី--

**ឆ៖** ភូមិឫស្សីកែវលើ។

**លោក គង់ សំអុន៖**

បាទ សូមសូមអរគុណ។ លោកប្រធានខ្ញុំអស់សំណួរ លោកស្រី។

[១៤:២៨:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រី សៀង សុវិដា ជាចុងក្រោយនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកស្រីប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត និងសមូហភាពពីជនជាប់ចោទ និងអំពីព្យសនកម្មដែលមានចំពោះលោកស្រីជាអាថ៌ការខូតខាតខាងរាងកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ។ ហើយប្រសិនបើមាន បើលោកស្រីមានបំណងធ្វើដូច្នេះ។

សូមអញ្ជើញ!

**លោកស្រី សឿង សុវិដា៖**

នាងខ្ញុំអាចមានសំណួរ ចាស ខ្ញុំចង់សួរថា លោកមេខ្មែរក្រហមទាំងអស់--

**ប្រធានអង្គជំនុំ៖**

លោកស្រីមិនអាចសួរផ្ទាល់ជាមួយគាត់បានទេ សួរតាមរយៈប្រធានអង្គជំនុំជម្រះ គឺតាមរយៈយើងណ៎ា។

[១៤:៣០:០៩]

**លោកស្រី សឿង សុវិដា៖**

នាងខ្ញុំសូមសួរលោកប្រធានជំនុំជម្រះសាលាក្តីខ្មែរក្រហម ខ្ញុំចង់ដឹងថា តើលោកមេដឹកនាំខ្មែរក្រហមទាំងអស់ គាត់បានឃោសនាថា គាត់ជួយជាតិ ជួយប្រជារាស្ត្រ។ ផ្ទុយស្រឡះនៅពេលដែលគាត់បានជ័យជម្នះ និងអំណាចហើយ បែរជាគាត់កាប់សម្លាប់ធ្វើបាបប្រជារាស្ត្រខ្លួនឯង បង្ខំធ្វើការ បង្អត់អាហារ ហើយគាត់ទុកប្រជារាស្ត្រជាសត្រូវស្សូរពូជរបស់គាត់។ ប្រហែលគាត់ -- ខ្ញុំយល់ថា គាត់ទាំងអស់គ្នាហ្នឹងប្រហែលជាទុកប្រជាជន១៧មេសាហ្នឹង ឬក៏គាត់មានគំនុំអ្វីជាមួយប្រជាជន១៧មេសា បានគាត់ធ្វើបាបយ៉ាងហ្នឹង ហើយគាត់ធ្វើហ្នឹងដើម្បីអ្វី? ហើយគាត់ធ្វើហ្នឹងដើម្បីអ្នកណា? ខ្ញុំចង់ដឹង ហើយខ្ញុំសូមឲ្យគាត់ចង់រាយការណ៍ឲ្យ -- រៀបរាប់ឲ្យរឿងហ្នឹងឲ្យល្អិតល្អន់ ដើម្បីឲ្យពួកកូនខ្មែរជំនាន់ក្រោយបានដឹងច្បាស់។ បើមិនដូច្នេះទេ ការកាត់ក្តីនេះហាក់ដូចជា អត់បានប្រយោជន៍អ្វីទាំងអស់ ហើយយុត្តិធម៌ក៏គ្មានឲ្យម៉ែប៉ាខ្ញុំ បងប្អូនទាំងអស់ ប្រជារាស្ត្រនៅលើទឹកដីខ្មែរទាំងអស់ដែលបានទទួលរងគ្រោះដោយសាររឿងហ្នឹង។ ពេលអ្នកទាំងអស់ហ្នឹងស្លាប់មិនដឹងជាឈឺចាប់ប៉ុនណាទេ ខ្ញុំចង់បានចម្លើយពីគាត់តែប៉ុណ្ណឹង។ ហើយឲ្យគាត់រៀបរាប់ ហើយឲ្យច្បាស់ឲ្យពិត មិនឲ្យរៀបរាប់ទាំងខុសមកឲ្យពួកខ្ញុំស្តាប់ទេ។ គាត់ចេះតែប្រកែកថា គាត់អត់បានដឹង អត់បានអី ខាងថ្នាក់ក្រោមធ្វើ។

[១៤:៣១:៥០]

អ៊ីចឹងពេលជំនាន់នោះគាត់មានតែតំណែង តែគាត់អត់តួនាទី ឬក៏អត់មានអំណាចអ្វីទាំងអស់ហើយយ៉ាងម៉េច ខ្ញុំឆ្ងល់។ តែគាត់មិនអាចលម្អិត ខ្ញុំចង់ឲ្យលោកព្រះរាជអាជ្ញា ចៅក្រមជួយឲ្យគាត់មានពេលរាយឲ្យបានល្អិតល្អន់រឿងហ្នឹងឲ្យបានច្បាស់ សម្រាប់ទុកឲ្យប្រវត្តិសាស្ត្រខ្មែរនេះ ឲ្យបានកូនខ្មែរក្រោយដឹងផង។ ហើយសូមឲ្យជួយធ្វើមានដូចជាបណ្ណាល័យទុកតម្កល់ប្រវត្តិសាស្ត្រខ្មែរជំនាន់ប៉ុល ពត ហើយនិងរឿងប្រវត្តិ និងសួន្យនេះ កាត់ក្តីនេះក្នុងតុលាការពី០១ ដល់សួន្យប៉ុន្មានចប់នេះ សូមឲ្យមាននៅ

ក្នុងហ្នឹង តម្កល់ទុកបណ្ណាល័យផង កុំឲ្យបាត់បង់ក្នុងប្រវត្តិសាស្ត្រនេះ។ គឺមិនដែលជួបទេក្នុងពិភពលោក។ ហើយខ្ញុំសូមឲ្យគាត់ឆ្លើយនឹងសំណួរខ្ញុំផង ព្រោះអីខ្ញុំវាហាក់ដូចជាឆ្ងល់ ធ្វើអ្វីៗដើម្បីអ្នកណាធ្វើដើម្បីអ្វី ហេតុអីក៏សម្លាប់សត្រូវស្បូវពូជ ក៏គំនុំពី -- គំនុំ ខ្ញុំគិតខ្លួន ខ្ញុំថាប្រហែលជាគំនិតបុគ្គលខ្លាំងជាងជំនាន់៣ឆ្នាំ៨ខែ។ អ្នកនៅទីក្រុងភ្នំពេញទាំងអស់មិនមែនជា គ្នាចង់រស់នៅគ្រាប់ប្លោងសឹងរាល់ថ្ងៃ ខ្ញុំក៏នៅទីនោះដែរ ពេលបែកហ្នឹង។ គ្រាប់ប្លោងរាល់ថ្ងៃ រាល់ពេលខ្ញុំទៅរៀន ជួនកាលខ្ញុំអត់បានទៅរៀនទៀត ពេលខ្លាំងនៅផ្ទះ។ ហើយនៅក្នុងនោះក៏ខ្ញុំដឹងរឿងដែរ មានអ្នកខ្មែរនៅក្នុងនោះ ក៏មានអ្នករនុក ជួនកាលធ្វើការពាក់ស័ក្តិអីនៅក្នុងជំនាន់ នល់ នល់មែន តែឲ្យការណ៍ច្បាស់ៗទៅខាងក្រៅ មានទាំងពីថ្នាំពេទ្យ មានទាំងពីម្ហូបអាហារបញ្ជូនទៅជួយ។ អ៊ីចឹងអ្នក១៧មេសាហ្នឹង ក៏មានអ្នកចូលរួមក្នុងការតស៊ូហ្នឹងដែរ តែអត់មាននេះគ្នា យកគ្នាទៅដាក់គុកនិងសម្លាប់ ខ្ញុំបានស្គាល់ពូៗច្បាស់ទៀត ដែលធ្លាប់ធ្វើនេះជាមួយប៉ាខ្ញុំ។

[១៤:៣៣:៣១]

ហើយដូចជាប៉ាខ្ញុំអីក៏មិនដែលបំពានអ្នកណាដែរ ហើយធ្វើបាប។ ខ្ញុំគ្រាន់តែចង់បានយុត្តិធម៌ឲ្យបានឆាប់រហ័ស ពីព្រោះគាត់ទាំងអស់គ្នានេះចាស់ៗហើយ បើគាត់បាត់បង់គាត់ទាំងអស់គ្នាហ្នឹងទៅរឿងហ្នឹងវាអត់មានការពិតអីមកឲ្យជនរួមជាតិ ហើយនិងអ្នកដែលគ្នាបានរងគ្រោះទាំងអស់គ្នានេះ។ ហើយពួកអ្នកខ្ញុំទាំងអស់គ្នា និងប្រជារាស្ត្រទាំងអស់គ្នាហ្នឹង វាអត់បានប្រយោជន៍។ ដំបូងគ្រាន់តែឮថាតុលាការបើកមក ពួកខ្ញុំអរៗខ្លាំងណាស់។ ហើយពេលដំបូង ពេលខ្ញុំគិតថា អ្នកមេដឹកនាំខ្មែរក្រហមចូលមក ខ្ញុំអត់យល់ច្បាស់ ខ្ញុំថាខ្ញុំត្រូវតែ -- ខ្ញុំចង់កាប់សម្លាប់គាត់ទៅវិញ ខ្ញុំចង់ធ្វើយ៉ាងម៉េចឲ្យខ្ញុំអស់ចិត្តនៅពេលបំផ្លាញឪពុកម្ដាយខ្ញុំ ទុកឲ្យខ្ញុំនៅកំព្រា មិនមែនធម្មតាទេជីវិតក្មេងកំព្រា។ អ៊ីចឹងថាជីវិតខ្ញុំដែលវេទនាឯកាតាំងពីខ្ញុំ និងកូនចៅខ្ញុំ និងអ្នកទាំងអស់គ្នាក៏ដោយសារមេដឹកនាំខ្មែរក្រហមដែរ។ បើគាត់គ្មានសមត្ថភាពទេ ហេតុអីក៏គាត់ទៅកាន់អំណាច គាត់ធ្វើផ្តេសផ្តាសអ៊ីចឹង។ ហើយគាត់ថា គាត់អត់ដឹងទេនៅលើ អ៊ីចឹងម៉េចក៏គាត់មិនចុះទៅមើលប្រជាជននៅក្រោមផងឲ្យដល់ ដិតដល់ល្អិតល្អន់ផង។ អ្នកដឹកនាំ ពាក្យថា "ដឹកនាំ" គឺមិនធម្មតាទេ គឺត្រូវមើលល្អិតល្អន់។ សូម្បីតែម៉ែឪក្នុងផ្ទះកូន ក៏យើងត្រូវមានមេ -- ធ្វើមេផ្ទះមិនធម្មតាទេ។ ខ្ញុំពេលខ្លះ ខ្ញុំខឹង ខ្ញុំមិនដឹងនិយាយថាម៉េច តែដល់ដំណាក់កាលនេះ ខ្ញុំក៏មិនដឹងទុកឲ្យតុលាការដោះស្រាយ។ ហើយខ្ញុំក៏ធ្លាប់សុំបន្ថែមតិច ខ្ញុំក៏ធ្លាប់ឮប៉ាខ្ញុំគាត់ធ្លាប់និយាយពីលោក ខៀវសំផន គាត់លើកមុនគាត់ឧស្សាហ៍និយាយ គាត់ថា គាត់ចប់ខ្មែរឥស្សរៈមក ពួកគាត់ចង់ចូលព្រៃដែរ

តស៊ូវណ្ណៈតស៊ូអីអ៊ីណា ជិះជាន់អី ឮគាត់និយាយជាមួយលោក ហ៊ូ យន់, ហ៊ូ នឹម ហើយឈ្មោះលោកគាត់ដែរ។ គាត់ថាគាត់ជាមនុស្សល្អទេ តែហេតុអ្វីបានជាជំនាន់នេះវាទៅជាអ៊ីចឹងទៅវិញ? ខ្ញុំអត់យល់។ ហើយពេលនោះ ប៉ាខ្ញុំថា គាត់ឈប់ហើយ ឈប់ច្បាំងតស៊ូ គាត់អស់ចិត្តហើយ។ អ៊ីចឹងមកទៅ បានឆ្នាំ ៧០ ហ្នឹងទ្រង់ ចន្ទរង្សី ឲ្យគាត់នៅក្នុងបន្ទាយហ្នឹង កាន់លុយកាន់អីធម្មតាវិញ។

[១៤:៣៥:២៨]

ហើយរឿងរ៉ាវទាំងឡាយ ប៉ាខ្ញុំនិយាយច្រើនណាស់។ ហើយខ្ញុំចេះតែឆ្ងល់ ចុះហេតុអីបើមានគាត់ជាមនុស្សអ៊ីចឹងដែរ ហេតុអីក៏គាត់មិនមើលប្រជាជនយើងវាទទួលរងគ្រោះយ៉ាងម៉េចខ្លះ? អត់ដឹងអីសោះអ៊ីចឹង។ ហើយអ៊ីចឹងតាំងខ្លួនធ្វើជាអ្នកដឹកនាំធ្វើអ្វី? អានេះបើសិនជារឿងពិតដូចខ្ញុំថាជាម្ដាយខ្ញុំ បងខ្ញុំ ប៉ាខ្ញុំទាំងអស់ សាច់ខ្ញុំអីទាំងអស់ អ៊ីចឹងខ្ញុំឈឺចាប់ណាស់ តែអ្នកដទៃ ឬគេអត់ធ្លាប់អ៊ីចឹង គេគ្រាន់តែឃើញ អូ៎! អាណិតណាស់! បានតែពាក្យប៉ុណ្ណឹង បើប៉ះខ្លួនឯងវិញគឺឈឺចាប់ណាស់។ ដូចយើងដើរទៅកូនយើងបងប្អូនយើង បុកគេបុកផាំង យើងញ័ររន្ធត់ណាស់ ខ្លួនយើងមិនអាចទៅធ្វើម៉េចកើតទេ តែបើអ្នកដទៃឃើញ "អាណិតណាស់"។ បានតែថាពាក្យហ្នឹង ខ្ញុំអត់ចង់បានពាក្យហ្នឹងទេ ខ្ញុំចង់យកយុត្តិធម៌។ ខ្ញុំឈឺចាប់ខ្លាំងណាស់ ពេលហ្នឹងខ្ញុំក៏មិនចង់រស់។ គេបែកភ្នំពេញមក គេហៅខ្ញុំចូលធ្វើទាហាន តែមីងគាត់ថា "កុំអី ត្រឡប់មកភ្នំពេញមក"។ ខ្ញុំស្រឡាញ់ឪពុកម្ដាយខ្ញុំលើសជីវិតខ្ញុំ បើសិនគេថា ឲ្យខ្ញុំទៅសម្លាប់ខ្ញុំចោល ទុកឪពុកម្ដាយខ្ញុំរស់ ខ្ញុំយកជីវិតខ្ញុំប្ដូរហើយ។ ខ្ញុំមិនរស់ឲ្យឪពុកម្ដាយខ្ញុំស្លាប់ទេ។ សូម្បីតែនៅជំនាន់នោះ គេបង្អត់បាយគេធ្វើយ៉ាងម៉េច ខ្ញុំដើរធ្វើសព្វបែបយ៉ាងឲ្យបានម្ដាយឪពុកខ្ញុំពិសាព្រោះគាត់ទាំងពីរនាក់សុំសីល គាត់អត់ពិសាបាយល្ងាច។ ខ្ញុំតស៊ូ ខ្ញុំមិនដែល ខ្ញុំស្រឡាញ់គាត់ណាស់។ ខ្ញុំ ពេលខ្លះ ខ្ញុំអត់គិតថាខ្ញុំអត់ចង់បានសំណងអ្វីទាំងអស់។ ខ្ញុំចង់បានសំណងមកឲ្យធ្វើម៉េចឲ្យខ្ញុំបានធូរស្បើយចិត្ត មនុស្សណាដែលចុចសម្លាប់ឪពុកម្ដាយខ្ញុំ ខ្ញុំចាប់អ្នកហ្នឹងមកធ្វើ តែតាខ្ញុំគាត់ថា "កុំកូន អាពៀរ --" ហើយសិនបាត់ប៉ា គេសម្លាប់ពៀររំងាប់ដោយការមិនចងពៀរ។ ខ្ញុំក៏តាំងចិត្តស្ងប់ជារៀងរហូតមក។ ខ្ញុំគិតថា បើជីវិតខ្ញុំទំនេរ ខ្ញុំគិតរឿងហ្នឹង ខ្ញុំមិនអាចរស់ ខ្ញុំរស់នៅតែអារម្មណ៍ខ្ញុំមិនដូចគេទេ។ អ៊ីចឹងខ្ញុំត្រូវតែធ្វើអ្វីឲ្យជីវិតខ្ញុំរវល់។ ខ្ញុំសុំមីងពូខ្ញុំទៅរៀន ធ្វើការនេះធ្វើការនោះ មិនសូវឲ្យខ្លួនទំនេរទេ។

[១៤:៣៧:៣០]

ខ្ញុំមិនដឹងនិយាយប្រាប់ថាខ្ញុំឈឺចាប់ប៉ុនណាទេ។ ខ្ញុំ ទឹកភ្នែកខ្ញុំស្ទើរតែសឹងរាល់ថ្ងៃ ខ្ញុំនិយាយប្រាប់គេ បើអ្នកណាគេជឿក៏ជឿ។ កូនប្រុសខ្ញុំទេ អ្នកលបមើលឃើញ ឃើញតែខ្ញុំយំបិទទ្វារ។ តែអត់

មានអ្នកណាដឹងថាខ្ញុំពិបាកទេ ទាល់តែលបមើលឃើញ បើមិនលបមើលទេ គេអត់ដឹងទេ។

ខ្ញុំសុំឱ្យជួយបកស្រាយនឹងរឿងពិតហ្នឹងឱ្យពួកខ្ញុំស្តាប់ផង ខ្ញុំអត់ចង់បកស្រាយ និងការដោះសាខ្លួនដើម្បីឱ្យរួចខ្លួនណា។ ជីវិតម្នាក់ៗកើតមកគង់តែដល់ថ្ងៃស្លាប់ទេ មុននឹងស្លាប់ យើងចេះ យើងស្រឡាញ់ប្រជាជន ឱ្យកូនខ្មែរយើងដឹងប្រវត្តិសាស្ត្រពិតៗផង។ ខ្ញុំសុំតែប៉ុណ្ណឹងទេ ហើយក៏ខ្ញុំមិនចងពៀរអីទៀតដែរ គ្រាន់តែខ្ញុំសុំឱ្យវរណា ព្រោះអីចាស់ៗហើយ។ ហើយសំណាងណាស់ដែលបាននៅឃុំខ្លួននេះ នៅឃុំខ្លួនហើយ អត់មានពិបាកដូចពួកដែលគេសម្លាប់ គេកាត់ដៃកាត់ជើង គេឱ្យគ្នាអត់ដេកលើអីសព្វបែបសព្វយ៉ាង គាត់នៅម៉ាស៊ីនត្រជាក់ ពិសាស្រួលអីស្រួលទាំងអស់។ តែរឿងគ្រាន់តែរឿងពិតសូមជួយបកស្រាយ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ឬក៏លោកអត់មាន មានតែតំណែង លោកអត់មានសិទ្ធិអំណាច ឬយ៉ាងម៉េច? ពួកខ្ញុំចង់ឱ្យមានពេលវេលាឱ្យច្រើន ឱ្យលោកបកស្រាយឱ្យអស់។ អ៊ីចឹងប៉ុណ្ណឹងសិនហើយ ខ្ញុំក៏អស់សេចក្តីហើយ។

[១៤:៣៨:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី សៀង សុវិដា ថានៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីរនាក់ឆ្លើយបញ្ជាក់ដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួររបស់ -- អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហាររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងទៀត ពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីជនជាប់ចោទ។

នៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឱ្យជនជាប់ចោទ និង/ឬសហមេធាវីការពារក្តីជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ ដែលសួរដោយអង្គជំនុំជម្រះ ឬភាគីពាក់ព័ន្ធ។

រហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហាររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប មកយល់ព្រមឆ្លើយតបនៅនឹង

សំណួររបស់អង្គជំនុំជម្រះ ឬភាគីនៅឡើយទេ។ សូមលោកស្រីជ្រាប។

បាទ សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា បានដល់ទីបញ្ចប់ហើយ។ ហើយជាបន្តទៀត អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សាក្សីដែលលោករហស្សនាម 2-TCW-804 សូមភាគីជ្រាប។ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី សៀង សុវិដា។ សវនាការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។

យ៉ាងម៉េចទៅលោកស្រីមេធាវី?

[១៤:៤១:១៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមអន្តរាគមន៍ពេលនាទីចុងក្រោយ ព្រោះខ្ញុំដឹងថា លោកស្រី សុវិដា គាត់បានត្រៀមថ្លែងទុក្ខវេទនារបស់គាត់។ ខ្ញុំគិតថា អម្បាញ់មិញនេះ ប្រហែលជាមិនបានធ្វើទេ គាត់ចង់ធ្វើ ក៏ប៉ុន្តែដូចជាមិនបានរៀបរាប់ទេ។ អ៊ីចឹងខ្ញុំសូមការអនុញ្ញាត សូមឲ្យលោកប្រធាន សួរបញ្ជាក់គាត់ម្តងទៀត ថាតើគាត់ -- អម្បាញ់មិញនេះ គាត់បានអានឯកសារដែលគាត់រៀបរាប់អំពីការរងទុក្ខវេទនា និងព្យសនកម្មរបស់គាត់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហើយឬនៅ? ព្រោះថាឃើញអម្បាញ់មិញនេះ គាត់ដូចជាគ្រាន់តែបានសួរសំណួរទៅជនជាប់ចោទតែប៉ុណ្ណឹងទេ ហើយមិនបាននិយាយលម្អិតទេ។ ដូច្នេះខ្ញុំសូមឲ្យលោកប្រធានអនុញ្ញាតឲ្យគាត់មានលទ្ធភាពអានអត្ថបទ ដែលគាត់បានត្រៀមទុកលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកស្រីធ្វើទេ ព្រោះយើងបានប្រគល់នាទីជូនលោកស្រីរួចហើយ បានបញ្ជាក់ច្បាស់លាស់ណាស់ ហើយលោកស្រីនិយាយយ៉ាងវែង សំណួរយ៉ាងវែង។ អ៊ីចឹងហើយបានជាយើងយល់ថា ព្រោះលោកស្រីថាចប់ហើយ តើលោកស្រីធ្វើទេ សេចក្តីថ្លែងរៀបរាប់ពីទុក្ខសោកវេទនាដែរឬទេ នាពេលនេះ? បើត្រូវការធ្វើ សូមអញ្ជើញ!

**លោកស្រី សៀង សុវិដា៖**

នាងខ្ញុំដូចជាបានរៀបរាប់តាំងពីព្រឹក មកដល់ពេលនេះ ដូចជាច្រើនណាស់ដែរហើយ។ តែរឿង

នាងខ្ញុំចង់រៀបរាប់ហ្នឹង ក៏ដូចដំណើររឿងដែលខ្ញុំបាននិយាយពី ជម្លៀសពីមួយដំណាក់ទៅមួយដំណាក់ និងការវេទនារបស់ក្រុមគ្រួសារនាងខ្ញុំ។ ដូច្នេះនាងខ្ញុំនិយាយកាត់ៗ ចន្លោះចុះកុំឲ្យខាតពេល។ អ៊ីចឹងនាងខ្ញុំ កាលចេញមកខ្ញុំបាននិយាយថា ថ្ងៃ១៨មេសា ម៉ោងប៉ុន្មានហ្នឹង ចេញពីភូមិមួយចូលភូមិមួយហ្នឹង មកដល់ឫស្សីកែវ។ ខ្ញុំនិយាយចន្លោះ ខ្ញុំចង់និយាយថា និយាយត្រឹមនៅកាលដែលគេធ្វើបាបក្រុមគ្រួសារនាងខ្ញុំ នៅភូមិឫស្សីកែវលើហ្នឹង។ ឪពុកខ្ញុំគាត់ហាក់ដូចជាដឹងខ្លួនថា នៅជំនាន់ហ្នឹង គេតាមដានមន្ត្រីរាជការ ឬក៏អ្នកបញ្ញវន្ត ឬអ្នកអីអ៊ីចឹងដែរ គេតាមសង្កេតមើល។ ត្បិតថាយើងភរគេមែន ថាយើងអត់ធ្វើហ្នឹងមែន យើងធ្វើស្រែចម្ការ លក់ដូរ ក៏ប៉ុន្តែគេតាមសង្កេតឃើញថា តែគាត់ប្រឹងធ្វើការណាស់ ខ្ញុំអាណិតប៉ាខ្ញុំណាស់ គាត់ធ្វើការ គាត់គ្មានឈប់មួយថ្ងៃណាទេ។ រហូតដល់ពួកអ្នកស្រុកហ្នឹង ចាស់ៗហ្នឹងតាំងប៉ាខ្ញុំធ្វើជាប្រធានមើលខុសត្រូវខាងប្រជាជនថ្មី ខាងធ្វើចប ធ្វើបង្កី ធ្វើអ្វីៗនៅសិប្បកម្មហ្នឹង។ ហើយពេលឪពុកខ្ញុំគាត់ឈឺ ពេលឪពុកខ្ញុំទៅដល់ឫស្សីកែវលើ ឪពុកខ្ញុំមានជំងឺជាទម្ងន់ ពេលហ្នឹងនៅក្នុងឆ្នាំ៧៦។ ខ្ញុំពីរនាក់បងខ្ញុំនៅការដ្ឋានមួយ គេហៅ ការដ្ឋានស្ទឹងធំ។ ពេលនោះដំណឹងថាប៉ាខ្ញុំឈឺ គេឲ្យដំណឹងមកតាមពួកអ្នករទេះដែរ។ ពេលនោះប៉ាគាត់ ពួកខ្ញុំទាំងពីរក៏សុំគេមកទាំងពីរ គេអត់ឲ្យ គេឲ្យមកតែមួយ។ ដល់ក្រោយមកគេអាណិត ឃើញយំឱបបងប្អូន ក៏គេឲ្យពួកខ្ញុំមកទាំងពីរមក និងការដ្ឋានជាច្រើនទៀតពីរនាក់បងប្អូន។ ដល់ក្រោយមក នាងខ្ញុំ -- ចុងក្រោយដែលនាងខ្ញុំឈឺចាប់ជាងគេ គឺនាងខ្ញុំឈឺចាប់នៅពេលដែលគេយកគាត់ទៅសម្លាប់។

[១៤:៤៤:៥១]

ពេលដែលបង ខ្ញុំរៀបរាប់ច្រើនណាស់ ខ្ញុំរៀបរាប់កាត់ត្រឹមហ្នឹងចុះ បងស្រីមួយឈ្មោះ បងសៀង ហ្នឹងគាត់ដើរកាត់ គាត់មកលបឃើញ។ ហើយគាត់តាមទៅលបមើលកន្លែងគេសម្លាប់ទៀត ហើយនៅពេលដែលគាត់ -- គេសម្លាប់ទាំងអស់គ្នាហើយ គេប្រមូលទ្រព្យសម្បត្តិយកទុក យកដាក់អស់ហើយ ប្រជាជនហ្នឹងគ្រប់គ្នាទាំងអស់។ ដល់ពេលថ្ងៃសម្លាប់ហ្នឹង ខ្ញុំចង់និយាយពីព័ត៌មានមួយនៅសល់ពីរនាក់រស់ ពេលនាងខ្ញុំទៅធ្វើបុណ្យឆ្នាំ២០០០គត់ មានពីរនាក់នៅរស់ ឈ្មោះ វីន មួយ ឈ្មោះលោកគ្រូខុម មួយគាត់នៅសហរដ្ឋរាល់ថ្ងៃ។ គាត់មើលពីសកម្មភាពហ្នឹងទាំងអស់ គាត់ទៅធ្វើបុណ្យមុនខ្ញុំប្រហែលពីរបីថ្ងៃ។ ដល់ខ្ញុំត្រឡប់ទៅវិញ មានលោកថាមានគេនៅរស់ពីរនាក់កាលជំនាន់ៗហ្នឹង។ ខ្ញុំក៏ចង់ព្យាយាមសួរនាំ ចង់ដឹងថាសភាពការណ៍សម្លាប់ហ្នឹងរបៀបម៉េចៗ តែខ្ញុំអត់ដែលបានជួបគាត់សោះមកដល់ថ្ងៃហ្នឹង។

ខ្ញុំមិនចង់ឲ្យខាតពេលទេ ពីព្រោះអីការទុក្ខសោករូបខ្ញុំ ក៏ដូចប្រជាជនគ្រប់គ្នាក្នុងរបប៣ឆ្នាំហ្នឹង ទាំងអស់គ្នាដែរ។ បើនិយាយទឹកភ្នែករហូត ចង់ស្ទះហើយខ្ញុំនេះ ញ័រសាច់ទទ្រើកហើយ។ ខ្ញុំអត់ចង់និយាយអីច្រើនទេ ចង់ថាទុក្ខសោកដូចគ្នាទាំងអស់ គឺខ្លាំងណាស់ មកលើគ្រួសារខ្ញុំៗដូចបានរៀបរាប់អីចឹង គឺខ្លាំង។ ហើយខ្ញុំៗចង់និយាយ -- នៅពេលត្រឡប់ – ខ្ញុំសូមនិយាយកាត់មកដល់នេះហ្មង ពេលត្រឡប់ពីភ្នំពេញវិញមក ទុក្ខសោកទាំងឡាយមកលើរូបខ្ញុំគឺធំធេងណាស់។ ធំធេងរកអ្វីមិនបាន ហើយកូនតែងតែសួរថា ហេតុអីក៏ម្ដាយមិនដែលឃើញសប្បាយចិត្តសោះ? ខ្ញុំប្រាប់គាត់ -- កូនថាម្ដាយមិនដឹងសប្បាយយ៉ាងម៉េចទេ បើម្ដាយបាត់បង់អ្នកជាទីស្រឡាញ់ អ្នកមានគុណអស់ហើយ ម្ដាយ -- ខ្ញុំនិយាយ -- ខ្ញុំចង់ -- អត់ចង់បន្តទៀតទេ ខ្ញុំចេះរំឭកឡើង ខ្ញុំចង់តែវិល ចង់តែដួល។ ខ្ញុំៗគិតថា ប្រវត្តិវាជូរចត់ណាស់ គ្រាន់តែថារឿងកំសត់ រឿងអត់ហូប រឿងគេធ្វើបាប ទារុណកម្មមកលើវ៉ៃដំក៏អត់ដែលធ្វើបាបក្នុងតាមផ្លូវចិត្ត និងផ្លូវកាយបង្អត់អាហារ ជាពិសេសឈឺចាប់នឹងបង នឹងម្ដាយហ្នឹង។ អីចឹងខ្ញុំសូមនេះប៉ុណ្ណឹងចុះ ខ្ញុំដូចជាបន្តទៅទៀត ខ្ញុំអត់សូវស្រួលក្នុងខ្លួនម៉េចទេ។

[១៤:៤៨:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សៀង សុវិដា។ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ ហើយសូមលោកស្រីមានសុខភាពល្អ ហើយជួបតែនឹងសំណាងល្អ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពាសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកស្រី សៀង សុវិដា វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះក៏សូមអរគុណផងដែរ កញ្ញា ថ្លែន សុគន្ធណារ៉ា ដែលបុគ្គលិកអង្គការ ធី.ភី.អូ ដែលបានមកជួយសម្រួល អង្គុយជិតដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលផ្ដល់សក្ខីកម្ម ហើយលោក -- នាងកញ្ញាអាចសម្រាកបានហើយ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីដប់នាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសវនាការនៅវគ្គក្រោយនេះ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មដើម -- សាក្សីដែលមានរហស្សនាម 2-TCW-804។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៩ នាទី ដល់ម៉ោង ១៥:១១ នាទី)*

[១៥:១១:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ចាប់ពីពេលនេះតទៅ អង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-804 មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក អ៊ុត សេង៖**

**ឆ៖** ខ្ញុំជម្រាបសួរ ខ្ញុំបាទឈ្មោះ អ៊ុត សេង។

**ស៖** អរគុណលោក អ៊ុត សេង។ តើលោកកើតនៅខែឆ្នាំណា? កុំអាលទាន់ឆ្លើយតប!

**ឆ៖** កើតនៅឆ្នាំ -- ថ្ងៃទី០៧ មករា ឆ្នាំ១៩៥៦។

[១៥:១៣:២៦]

**ស៖** អរគុណលោក អ៊ុត សេង។ តើទីកន្លែងកំណើតរបស់លោក លោកកើតនៅទីកន្លែងណា?

**ឆ៖** បាទ ទីកន្លែងកំណើតនៅភូមិកងសៅ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។

**ស៖** ចុះទីលំនៅរបស់លោកបច្ចុប្បន្ន តើលោករស់នៅទីកន្លែងណា? ហើយលោកប្រកបមុខរបរអ្វី?

**ឆ៖** សព្វថ្ងៃខ្ញុំបាទរស់នៅភូមិកងសៅ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ដដែល។ មុខងារនៅធ្វើជាមន្ត្រីនៃមន្ទីរធនធានទឹកខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ហើយតើឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោក

ឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ អ៊ុត ខៀវ។ ម្តាយ លឿង អៀន។

**ស៖** បាទ អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទ ឈ្មោះ ខាំ សាឡាត់។ មានកូន៣នាក់ ប្រុសពីរ ស្រីមួយ។

[១៥:១៤:៥៨]

**ស៖** អរគុណលោក អ៊ុត សេង។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ញាតិលោកហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប និងបុគ្គលដែលត្រូវបានទទួលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពុំមានពាក់ព័ន្ធជាមួយ។

**ស៖** បាទ ហើយថាលោកបានស្បថរួចហើយ មុននឹងចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ តើពិតមែនដែរទេ?

**ឆ៖** ពិតៗមែន។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចលោកក្នុងនាមលោកជាសាក្សី។ លោក អ៊ុត សេង ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនាពេលវេលានេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច លោក អ៊ុត សេង ក្នុងនាមលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ហើយក្នុងនាមជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹងបានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

[១៥:១៧:១០]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក អ៊ុត សេង តើលោកធ្លាប់ផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើប៉ុន្មានដង? ហើយធ្វើនៅកន្លែងណា? ពេលណា?

**លោក អ៊ុត សេង៖**

**ឆ៖** ខ្ញុំបាទបានធ្វើម្តងនៅឆ្នាំ -- ខ្ញុំភ្លេចឆ្នាំ ២០០៥មិនដឹង ២០០៦ នៅៗទំនប់ស្ទឹងជីនិត នៅគម្រោងសាងសង់ទំនប់ស្ទឹងជីនិត។

**ស៖** អរគុណ។ ហើយនៅមុនពេលចូលមកមុខអង្គជំនុំជម្រះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុ ដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បានអានសាថ្មីម្តង។

[១៥:១៨:២០]

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ ថាតើលោកអាចបញ្ជាក់បានទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬក៏វាស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយ ដែលលោកបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** វាសមរម្យដែលត្រូវនឹងចម្លើយដែលខ្ញុំបានឆ្លើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដេញដោលលោកសាក្សី អ៊ុត សេង មុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថាភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពីរវគ្គនៃថ្ងៃសវនាការ ក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់នៃសវនាការ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិ។ តទៅនេះ ខ្ញុំមានសំណួរមួយចំនួនចង់សាកសួរលោកពាក់ព័ន្ធទៅនឹងកិច្ចការដែលលោកធ្លាប់ធ្វើនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ តើមុនឆ្នាំ១៩៧៥ លោករស់នៅឯណា?

[១៥:២០:០៧]

**លោក អ៊ុត សេង៖**

**ឆ៖** មុនឆ្នាំ៧៥ ខ្ញុំបាទ រស់នៅទីក្រុងភ្នំពេញជាមួយបងស្រី។

**ស៖** កាលនោះ លោកធ្វើអ្វីដែរ?

**ឆ៖** កាលនោះ ខ្ញុំបាទនៅរៀននៅវិទ្យាល័យទួលទំពូង នៅជាសិស្ស។

**ស៖** ចុះក្រោយមក នៅចន្លោះពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ តើលោករស់នៅឯណាដែរ?

**ឆ៖** ១៧ មេសា បានមកដល់ ខ្ញុំបាទបានចេញ ថាជម្លៀសចេញពីភ្នំពេញ ធ្វើដំណើរទៅភូមិកំណើតនៅភូមិកងសៅ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។ ដោយធ្វើដំណើរទៅ គឺថារយៈពេល១ខែទៅដល់ទីដៅ។

**ស៖** លោកត្រូវបានជម្លៀសពីភ្នំពេញទៅនៅស្រុកសន្ទុក ខេត្តកំពង់ធំ តើនៅទីនោះ លោកស្គាល់ទំនប់១មករាដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់ច្បាស់ទំនប់ ព្រោះនៅជិតភូមិខ្ញុំ។

[១៥:១២:៥៩]

**ស៖** ក្រៅពីនៅជិតភូមិលោក តើមានមូលហេតុអីទៀត ដែលនាំឲ្យលោកស្គាល់ទំនប់១មករាច្បាស់?

**ឆ៖** នៅឆ្នាំ៨០ ខ្ញុំបានចូលធ្វើការរាជការ រហូតថាខាងក្រសួងធនធានទឹក រហូតដល់បច្ចុប្បន្ន។

**ស៖** ខ្ញុំចង់ជម្រាបសួរលោក អំពីចន្លោះពេលឆ្នាំ៧៥ ដល់៧៩នោះ តើកាលនោះលោកស្គាល់

ទំនប់១មករា ក្រៅពីមូលហេតុដែលលោករស់នៅជិតទំនប់ហ្នឹង តើមានមូលហេតុអីផ្សេងទៀត ដែលនាំឲ្យលោកស្គាល់ច្បាស់? លោកបញ្ជាក់ជូនអង្គសវនាការមុននឹងថា ស្គាល់ច្បាស់ តើមានមូលហេតុអីផ្សេងពីហ្នឹងទៀត?

**ឆ៖** ក្រោយ -- ក្នុងអំឡុងឆ្នាំ ចុងឆ្នាំ៧៦ ខ្ញុំបាទបានគេឲ្យចូលទៅវរៈ ហៅថា វរយុវជន នៅឃុំកំពង់ថ្ម ដើម្បីគឺថា ជីក លើកទំនប់ប្រឡាយស្ទឹងជីនិត។ តែដំបូងគឺធ្វើ គឺថាប្រឡាយជាយៗទំនប់ ដោយសារទំនប់ស្ទឹងជីនិតយើងអត់ទាន់បានលើក លើកនៅឆ្នាំ៧៨។ យើងធ្វើតូចៗតាមជាយទំនប់ធំ។ និយាយទៅ ជាទំនប់របស់ឃុំសង្កាត់។

[១៥:២៣:៥៨]

**សៈ** ខ្ញុំឮសួរលោកប្រើពាក្យថា "ទំនប់ស្ទឹងជីនិត" តើទំនប់នេះមានឈ្មោះហៅផ្សេងទៀត ឈ្មោះជាផ្លូវការ កាលសម័យនោះ គេហៅឈ្មោះថាអ្វីដែរ ទំនប់ស្ទឹងជីនិតហ្នឹង?

**ឆ៖** សម័យ៧៥ គឺឈ្មោះ "ទំនប់១មករា" ដល់ក្រោយមក--

**សៈ** សូមអរគុណ។ តើលោកត្រូវគេចាត់តាំងឲ្យទៅលើកទំនប់១មករាហ្នឹង រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំមិនចាំរយៈពេល គ្រាន់តែខ្ញុំបានចូលវរយុវជនហ្នឹងទៅ គឺគេចាប់ផ្ដើមឲ្យក្រុមយុវជនហ្នឹងនិយាយរួមទំនប់ហ្នឹង វាជាទំនប់ភូមិភាគ វាមានតំបន់ វាច្រើនតំបន់ តំបន់៤២, ៤៣ ចូលរួមហ្នឹងមនុស្សវាច្រើន។

**សៈ** លោក -- តើខ្ញុំអាចនិយាយថា ទំនប់១មករាហ្នឹង -- តាមចម្លើយរបស់លោក តើមានអ្នកធ្វើការច្រើន មាននៅក្នុងតំបន់ អ្នកមកពីតំបន់៤២, ៤៣។ អ៊ីចឹងតើខ្ញុំអាចនិយាយបានថា ទំនប់១មករានេះ ត្រូវបានសាងសង់ដោយពលករដែលមកពីទំនប់ -- មកពីតំបន់៤២ និង៤៣ តើខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** អាចនិយាយបាន។

[១៥:២៦:០០]

**សៈ** បើតាមការសង្កេតរបស់លោក តើមានចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** មានចំនួនចូលរួមច្រើន យើងមិនអាចស្មានបានទេព្រោះខ្មៅ វាច្រើនណាស់ តែយើងដឹងៗតែកន្លែងដែលថាជិតដែលយើងធ្វើ ហើយយើងមើលទៅសងខាងទេ អត់មានៗពេលហ្នឹង អត់ដឹងច្បាស់។

**សៈ** តើលោកមានចាំបានទេថាទំនប់ហ្នឹងចាប់ផ្ដើមការដ្ឋាននៅឆ្នាំណា?

**ឆៈ** នៅដើមឆ្នាំ៧៨។

**សៈ** ដោយឡែក ក្នុងអំឡុងពេលដែលលោកត្រូវបានចាត់តាំងឲ្យបំពេញការងារនៅទំនប់នោះ តើកងរបស់លោកមានសមាជិកប៉ុន្មាននាក់?

**ឆៈ** នៅក្នុងកងរបស់ខ្ញុំមានគ្នា៣៣នាក់ វាមានបីក្រុម។ មួយក្រុមវា១២នាក់ ១០នាក់ទៅ១២នាក់។

**សៈ** តើការបែងចែកកងហ្នឹង គេបែងចែករបៀបម៉េចដែរ? គេបែងចែកទៅតាមស្ថានភាពដូចម្ដេចដែរ?

**ឆៈ** កងយុវជនសរុបមានគ្នាច្រើនប្រហែលជា៤០០ទៅ៥០០នាក់អ៊ីចឹង គឺចែកជាកងថាប៉ុន្មានកង គឺគេបែងចែក រាប់ដាក់ៗឲ្យតាមកង។

**សៈ** នៅក្នុងឯកសារ E3/5267 ERN ជាភាសាខ្មែរ 00271407, ជាភាសាអង់គ្លេស 00282355, ជាភាសាបារាំង 00482932 លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលគេចាត់ទុកថាយើងជាអ្នកខ្ជិល គេនឹងយកយើងដាក់ក្នុងក្រុមពិសេសមួយទៀត សម្រាប់តែអ្នកខ្ជិល។ ប្រសិនបើប្រឹងប្រែធ្វើការនៅ គេនឹង -- បើប្រសិនបើមិនប្រឹងប្រែងធ្វើការនោះ គេនឹងសម្លាប់ចោល។" តើត្រង់ឃ្លានេះ លោកចង់សំដៅទៅលើ លោកចង់មានន័យថាដូចម្ដេចដែរ ក្នុងការបែងចែកមានក្រុមពិសេសនេះ?

**ឆៈ** នេះខ្ញុំគ្រាន់តែយល់ថា ជាការព្រមាន ឬការបន្លាច។ មានក្រុមពិសេសហ្នឹងគឺ និយាយរួមគឺអ្នកដែលធ្វើការមិនដិតដល់ហើយ ព្រោះតែជីវភាព។ ដល់អ៊ីចឹងរាប់រយនាក់ អាចបានត្រឹម២០-៣០នាក់ទៅកងពិសេស។ ហ្នឹងគំនិតខ្ញុំ។ ដល់អ៊ីចឹងយើងត្រូវតែភ័យខ្លាចហើយ ខ្លាចយើងហូបមិនឆ្អែតផង ទៅចូលអាហ្នឹង ធ្វើការខ្លាំង វារឹតតែយ៉ាប់។ ដល់អ៊ីចឹង យើងត្រូវកុំឲ្យធ្វើម៉េចទៅកងពិសេស។

[១៥:៣០:០៨]

**សៈ** តើលោកមានបទពិសោធន៍យ៉ាងដូចម្ដេចចំពោះក្រុមអ្នកពិសេសនេះ ដែលលោកចាត់ទុកលោកអំមិញលើកឡើងថា ខ្លួនឯងហ្នឹងពិនិត្យឃើញថា អ្នកខ្ជិលក្នុងចំណោម៥០០នាក់ រើសបាន២០នាក់ ម៉េចបានលោកដឹងអ៊ីចឹង?

**ឆៈ** ធម្មតារបបហូបដែលចែកអ្នកមូលដ្ឋាន អ្នក១៧មេសាគឺខុសគ្នា។ ១៧មេសា គឺបបររាងរាវបន្តិចទៅ តិច។ មូលដ្ឋាន យុវជនមូលដ្ឋានអ៊ីចឹង គេរាងគ្រាន់បើ។ ដល់អ៊ីចឹងយើងហូបអត់ឆ្អែត--

**ស៖** សូមទោស ខ្ញុំចង់ជម្រាបសួរលោកបញ្ជាក់អំពីក្រុមពិសេស តើលោកដឹងក្រុមពិសេសហ្នឹងពីណាមក?

**ឆ៖** កងចល័តឃុំ យើងធ្វើការជីកប្រឡាយក្បែរៗគ្នា។ ពេលចប់ល្ងាច កងពិសេសត្រូវតម្រង់ជួរ វាយការណ៍ ឬក៏លើកហៅថាប្រជុំទិតៀនគ្នាទៅ។ គេបង្ហាញឲ្យយើងឃើញថា កងពិសេស គឺមានការវ៉ៃ ប៉ុនវ៉ៃ ក៏មិនខ្លាំងប៉ុន្មានដែរ គ្រាន់ថាជាការព្រមានដល់អ្នកក្បែរៗនោះ ដែលអ្នកមើលឃើញ។

[១៥:៣១:៥៦]

**ស៖** សូមអរគុណ។ ដោយឡែកចំពោះលក្ខខណ្ឌការងាររបស់លោកផ្ទាល់ខ្លួនវិញ តើនៅពេលនោះ លោកត្រូវបានចាត់តាំងឲ្យបំពេញការងារអ្វីដែរ?

**ឆ៖** យើងជាក្រុមរែកដី មានតែប្រធានកងទេដែលគេឈរ ឈរមើលកូនក្រុមធ្វើការ ក្រៅពីនោះ រែកដីទាំងអស់គ្នា។

**ស៖** ក្នុងការរែកដីហ្នឹង តើគេបែងចែកការងារម៉េចដែរ?

**ឆ៖** ឧទាហរណ៍មួយក្រុម ដូចថាមួយកង ប្រធានកងទទួលផែនការមកថា ១០០ម៉ែត្រសម្រាប់បីក្រុម។ យកមក គេចែកជាបីក្រុម ៣០ម៉ែត្រ ឬក៏៣០ម៉ែត្រឲ្យសម្រេចផែនការមួយថ្ងៃ។

**ស៖** ម៉ែត្រកន្លែងនេះ លោកសំដៅលើម៉ែត្ររត់ ឬក៏ម៉ែត្រគូប?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក អ៊ុត សេង៖**

**ឆ៖** វាជាម៉ែត្រប្រវែង។ ដោយសារគេគិតថា តាមស្ថានភាពដី ប្រឡាយអាចជ្រៅ អាចរាក់គេវាស់ចែកឲ្យច្រើន ប៉ុណ្ណឹង។

[១៥:៣៣:៤៤]

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់បន្តិច តាមធម្មតាការគិតអំពីមាឌគុណនៃដី គេច្រើនគិតពីម៉ែត្រគូប ប៉ុន្តែលោកមានប្រសាសន៍អំពីម៉ែត្រចម្ងាយ។ តើចម្ងាយនៃអី នៃទំនប់ នៃប្រឡាយ ឬក៏នៃស្អីផ្សេងទៀតដែលតាមបទពិសោធន៍ជាក់ស្តែងរបស់លោកនៅកាលនោះ?

**ឆ៖** ដូចថាមួយក្រុម៣០ ឬក៏១០ម៉ែត្រអ៊ីចឹង គឺជីកឲ្យបានជារាងប្រឡាយ ទំនប់សងខាង មួយស្អាត ប្រវែង១០ម៉ែត្រ។ បើថាជម្រៅជ្រៅ ឬក៏រាក់ វាវែងជាង១០ម៉ែត្រ។

**ស៖** លោកបញ្ជាក់អំពីការងារជាក្រុម មួយក្រុមគេចែកឲ្យ៣០ម៉ែត្រ ចុះនៅក្នុងក្រុមហ្នឹង មានបែងចែកការងារជាបុគ្គលតទៅទៀតទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៣៤:៥៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ សាក្សីមិនបានបញ្ជាក់ពីអង្គហេតុជាក់លាក់ថា ក្នុងក្រុមមួយប្រគល់ឲ្យភារកិច្ច៣០ម៉ែត្រ ក្នុងការជីកដីនេះទេ បាទ។ គាត់គ្រាន់តែលើកជាឧទាហរណ៍ថាវា បើសិនជាក្នុងកងហ្នឹង១០០ម៉ែត្រ អ៊ីចឹងវាអាច៣០ម៉ែត្រក្នុងក្រុមអ៊ីចឹងទៅ។ ហើយគាត់លើកជួនកាលទៅអាចថា១០ម៉ែត្រ ឬក៏វែងជាងនេះ ឬក៏ខ្លីជាងនេះ។ បាទអ៊ីចឹងបើសិនជាតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិលើកអំពីប្រវែងជាក់លាក់ អាហ្នឹងជាចំណុចមួយមិនៗសមស្របទេ។ សូមអរគុណ។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** នៅពេលនោះ ខ្ញុំស្តាប់ឮថាចែកជាបីក្រុមក្នុង១០០ម៉ែត្រ ហើយគាត់លើកឧទាហរណ៍នៅក្នុងហ្នឹងថា មួយក្រុមអាច៣០ម៉ែត្រ។ បើសិន -- អ៊ីចឹងខ្ញុំសូមដូរទៅជាសំណួរជាក់លាក់មួយថាតើ នៅក្នុងហ្នឹង តាមចំនួនដែលលោកទទួលបានកាលនោះ បែងចែកជាក្រុមហ្នឹង តើលោកទទួលបានចំនួនជាបុគ្គលទេ ជាប្រវែងជាបុគ្គលទេ? បានន័យថា តើក្នុងម្នាក់លោកត្រូវបំពេញការងារប៉ុន្មានក្នុង១ថ្ងៃ?

**លោក អ៊ុត សេង៖**

**ឆ៖** វាគ្រាន់តែក្នុងកង -- ក្នុងក្រុមដូចថា យើងចែកជាគ្នាពីរនាក់ បីនាក់តាមដែលយើងគិតថាយើងស្រឡាញ់អ្នកណា អាចរួមកម្លាំងបង្កើយ ដូចថា១ម៉ែត្រ ឬក៏២ម៉ែត្រម្នាក់ឯងរួច ឬក៏ពីរនាក់រួចយើងស្រឡាញ់ យើងយកគ្នាចែកគ្នាជាពីរនាក់ ឬក៏បីនាក់បន្តទៅទៀត។ យើងមិនដែល -- ខ្ញុំមិនដែលបានចែកដាច់ថា តែឯងហ្នឹងលើកឲ្យបានប៉ុន្មានគូបនោះអត់ទេ ប៉ុន្តែបើចែកពីរនាក់ ផែនការគឺត្រូវតែរួច

មិនកំណត់ថាប៉ុន្មានគូបទេ ម៉ៃហ្នឹងគឺត្រូវតែរួច។ ប៉ុន្តែយើង--

[១៥:៣៧:១៥]

**ស៖** សូម១អញ្ជើញលោកបន្តនូវអ្វីដែលលោកចង់លើកឡើងអំមិញ។

**ឆ៖** ភ្លេច។

**ស៖** អំមិញ -- អម្បាញ់មិញនេះ លោកលើកឡើងពាក្យថាក្រុមមួយសារទៀត នៅខាងលើ លោកលើកឡើងមួយក្រុមមាន១០នាក់ ឬ១២នាក់ ឥឡូវលោកលើកឡើងពីរ ឬបីនាក់ទៀត។ តើក្រុម១ ខាងក្រោយនេះជាក្រុមអ្វី ហើយមានការកំណត់ផែនការជាក់លាក់ប៉ុនណាដែរ?

**ឆ៖** យើងបែងចែកតាមកម្លាំង ដូចថា១០នាក់ យើងត្រូវវាស់ចែកដីគ្នាបន្តទៅទៀតដើម្បី -- បើអ្នកចង់ម្នាក់ក៏បាន ចង់រួមគ្នាពីរនាក់ក៏បាន។ ធ្វើម៉េចឲ្យរួចថាឥឡូវ របបម្នាក់១ម៉ែត្រអ៊ីចឹង យើងបូកគ្នាពីរនាក់២ម៉ែត្រ ធ្វើទៅពីរនាក់ធ្វើឲ្យរួច។ យើងជួយគ្នាតែពីរនាក់ទេ អ៊ីចឹង។

**ស៖** តាម១ប្រសាសន៍លោកលើកនៅចំណុចចុងក្រោយនេះថា ពីរនាក់២ម៉ែត្រ ម្នាក់១ម៉ែត្រ តើខ្ញុំស្តាប់បានអ៊ីចឹងជាការពិតទេ?

*(សម្រាករយៈពេលខ្លី)*

ខ្ញុំសូមសួរសំណួរចុងក្រោយសាឡើងវិញលោកប្រធាន។ នៅសំណួរចុងក្រោយរបស់ខ្ញុំអំមិញហ្នឹង គឺខ្ញុំស្រង់ចម្លើយ -- ប្រសាសន៍របស់លោកថាពីរនាក់២ម៉ែត្រ អ៊ីចឹងបានន័យថា អ្វីដែលខ្ញុំលើកឡើងនេះជាការ១ពិតតាមអ្វីដែលលោកបានលើកឡើងនៅមុននេះ អ៊ីចឹងមែនទេ?

**ឆ៖** ២ម៉ែត្រ ខ្ញុំចង់និយាយម៉េច។ ២ម៉ែត្រហ្នឹងយើងត្រូវធ្វើឲ្យហើយ ជាទំនប់ទាំងសងខាងបាតប្រឡាយ។ យើងដឹង -- អត់ដឹងថាប៉ុន្មានគូបទេ។ អ៊ីចឹងជួនកាលជ្រៅ ជួនកាលរាក់ ឲ្យតែរួចផែនការគឺចប់។

**ស៖** តើផែនការហ្នឹងដាក់មកពីណា ជ្រៅ ឬរាក់ អ្នកណាអ្នកកំណត់? ហើយជម្រៅដែលជ្រៅបំផុតហ្នឹងអាចមានជម្រៅប្រហែលប៉ុន្មានម៉ែត្រ ហើយទទឹងមាត់ប្រឡាយហ្នឹងប៉ុន្មានម៉ែត្រ?

[១៥:៤១:១១]

**ឆ៖** អានេះ ខ្ញុំនិយាយពីប្រឡាយតូចល្មម និងប្រឡាយធំ គឺថាខ្នង៥ម៉ែត្រ ជម្រៅហៅថា បាត -- មាត់ប្រឡាយ៤ម៉ែត្រ ឬជម្រៅ២ម៉ែត្រ ឬក៏១,៥ម៉ែត្រ តាមជម្រាលដី។ គេមានគេវាស់ស្ទង់ឲ្យយើងស្រេច យើង។

**ស៖** ខ្ញុំសូមសួរតាមរយៈចម្លើយលោកនេះ ខ្ញុំសូមសួរបញ្ជាក់ឡើងវិញថា អ្វីដែលខ្ញុំជម្រាបសួរលោកនេះ គឺកិច្ចការដែលលោកទទួលបាននៅទំនប់១មករា។ តែលោកប្រើពាក្យអំមិញថា ប្រឡាយឃុំហ្នឹង អាហ្នឹងនៅជាៗវាពាក់ព័ន្ធនឹងទំនប់១មករា -- ការងារដែលលោកទទួលបាននៅទំនប់១មករា ឬការងារផ្សេងទៀត? ព្រោះខ្ញុំដឹងថា មួយចន្លោះពេលហ្នឹង លោកធ្វើការងារច្រើនកន្លែង ប៉ុន្តែអ្វីដែលខ្ញុំលើកឡើង គឺលើកឡើងតែការងារនៅទំនប់១មករា តែប៉ុណ្ណោះ។ អ៊ីចឹងសូមលោកបញ្ជាក់កន្លែងនេះឲ្យច្បាស់បន្តិច។ តើការងារដែលយើងកំពុងតែនិយាយគ្នា ដែលខ្ញុំកំពុងសាកសួរលោកហ្នឹង ជាការងារដែលលោកទទួលបាននៅទំនប់១មករា មែនឬទេ?

**ឆ៖** ខ្ញុំនិយាយអំមិញមិនមែនទេ គឺទំនប់តូចចេញពីស្ទឹង -- ពី១មករា។ ប៉ុន្តែបើទំនប់១មករាដែលៗក្រុម ឬក៏វរយុវជនខ្ញុំធ្វើហ្នឹង គឺមានទំហំធំ។ មាត់លើប្រហែលជា២០ម៉ែត្រ មាត់ប្រឡាយប្រហែល២០ម៉ែត្រ ខ្នង៥ម៉ែត្រ កម្ពស់តាមស្ថានភាពដី ២ទៅ៣ម៉ែត្រ។

[១៥:៤៣:០២]

**ស៖** សូមលោកកុំមានការភ័ន្តច្រឡំអំពីទំហំប្រឡាយ និងទំហំទំនប់១មករា។ អ្វីដែលខ្ញុំជម្រាបសួរលោកនៅពេលនេះ គឺទំហំការងារដែលលោកត្រូវបានចាត់តាំងឲ្យធ្វើនៅទំនប់១មករា នៅអំឡុងពេលដែលលោកធ្វើការនៅទំនប់១មករា។ អ៊ីចឹងសូមលោកបញ្ជាក់ឲ្យច្បាស់កន្លែងនេះ។ តើការងារដែលលោកធ្វើ២ម៉ែត្រ សម្រាប់គ្នាពីរនាក់ហ្នឹងលោកធ្វើនៅទំនប់១មករា មែនទេ?

**ឆ៖** និយាយ២ម៉ែត្រអំមិញ ខ្ញុំនិយាយពីប្រឡាយតូចរបស់ឃុំ កងចល័តឃុំ មិនមែនទំនប់១មករា។

**ស៖** ចុះកាលលោកធ្វើការនៅទំនប់១មករា លោកទទួលផែនការយ៉ាងដូចម្តេចដែរ?

**ឆ៖** នៅទំនប់១មករា យើងធ្វើជាក្រុម ជាកង ដូចថា៣០ម៉ែត្រអ៊ីចឹង យើងធ្វើទាំងអស់គ្នា។ អាហ្នឹងដែលខ្ញុំនិយាយអំមិញ គឺនិយាយពីទំនប់ប្រឡាយមួយដែលចេញពី ១មករា ជាប្រឡាយឃុំ។

**ស៖** ខ្ញុំសូមបញ្ជាក់ជូនលោកមួយសាទៀតថា រាល់សំណួរដែលៗខ្ញុំជម្រាបសួរលោកពេលនេះ គឺពាក់ព័ន្ធតែទំហំការងារនៅ -- ទំហំការងារ និងលក្ខខណ្ឌការងារផ្សេងៗនៅទំនប់១មករាប៉ុណ្ណោះ។ អ៊ីចឹងការងារដែលលោកទទួលបាន គឺ៣០ម៉ែត្រសម្រាប់ក្រុមមួយដែលមានគ្នាប៉ុន្មានដែរ លោកអត់បានបញ្ជាក់ទេមុនហ្នឹង? សូមលោកបញ្ជាក់ពីទំហំការងារហ្នឹង ឲ្យបានច្បាស់បន្តិច ការងារនៅទំនប់១មករា។

[១៥:៤៥:១៤]

**ឆ៖** ខ្ញុំសូមបញ្ជាក់ពីកងរបស់ខ្ញុំ៣០នាក់ហ្នឹង គឺធ្វើការរួមគ្នានៅទំនប់១មករា។

**ស៖** ចុះទំហំការងារដែលលោកទទួលបានទំហំប៉ុនណាដែរ? បានន័យថាតើលោកត្រូវបំពេញការងារប៉ុន្មានៗក្នុង១ថ្ងៃ?

**ឆ៖** ការងារយើងចែក១ថ្ងៃពី១ម៉ែត្រគូប អាហ្នឹងចូលដល់ម៉ែត្រគូប និង១,៥ម៉ែត្រគូបក្នុងបុគ្គលម្នាក់។

**ស៖** តើក្នុងការបំពេញការងារនោះ មានការប្រើប្រាស់គ្រឿងយន្តជាជំនួយទេ?

**ឆ៖** មិនមានគ្រឿងចក្រជំនួយទេ។

**ស៖** តើនៅពេលបំពេញការងារនៅទំនប់១មករាហ្នឹង លោកមានសិទ្ធិអាចឈប់សម្រាកដែរឬទេក្នុងពេលបំពេញការងារ?

**ឆ៖** បើយើងអត់ឈឺអត់អី យើងពុំមានសិទ្ធិឈប់សម្រាកដាច់ខាត។

**ស៖** ចុះក្នុងៗអំឡុងពេលយើងបំពេញការងារហ្នឹង ក្រៅពីពេលក្រៅពីការបំពេញកិច្ចការហ្នឹង ឧទាហរណ៍ថា យើងស្រេកទឹក ឬក៏ចង់បត់ដៃបត់ជើងអី យើងធ្វើដូចម្តេច?

**ឆ៖** យើងសុំអនុញ្ញាតពីប្រធានកង តែហាមយូរ ព្រោះមានព្រៃជិតៗអីចឹង យើងបត់ដៃបត់ជើងហាលងៀតហាលវាលអីចឹងទៅ។

**ស៖** ចុះនៅពេលបំពេញការងារហ្នឹងមានអ្នកឃ្លាំមើលដែរ?

[១៥:៤៨:០៥]

**ឆ៖** ក្រៅពីប្រធានកង ខ្ញុំដូចជាមិនអាច មិនដឹង ព្រោះវាប្រជាជនច្រើន យើងមិនដឹងពីណាជាពីណាទេ។

**ស៖** ចុះចំពោះទំនាក់ទំនងក្នុងក្រុម សមាជិកក្នុងក្រុមហ្នឹង តើលោកមានសិទ្ធិនិយាយស្តីគ្នាទំនាក់ទំនងរាប់អានគ្នាជាធម្មតា ឬយ៉ាងដូចម្តេចដែរ?

**ឆ៖** យើងពេលពលកម្មយើងមាត់ធម្មតា ប៉ុន្តែមិនអាចជាក្រុមអង្គុយប្រាជ្ញ ឬជជែកគ្នា អត់បាន។

**ស៖** តាមបទពិសោធន៍របស់លោកបំពេញការងារនៅទីនោះ តើលោកធ្លាប់ជួបគ្រោះថ្នាក់ការងារ ឬក៏ធ្លាប់ឃើញមានអ្នកជួបគ្រោះថ្នាក់ការងារដែរឬទេ?

**ធ៖** ធ្លាប់ឃើញ។

**ស៖** យ៉ាងម៉េចដែរ គ្រោះថ្នាក់អីដែរ?

**ធ៖** ការហែរហត់អាចដួល ទន់ជង្គង់អ៊ីចឹង។

**ស៖** មានៗច្រើនទេករណីបែបហ្នឹង?

**ធ៖** វាមិនមានច្រើនប៉ុន្មានទេ ប៉ុន្តែយូរៗយើងឃើញគេដួលអីអ៊ីចឹងម្តង។

[១៥:៥០:០៩]

**ស៖** នៅក្នុងឯកសារ E3/5267 ដែលមាន ERN ជាភាសាខ្មែរ 00271408, ជាភាសាអង់គ្លេស 00282355 និងជាភាសាបារាំង 00482933។ លោកបានលើកឡើងថា "គឺធ្វើការពីម៉ោងប្រាំ វាបភ្លឺ គេបានចាក់មីក្រូនៅពេលយើងភ្ញាក់ហើយ។ គេផ្លុំកញ្ចែ ពួកខ្ញុំនឹងក្រោកឡើង ទៅដល់កន្លែងធ្វើការ ហើយធ្វើរហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់។ បន្ទាប់មកត្រូវចូលធ្វើការវិញ នៅម៉ោងរសៀល -- ម៉ោងមួយរសៀលដល់ម៉ោងប្រាំល្ងាច។ ប៉ុន្តែផែនការពិសេសនោះ នឹងត្រូវធ្វើ -- ប៉ុន្តែបើមានផែនការពិសេស នោះយើងត្រូវធ្វើការពីម៉ោងប្រាំមួយសាមសិបនាទីយប់ ទៅដល់ម៉ោងប្រាំបួនយប់ ហើយមានអំពូលភ្លើងបំភ្លឺផង។ ការធ្វើការងារយប់នេះ គឺសុទ្ធតែជារឿងពិសេសហើយ ព្រោះនៅពេលយប់មានការបាត់មនុស្សក្នុងកងរបស់គេ។" ខ្ញុំចង់ជម្រាបសួរលោកបញ្ជាក់ឲ្យច្បាស់ថា តើពិសេសនៅកន្លែងនេះ លោកចង់បញ្ជាក់មានន័យថាម៉េច?

**ធ៖** ខ្ញុំចង់ថា ពេលយប់ ពិសេសគេស្រួលចាប់ ឬស្រួលហៅទៅក្រៅ ដើម្បីទៅកន្លែងងងឹតទៅគេនឹងធ្វើការចាប់ចង យប់។ ចេញតែពីកន្លែងភ្លឺតែបន្តិច គឺងងឹត។ បានខ្ញុំដឹង ព្រោះកងនៅក្បែរគ្នា ដល់ស្អែកឡើង វាបាត់មនុស្ស អ៊ីចឹង។

**ស៖** តើការងារពិសេសបែបនេះ កើតឡើងញឹកញាប់ទេ?

**ធ៖** បានដឹងតែម្តងគត់។

**ស៖** នៅក្នុងអំឡុងពេលលោកបំពេញការងារនៅទំនប់១មករាហ្នឹង ជារដូវអីដែរ ប្រាំងឬវស្សា?

**ធ៖** ជារដូវប្រាំង។

[១៥:៥៣:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំមិនជំទាស់នោះទេ ក៏ប៉ុន្តែខ្ញុំសូមធ្វើការកត់សម្គាល់មួយទាក់ទងទៅនឹងសំណួរនេះ។ សហព្រះរាជអាជ្ញារងបានដកស្រង់ចម្លើយរបស់គាត់ ហើយខ្ញុំឃើញជាភាសាខ្មែរ ហើយនិងភាសាបារាំងនោះ ម៉ោងធ្វើការងារនៅពេលរសៀល គឺចន្លោះម៉ោងដប់បីទៅម៉ោងដប់ប្រាំ ក៏ប៉ុន្តែនៅភាសាអង់គ្លេសនោះ គឺម៉ោងដប់បីដល់ម៉ោងដប់ប្រាំបីឯណោះ។ អ៊ីចឹងខ្ញុំឆ្លៀតយកឱកាសនេះ ដើម្បីធ្វើការកត់សម្គាល់ ដើម្បីឲ្យកែប្រែភាពខុសគ្នានេះ នៅពេលនេះតែម្តង លោកប្រធាន។ អ៊ីចឹងខ្ញុំគ្រាន់តែសុំបញ្ជាក់ប្រាប់ទៅព្រះរាជអាជ្ញាហ្នឹង គឺថាពិតជាអ៊ីចឹងហើយ គឺជាភាសាខ្មែរ គឺចន្លោះម៉ោងដប់បី ដល់ម៉ោងដប់ប្រាំពីរ។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** តើនៅពេលដែលលោកបំពេញការងារនៅទំនប់១មករានោះ ជារដូវប្រាំង ឬក៏ជារដូវវស្សា?

**លោក អ៊ុត សេង៖**

**ឆ៖** វាជារដូវប្រាំង។

**ស៖** នៅពេលនោះ មានម្លប់ជ្រក ឬក៏នៅពេលបំពេញការងារហ្នឹង គេមានបាំងម្លប់ឲ្យលោកធ្វើការទេ?

[១៥:៥៤:៥៨]

**ឆ៖** មិនមានម្លប់ ឬក៏ធ្វើរបាំងជ្រកអីទេ។ មានតែមួកពាក់ខ្លួនឯង។

**ស៖** ចុះនៅពេលបំពេញការងារហ្នឹង បើសិនជាក្តៅខ្លាំង តើពលករណាម្នាក់អាចសុំច្បាប់ឈប់សម្រាកមួយភ្លែតសិន បានបន្តការងារទៅទៀតក្រៅពីពេលដែលសុំបត់ដៃបត់ជើងហ្នឹងបានទេ?

**ឆ៖** និយាយទៅគឺ ៗមានម៉ោងសម្រាកតូច និយាយទៅគេថាសម្រាកតូចមួយភ្លែត។

**ស៖** ក្រៅពីម៉ោងសម្រាកតូចនោះ គឺអត់មានម៉ោងណាផ្សេងទៀតទេ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប!

**លោក អ៊ុត សេង៖**

**ឆ៖** ក្រៅពីសម្រាកតូចយើងអត់មានអីទៀតទេ ទាល់តែចប់ម៉ោងការងារគឺយើងមករោងស្នាក់នៅវិញ ហូបបាយ។

**លោក ស្រ៊ា រតនៈ៖**

សូមជម្រាបលោកប្រធាន ខ្ញុំសុំបញ្ចប់ការតាំងសំណួររបស់ខ្ញុំនៅពេលនេះ ហើយសុំអនុញ្ញាតឲ្យសហការីរបស់ខ្ញុំលោក ត្រាវិស បន្តសំណួរបន្តទៀត។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញបាទ!

[១៥:៥៦:៣៥]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** សូមជម្រាបសួរ លោក អ៊ុត សេង។ ខ្ញុំចង់សួរលោកសំណួរបន្ថែមបន្តិចទៀតទាក់ទងទៅនឹងក្រុមពិសេសរបស់អ្នកខ្ជិលច្រអូសដែលលោកទើបតែនិយាយប្រាប់។ ខ្ញុំសូមអានទូវកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺនៅទំព័រជាភាសាខ្មែរមានលេខ 00271407, ជាភាសាអង់គ្លេស 0028 2355 និងភាសាបារាំងមានលេខ 00482928។ លោកបាននិយាយដូចតទៅនេះ៖ "អ្នកដែលគេចាត់ទុកថាជាអ្នកខ្ជិលច្រអូសត្រូវគេដាក់ចូលទៅក្នុងក្រុមផ្សេង។ ប្រសិនបើយើងមិនប្រឹងធ្វើការនោះទេ គេនឹងសម្លាប់ចោល។" សុំបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំ -- គឺថាដំបូងគេសួរលោកថាលោកធ្វើយ៉ាងណាដឹងអំពីក្រុមពិសេសនេះ ហើយលោកនិយាយថា គឺថានៅក្នុងកងហ្នឹង គឺថាគេគិតអ្នកដែលខ្ជិលច្រអូស។ ដូច្នេះចង់ដឹងថា តើគេបែងចែកយ៉ាងណាអ្នកដែលខ្ជិលច្រអូសៗគេបែងចែកដោយលក្ខណៈរបៀបណា?

**លោក អ៊ុត សេង៖**

**ឆ៖** និយាយរួមកងពិសេស គឺប្រមូលជនដែលខ្ជិលធ្វើការ រត់ចោលការងារ ឬក៏ទៅផ្ទះអត់ច្បាប់ គឺថាមិនគោរពអង្គការវិន័យ។

[១៥:៥៨:២៨]

**ស៖** ខ្ញុំសូមសង្ខេបទៅលើអ្វីដែលលោកបានឆ្លើយ។ គេសួរលោក ថាតើក្រុមពិសេសនេះ ខុសប្លែកពីក្រុមធម្មតាយ៉ាងដូចម្តេច ហើយលោកនិយាយថា ខ្ញុំសុំដកស្រង់៖ "គេតាមដាន ប្រសិនបើគេចាត់ទុកថាខ្ជិលច្រអូស គេនឹងវាយដំធ្វើបាប។ ខ្ញុំធ្លាប់បានឃើញគេវាយមនុស្ស។" ហើយខាងក្រោមបន្តិចលោកនិយាយថា៖ "គេវាយធ្វើបាបតែក្រុមពិសេសទេ"។ លោកបាននិយាយថា លោកបានឃើញគេវាយ

ដំមនុស្សនៅក្នុងក្រុមកងពិសេសហ្នឹង តើលោកអាចរៀបរាប់បានទេ ថាតើជាមនុស្សបែបណាដែលគេវាយធ្វើបាប? ឬក៏មានលក្ខណៈបែបណាដែរ ដែលគេវាយនោះ?

**ធ៖** និយាយរួម ជនដែលចូលទៅកងពិសេសច្រើនតែជាយុវជនយុវនារីមូលដ្ឋាន ដែលគេហៅថាដូចជាគេមានសិទ្ធិ គេមិនសូវខ្លាចអង្គការវិន័យ សឹងតែថាគ្មានច្បាប់គ្មានទម្លាប់អីចឹងទៅ។ គេ ដូចថាគេឲ្យធ្វើការហួសម៉ោងជាងអ្នកធម្មតា អ្នកអត់កំហុស។ ខ្ញុំថា គេវាយដំនោះ គ្រាន់តែជារំពាត់ មិនមែនជាវ៉ៃដំឲ្យឈឺស្រែកអួយអាយទេ គ្រាន់តែវ៉ៃធម្មតា ឈឺដែរ មួយឆ្វាច់ដូចមោងអីចឹង គឺគេគំរាមដល់អ្នកដទៃ។

**សះ** តើលោកអាចរៀបរាប់បានទេ អំពីការវាយមួយរំពាត់អីហ្នឹង? តើនរណាជាអ្នកវាយ?

**ធ៖** គឺជាប្រធានកងពិសេស។ ប្រធានកងពិសេស មាននារី និងយុវជន ព្រោះក្នុងកងហ្នឹងវាមាននារីផង យុវជនផង។

[១៦:០១:២១]

**សះ** តើគេវ៉ៃមួយរំពាត់ គេវ៉ៃរំពាត់ហ្នឹង គេវ៉ៃនៅកន្លែងណាដែរ?

**ធ៖** គេវ៉ៃនៅកំភួនជើង។

**សះ** តើលោកអាចប្រាប់បានទេ ថាគេវ៉ៃមនុស្សហ្នឹង គេវ៉ៃនៅកន្លែងសាធារណៈដែលអ្នកធ្វើការដទៃទៀតអាចឃើញ ឬមួយក៏វ៉ៃនៅកន្លែងផ្សេងទេ?

**ធ៖** គឺគេតម្រៀបជួរ តម្រង់ជួរ គេវ៉ៃឲ្យសាធារណជន ឲ្យអ្នកដទៃឃើញ ដើម្បីគំរាមកំហែង។

**សះ** តើលោកធ្លាប់ឃើញវាយរំពាត់ហ្នឹងញឹកញាប់ដែរឬទេ?

**ធ៖** មិនញឹកញាប់ទេ ព្រោះធ្វើការអាចបែកគ្នា អាចឆ្ងាយពីគ្នាអីចឹងទៅ។

**សះ** តើអ្នកដែលត្រូវគេវ៉ៃនឹងរំពាត់ហ្នឹង គាត់មានប្រតិកម្ម ឬក៏គាត់ធ្វើបែបណាដែរនៅពេលគាត់ត្រូវគេវ៉ៃនោះ?

**ធ៖** គឺស្ងៀម។

**សះ** តើពួកគាត់មានរបួសស្នាមអី ក្រោយពេលគេវ៉ៃនឹងរំពាត់ហ្នឹងដែរឬទេ?

**ធ៖** មិនជាធំដុំ។

[១៦:០៣:៣៣]

**សះ** មុននេះបន្តិចលោកនិយាយថា លោកមិនអាចជជែកជាមួយនឹងអ្នកធ្វើការជាមួយលោកខ្លះ

នៅពេលដែលលោកធ្វើការ ប៉ុន្តែពេលខ្លះលោកថា លោកអាចជជែកគ្នាបាន។ តើលោកអាចបញ្ជាក់តើលោកធ្លាប់ជជែកជាមួយអ្នកធ្វើការជាមួយលោកពីការវាយនឹងរំពាត់ហ្នឹងដែរឬទេ?

**ឆ៖** មិនដែលទេ។ រឿងអ៊ីចឹងៗ យើងអត់ប៊ានអនិយាយទេ និយាយបានតែពាក្យល្អៗសម្រាប់គ្នាឯង។ ខ្លាចអ្នកដទៃឮ យើងនឹងមានរឿងរ៉ាវតទៅទៀត។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសង្កេតឃើញថា ឥឡូវនេះហាក់ដូចជាដល់ម៉ោងដែលយើងឈប់សម្រាកហើយ តើលោកប្រធានសម្រេចយ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ មុននឹងសម្រាកនៅរសៀលនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានទទួលព័ត៌មានពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញកាលពីម្សិលមិញថា សាក្សីដែលមានរហស្សនាម 2-TCW-830 មិនអាចមកផ្តល់សក្ខីកម្មនៅសប្តាហ៍នេះបានទេ ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ហើយបន្ទាប់ពីអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-887 ចប់ អង្គជំនុំជម្រះនឹងចូលស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងជាមួយនឹងអង្គហេតុការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ចាប់ពីថ្ងៃចន្ទ ទី០៨ ខែមិថុនា ឆ្នាំ២០១៥តទៅ។ ហើយបន្ទាប់ពីបញ្ចប់អង្គហេតុការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងរួច អង្គជំនុំជម្រះនឹងត្រឡប់មកស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-830 វិញ ដើម្បីបញ្ចប់អង្គហេតុការដ្ឋានទំនប់១មករា នៅមុនបំណាច់ឆ្នាំ -- បំណាច់ខែមិថុនា ឆ្នាំនេះ។ បាទ សូមភាគីជ្រាប។

[១៦:០៥:៤០]

បាទ សវនាការដល់ថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៣ ខែមិថុនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី អ៊ុត សេង ហើយនិងអាចផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-887 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ អង្គជំនុំជម្រះអរគុណលោក អ៊ុត សេង ដំណើរការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំ

បួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ុត សេង វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*